ឆ្នាំគ្រួសារ ២០១៧-២០២០

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១០ សម្រាប់ខែមករា ឆ្នាំ២០១៨ លក់តម្លៃ ១០០០រៀល

លេខ ១០៧



# អបអរសាទបុណ្យព្រះយេស៊ូប្រសូត! សួស្តីឆ្នាំថ្មី ២០១៨

CSC
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ: ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# ពលរដ្ឋកម្ពុជាមួយចំនួនកំពុងតែត្រៀមខ្លួនសម្រាប់បុណ្យព្រះយេស៊ូប្រសូត

បើទោះបីជាមិនមែនជាគ្រីស្តសាសនិក ប៉ុន្តែពលរដ្ឋកម្ពុជានៅតាមទីប្រជុំជន និង ទីក្រុងសំខាន់ៗ បានត្រៀមខ្លួនរួចហើយ ដើម្បីរីករាយ និងទទួលអំណរសប្បាយ នៅថ្ងៃបុណ្យព្រះយេស៊ូប្រសូត ដែល សាធារណជនទូទៅស្គាល់ថា បុណ្យណូអែល ឬបុណ្យគ្រីស្តស្មាក់នោះ។

កញ្ញា ជា ទេវិន ជាទេសចរនៅក្នុងស្រុកដែលបានទៅលេងកំសាន្តនៅទីក្រុងសៀមរាប បានអះអាង ថា កញ្ញាបានណាត់មិត្តភក្តិរៀបចំកម្មវិធីសប្បាយៗរួចហើយ។

កញ្ញាបានបញ្ជាក់ថា "អត់មានអ្វីពិសេសទេ តែនៅថ្ងៃណូអែលនេះ ខ្ញុំមានណាត់ញ៉ាំអីជុំគ្នាជាមួយ នឹងមិត្តភក្តិកាលនៅរៀនមហាវិទ្យាល័យជាមួយគ្នា"។

កញ្ញាបានបន្តទៀតថា ថ្ងៃនោះដូចជាគ្មានអ្វីពិសេសសម្រាប់កញ្ញាទេ ប៉ុន្តែវាជាទម្លាប់ដែលកញ្ញា និងមិត្តភក្តិបានធ្វើ៤ទៅ ៥ឆ្នាំហើយ ពោលគឺតាំងពីកញ្ញានៅរៀនមហាវិទ្យាល័យមកម្ល៉េះ។ កញ្ញា បានបន្តទៀតថា កាលនៅរៀនបើតាមការចងចាំរបស់កញ្ញា គឺអាចមានលេងប៉ាតម្សៀ ជូនអំណោយឲ្យគ្នា ហើយនឹងទៅញ៉ាំអីជុំគ្នាបន្តិចបន្តួចដដែលៗហ្នឹង ប៉ុន្តែដល់មានការងារធ្វើ គឺមិនមានអីលែង ដូចជាកូនក្មេងទៀតទេ គឺគ្រាន់តែជួបជុំគ្នានិយាយសួរសុខទុក្ខ និយាយលែង ចែកបទពិសោធន៍តិចតួចប៉ុណ្ណោះ។

លោក មុន្នី តុលា ជាមន្ត្រីរាជការមួយរូប បានមានប្រសាសន៍ថា សម្រាប់បុណ្យណូអែលនេះ គេមានអត្ថន័យរបស់គេជាពិសេសសម្រាប់បងប្អូនខាងគ្រីស្តសាសនា ប៉ុន្តែលោកនិងមិត្តភក្តិភាគ ច្រើនមិនបានចាប់អារម្មណ៍អំពីអត្ថន័យស៊ីជម្រៅទេ ដោយគ្រាន់តែយកថ្ងៃនោះជាថ្ងៃក្រហមសម្រាប់បង្កើតកម្មវិធីសប្បាយៗនៅក្នុងគ្រួសារ ឬជាមួយនឹងមិត្តភក្តិ។

លោកបានបញ្ជាក់ថា "ខ្ញុំដូចជាមិនចូលរួមអបអរបុណ្យនេះជារៀងរាល់ឆ្នាំពេកទេ ប៉ុន្តែក៏មិនជាស្ងួរខកខានដែរទេ ដោយជួនកាលក៏មានកម្មវិធីជាមួយនឹងមិត្រភក្តិទៅ ហើយជួនកាលក៏ជាមួយគ្រួសារទៅ"។

លោក ឈៀង យ៉ានី ជាភ្ញៀវទេសចរមួយរូប បានមានប្រសាសន៍នៅជិតផាប់ស្ទ្រីត ដែលជាកន្លែងប្រមូលម្តុំហាងបារាំងជាច្រើននៅខេត្តសៀមរាបថា បុណ្យណូអែល មិនមែនជាបុណ្យជាតិ អ្វីនោះទេ ប៉ុន្តែទាំងលោក និងក្រុមគ្រួសារ ព្រមទាំងមិត្តភក្តិជាច្រើន គឺរីករាយនៅថ្ងៃបុណ្យនេះ។

លោកបានបន្តទៀតថា បុណ្យនេះវាត្រូវមកដល់នៅថ្ងៃទី២៥ ខែធ្នូឯណោះទេ ប៉ុន្តែខ្មែរយើងខ្លះចាប់ផ្តើមរៀបចំតាំងលំអរ អបអរបុណ្យនេះបណ្តើរៗហើយ។

លោកបានបញ្ជាក់ថា "កាលនៅភ្នំពេញ ខ្ញុំឃើញ កន្លែងខ្លះចាប់ផ្តើមរៀបចំបណ្តើរៗហើយ ដល់ពេលមកដល់សៀមរាប គឺក៏ឃើញគេកំពុងតែរៀបចំដែរ"។

លោកបានបន្តទៀតថា អត្ថន័យបុណ្យនេះយ៉ាងម៉េចប្រហែលជាមិនសូវនៅក្នុងការរិះគិតរបស់អ្នកទាំងនោះទេ ប៉ុន្តែបុណ្យនេះ គឺនៅក្នុងកាលវិភាគប្រចាំឆ្នាំរបស់គេ។ លោកបន្តទៀតថា គេដឹងគេរៀសតែម្តងរឿងការរៀបចំត្រៀមខ្លួនសម្រាប់បុណ្យនេះ។

ថ្ងៃបុណ្យព្រះយេស៊ូប្រសូត ឬបុណ្យណូអែល ឬបុណ្យគ្រីស្តស្មាក់នេះ គឺមិនមែនជាថ្ងៃឈប់សម្រាក ផ្លូវការរបស់កម្ពុជានោះទេ ប៉ុន្តែមន្ត្រីរាជការ អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនមួយចំនួន គឺតែងតែ នាំគ្នាដាក់ច្បាប់ដើម្បីយកពេលនេះទៅសម្រាកលំហែ ជាមួយគ្រួសារ ឬមិត្តភក្តិជាហូរហែ។

មុន្នី តុលា បានឲ្យដឹងថា ថ្ងៃដែលលោកសំភាសន៍នេះ (ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៧) នៅខេត្តសៀមរាបនេះ លោកមានធុរៈការងារ ប៉ុន្តែចាប់ពីថ្ងៃទី២៥ ខែធ្នូ ដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ គឺលោកបានដាក់ច្បាប់ហើយដើម្បីនាំគ្រួសារដើរលេងកម្សាន្ត។

លោកបានបន្តថា ថ្ងៃនោះ (ថ្ងៃបុណ្យគ្រីស្តស្មាក់) មិនមែនជាថ្ងៃឈប់ទេ តែវាកៀកនឹងថ្ងៃឆ្លងឆ្នាំសាកល ក៏ឆ្លៀតពេលបង្កើតកម្មវិធីនាំគ្រួសារដើរលេងជួបជុំគ្នាកុំរវល់តែធ្វើការពេញមួយឆ្នាំនោះ។

លោកបានបន្តទៀតថា រាល់ឆ្នាំថ្ងៃនោះ គឺម្នាក់ៗមានកម្មវិធីរៀងៗខ្លួន ដោយខាងកូន គេមានកម្មវិធីពូកគេនៅសាលារៀនអង់គ្លេស គេជួបគ្នីគ្នាគេ ជប់លៀងតាមយុវភាពរបស់គេ ខាងភរិយា គេមាន កម្មវិធីរបស់គេដែរទៅ ហើយខាងលោកវិញ ក៏មានកម្មវិធីផ្ទាល់ខ្លួនដែរ ប៉ុន្តែឆ្នាំនេះ គ្រួសារលោក មានកម្មវិធីជួបជុំបង្កើតទំនាក់ទំនងគ្រួសារកក់ក្តៅបន្តិច ពីព្រោះវាខានជួបជុំគ្នាយូរហើយ ដោយម្នាក់ៗរវល់រៀងៗខ្លួន។

លោកស្រី គៀង ស៊ីណៃ ដែលជាម្ចាស់ហាងលក់អនុស្សាវរីយ៍មួយរូបនៅខេត្តសៀមរាប បានឲ្យដឹងថា នៅខេត្តសៀមរាបក៏មិនខុសពីនៅភ្នំពេញដែរ របស់របរដែលហាងលោកស្រីលក់ដាច់នោះគឺ គ្មានអ្វីក្រៅពីរបស់សម្រាប់គេយកទៅតុបតែងធ្វើដើមគ្រីស្តស្មាក់ កណ្តឹង ខោអាវ សន្តក្លូសរបស់អនុស្សាវរីយ៍ ស្ករសូកូឡា និងផ្កាផ្លាស្ទិក ឬផ្កាស្រស់ហ្នឹងឯង។

លោកស្រីបានបន្តថា សម្រាប់ហាងលោកស្រី បរទេសដូចជាមិនសូវមានទេ ភាគច្រើនគឺតែខ្មែរ ហើយបើមាន គឺភាគច្រើនមកទិញតែរបស់ញ៉ាំ ដូចជាសូកូឡា ផ្កាអីតែប៉ុណ្ណឹង។

លោកស្រីបានបញ្ជាក់ថា បរទេសប្រហែលជាគេអាចទិញនៅ ហាងម្តុំផាប់ស្ទ្រីត តែហាងខ្ញុំនៅក្បែរផ្សារ គឺភាគច្រើនលក់ដាច់តែខ្មែរហ្នឹង"។ *ដោយ អរិយបុត្រ*



ថតដោយ: រិទ្ធី

# រ៉ឺម៉កកង់ជាមធ្យោបាយដឹកជញ្ជូនដែលអាចនឹងសល់ត្រឹមតែជាអនុស្សាវរីយ៍



ថតដោយៈ ផានិត

យានដឹកជញ្ជូនមួយប្រភេទដែលកាល ពីអតីតកាល សម្បូរដោយបុរសដែលមាន រូបរាងស្វាហាប់កម្លាំងខ្លាំងក្លាជាក់ដឹកអតិថិជនរបស់ពួកគាត់ធ្វើដំណើរកាត់ក្រុង ភ្នំពេញសម្រាប់ការធ្វើផ្សេងៗ និងដឹករបស់ របរសម្រាប់ជីវភាពប្រចាំថ្ងៃកាលពីអតីតកាល មកដល់បច្ចុប្បន្នយានមួយនេះខ្សត់ មែនទែន ហើយកំពុងតែឈានទៅបាត់បង់ ជាស្ថាពរហើយ។

យាននេះ មានតួកង់ភ្ជាប់នឹងកន្ទុយ សន្តោងដែលអាចធ្វើដំណើរទៅមុខ ដោយ ប្រើកម្លាំងកាយជាក់។ វាអាចធ្វើដំណើរ បាន លឿនឬយឺត អាស្រ័យទៅនឹងកម្លាំង របស់អ្នកជាក់ ដូច្នេះហើយកាលពីអតីត កាលអ្នកដែលប្រកបរបរនេះ គឺភាគច្រើន មានកម្លាំងខ្លាំងក្លា ។រ៉ឺម៉កកង់ជានិមិត្តរូប នៃ សេវាដឹកជញ្ជូនមួយក្នុងទីក្រុងភ្នំពេញ ជាពិសេសតំបន់ច្បារអំពៅ ហើយប្រហែល ជាមិនយូរប៉ុន្មានទៀតទេ វិស័យដឹកជញ្ជូន សម័យទំនើប នឹងធ្វើអោយសេវារ៉ឺម៉កកង់ លែងមាន ហើយវានឹងក្លាយទៅជាសេវា ដឹកជញ្ជូនដែលមានតែនៅក្នុងប្រវត្តិសាស្ត្រ ប៉ុណ្ណោះ។

រហូតមកដល់បច្ចុប្បន្ននេះនៅតំបន់ផ្សារ ច្បារអំពៅ រាជធានីភ្នំពេញ អាចចាត់ទុកជា តំបន់ដែលនៅសេសសល់ នូវអ្នកដែល ប្រកបរបរ ជាក់រ៉ឺម៉ក់សណ្តោងនឹងកង់ខ្លះ ថ្វីត្បិតតែមិនច្រើននិងពិបាករកក៏ដោយ ដោយសារអ្នកប្រកបរបររ៉ឺម៉កកង់ កាន់តែ ហោចទៅៗ បានធ្វើឲ្យអ្នកដែលពឹងអាស្រ័យ នឹងអាជីព សល់តាំងពីសម័យសង្គមរាស្ត្រ និយមនេះ កំពុងបារម្ភពីការបន្តវិចរិល និង អាចឈានទៅបាត់បង់ទាំងស្រុងនូវ រ៉ឺម៉ក ប្រពៃណីនេះ ដោយការជំនួសមកវិញនូវ រ៉ឺម៉កម៉ូតូ និងយានយន្តសណ្តោងផ្សេង ទៅវិញ។

លោក ឃឹម សំអោ ជាអ្នករត់រ៉ឺម៉កកង់ នៅផ្សារច្បារអំពៅមួយរូប តាំងពីទសវត្ស ឆ្នាំ៨០មកនោះបានថ្លែងថា ដោយសារ រ៉ឺម៉កកង់វាយឺត និងដឹកបានជិតៗនោះ លោកថាវាបានធ្វើឲ្យ រ៉ឺម៉កកង់ កាន់តែ ខើចអតិថិជន ពីមួយថ្ងៃទៅមួយថ្ងៃ។ លោកបានថ្លែងបន្តថា "អ្នកដែលនៅ ជិះ រ៉ឺម៉កកង់របស់ខ្ញុំសព្វថ្ងៃ ភាគច្រើនជាអ្នក ដំណើរជិតផ្សារ និងដឹករបស់របរកំប៉ិក កំប៉ុក"។ លោកបានថា អ្នកជិះមួយចំនួន នៅបន្តគាំទ្រសេវាកម្មរបស់លោកដោយ ក្តីអាណិត ដើម្បីចែករំលែកដល់ពួកលោក ដែលពឹងលើការជាក់រ៉ឺម៉កនេះប៉ុណ្ណោះ។

លោក ឃឹម សំអាបានថ្លែងបន្តថា នៅ ផ្សារច្បារអំពៅសព្វថ្ងៃ នៅសេសសល់អ្នក ជាក់រ៉ឺម៉ក បែបនេះរង្វង់១០នាក់ដែរ ហើយ អ្នកជាក់មួយចំនួនដែលមានលទ្ធភាព លោកថាបានច្នៃសណ្តោងដោយម៉ូតូវិញ។ លោកបញ្ជាក់ថា ធ្វើដូចនេះអាចឲ្យអ្នកទាំង នោះ ធូរកម្លាំង ដឹកបានឆ្ងាយ បានចំនួន ច្រើន និងសុវត្ថិភាព។ រីឯអ្នកជាក់ខ្លះទៀត ដែលពុំមានលទ្ធភាពទិញម៉ូតូមកសណ្តោង ដូចលោកជាដើម លោកថាក៏បង្ខំចិត្តបន្ត ជាក់នឹងកង់ដើម្បីសន្សំចំណូល តឹកតក់ៗ ចិញ្ចឹមគ្រួសារ។

តាមឯកសារដែលគេបានចងក្រងអំពី រ៉ឺម៉កបានឲ្យដឹងថា កាលពីប៉ុន្មានទសវត្ស មុនមានរ៉ឺម៉កកង់ដល់ទៅ ៦០០ រត់ស្ទើរ តែពេញដងផ្លូវនៅទីក្រុងភ្នំពេញ តែមក ដល់ខែ តុលា ឆ្នាំ២០១៧ ចំនួនរ៉ឺម៉កកង់ មានតែ១០ ប៉ុណ្ណោះ ហើយចំនួននេះកំពុង តែបន្តថយចុះយ៉ាងលឿន។ បើមើលទៅ តាមដងផ្លូវក្នុងទីក្រុងភ្នំពេញអ្វីៗ ត្រូវបាន កើតឡើងពេញផ្លូវ តែផ្ទុយទៅវិញ ចំនួន រ៉ឺម៉កកង់បានថយចុះ ដែលមុនដំបូង ម៉ូតូ ឌុប បន្ទាប់មករ៉ឺម៉កកង់បី (រ៉ឺម៉កទេសចរណ៍) មកជំនួសរ៉ឺម៉កកង់។

មិនខុសពីអ្នកជាក់រ៉ឺម៉កកង់រូបនេះ ប៉ុន្មាន ឡើយ ប្រជាជនមួយចំនួននៅ ច្បារអំពៅ លើកឡើងថា រ៉ឺម៉កកង់ ដែលពួកគាត់ធ្លាប់ ឃើញច្រើនទសវត្សមកហើយ ងាយ នឹង រលត់ដង្ហើមណាស់នៅពេលខាងមុខ ដោយ សារភាពសម្បូរបែបនៃយានយន្ត ដែល អាចឲ្យគេទៅណាមកណា បានលឿន និង ងាយស្រួល មានសុវត្ថិភាព ជាងរ៉ឺម៉ក ប្រពៃណីប្រចាំរាជធានីភ្នំពេញនេះ។

លោក ឃឹម សំអា មានប្រសាសន៍ថា យូរ ឬឆាប់ រ៉ឺម៉កកង់ នឹងក្លាយជារបស់ដែល គ្រាន់តែជាការចងចាំ សម្រាប់អ្នកដែលធ្លាប់ មានអនុស្សាវរីយ៍នឹងវាតែប៉ុណ្ណោះ។

ជុំវិញសេវាកម្មនៃយានយន្តដឹកជញ្ជូន ដោយរ៉ឺម៉កកង់នេះ លោក ជុម រចនា ជា ប្រជាពលរដ្ឋមួយរូប ដែលធ្លាប់ឃើញ សេវាកម្មដឹកជញ្ជូននេះនៅមានជីវិត បាន ចូលរួមបញ្ចេញយោបល់ថា អាជ្ញាធរគួរតែ មានវិធានការណ៍ជួយ សង្គ្រោះ ឬមួយ អភិរក្សយាននេះផង។ លោកបានបន្តថា អាយុកាលវា នឹងស៊ីក្លូ គឺប្រហែលជាមិន ខុសគ្នាទេ ប៉ុន្តែស៊ីក្លូមានការអភិរក្ស ហើយ មានអ្នកយកចិត្តទុកដាក់ ប៉ុន្តែរ៉ឺម៉កដូច ជាសូន្យតែម្តង។ លោកបានបញ្ជាក់ថា "ល្អដែរ បើយើងអាចមានកម្មវិធីជួយពួក គេ ដើម្បីទុកឲ្យកូនចៅនៅទីក្រុងបានស្គាល់ មធ្យោបាយដឹកជញ្ជូនរបស់យើង" ។

លោកបានបន្តថា ជាការពិតរ៉ឺម៉កកង់ ពិតជាមិនអាចផ្តល់សេវាដឹកជញ្ជូនជូន ប្រជាពលរដ្ឋនៅក្នុងរាជធានីបានទេ ដោយ សារតែរាជធានីបច្ចុប្បន្ននេះមានស្ថាន អាកាសផ្លូវខ្វែងខ្វាត់ ហើយវាគឺយានមួយ ដែលអាចបង្កបញ្ហាចរាចរណ៍ ដោយសារ តែវាពពីមពពើម ប៉ុន្តែបើយើងអាចរក កន្លែង មួយដែលសុវត្ថិភាពរកផ្លូវណាមួយ ដែលពួក គាត់អាចជាក់បានស្រួល ដូចជានៅ ជុំវិញរមណីដ្ឋានណាមួយ នៅកន្លែង កម្សាន្តណាមួយ ឬបរិវេណសណ្ឋាគារ គ្រាន់អ្នកទេសចរណ៍សាកល្បងប្រហែលជា អាចជួយសង្គ្រោះអ្នកប្រកបរបររកស៊ីចិញ្ចឹម ជីវិតនេះបាន ហើយក៏អាចជួយអភិរក្ស យានដឹកជញ្ជូននេះបានផងដែរ ។

លោកបានបញ្ជាក់ថា "ខ្ញុំគិតថា វា (រ៉ឺម៉កកក់) បាត់ហើយ ដោយសារមិន ដែលឃើញសោះនៅទីក្រុង ប៉ុន្តែប៉ុន្មាន ថ្ងៃមុន ពេលខ្ញុំឆ្លងកាត់ចំណុចជិតផ្សារ ច្បារអំពៅ ឆ្ពោះទៅវត្តព្រែកប្រា ខ្ញុំបាន ប្រទះឃើញដោយចៃដន្យ"។

លោក សេក ឧត្តម ជាប្រជាពលរដ្ឋមួយ រូប បានថ្លែងថា លោកមិនដែលបានឃើញ ទេរ៉ឺម៉កកង់នាពេលបច្ចុប្បន្ននេះ ប៉ុន្តែ លោកធ្លាប់ឃើញកាលពីសម័យទស្សវត្សរ៍ នៃឆ្នាំ១៩៨០មក ដោយឃើញច្រើននៅ ម្តុំផ្សារច្បារអំពៅ ចំណុច ឆ្លងស្ពានព្រះ មុនីវង្ស។ លោកបានបន្តថា ទាន់រ៉ឺម៉កកង់ នៅមានសេសសល់បែបនេះ យើងគួរតែ អភិរក្សវាទុក ពីព្រោះកម្រណាស់។ ឆ្លៀត ឱកាសនោះលោកក៏បានចែករំលែកបទពិសោធន៍កាលពីលោកនៅវ័យកុមារថា លោកឧស្សាហ៍ធ្វើដំណើរលេងតាមរ៉ឺម៉ក កង់នេះណាស់កាលពីវ័យខ្ទង់ ១០ ឆ្នាំ ។ លោកបានបន្តថា កាលនោះនៅផ្សាយអ្ញូឬស្សីសព្វថ្ងៃនេះ គឺសំបូរណាស់ ហើយ លោកច្រើនជិះនៅម្តុំនោះ ពេលដឹក ទំនិញចេញពីផ្សារទៅលក់ ដូរនៅផ្ទះ។

លោក ឧត្តម បានឯកភាពនឹងគំនិត អភិរក្សវា ប៉ុន្តែលោកមិនឯកភាពឲ្យរ៉ឺម៉ក កង់ជាក់នៅលើដងផ្លូវទៀតទេ។ យាន មួយនេះអាចរត់បាននៅតាមរមណីដ្ឋាន និង ជុំវិញកន្លែងណាមួយ ប៉ុន្តែមិនអាច នៅលើទ្រូងផ្លូវច្រើនបានទេ ដោយសារ តែវាវែង ហើយជាក់ដោយកម្លាំងកាយថែម ទៀត ដូច្នេះបើយើងលើកទឹកចិត្តហើយ ជំរុញឲ្យមានធ្វើដំណើរតាមផ្លូវច្រើននោះ ចរាចរណ៍នៅក្នុងទីក្រុងនឹងមានបញ្ហា ។

*ដោយ សុផានិត*

# ស្វាត់។កោះមួយទៀតនៅដែនសមុទ្រកម្ពុជាកំពុងតែទទួលគម្រោងអភិវឌ្ឍន៍



រូបថតពីវិបសាយរបស់ក្រសួងបរិស្ថាន

កោះមួយដែលមានឈ្មោះថា កោះ ប្រឹស ឬកោះចន្លុះ ត្រូវបានក្រសួងបរិស្ថានបង្ហើបថា កំពុងតែ មានគម្រោងអភិវឌ្ឍន៍ ប៉ុន្តែប្រភពដដែលមិនបានបញ្ជាក់ថា កោះនោះមានគម្រោងវិនិយោគអ្វីឲ្យពិតប្រាកដនៅឡើយទេ ។

ក្រសួងបរិស្ថានគ្រាន់តែបានឲ្យដឹងថា ក្រុមការងារបច្ចេកទេសកំពុងតែវាយតម្លៃហេតុផល ប៉ះពាល់បរិស្ថានគម្រោងអភិវឌ្ឍន៍កោះប្រឹសនេះ ។

ប្រភពដដែលបានបន្តថា កិច្ចប្រជុំនេះ គឺជាកិច្ចប្រជុំអន្តរក្រសួងស្តីពីការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ សម្រាប់គម្រោងអភិវឌ្ឍន៍កោះប្រឹស (ហៅកោះចន្លុះ)របស់ក្រុមហ៊ុន អេនដេឡា រៀល អ៊ីស្ទេតនៅលើផ្ទៃដីទំហំ ៥៦,២២ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ប្រភពដដែលបានបន្តថា កិច្ចប្រជុំនេះ ដឹកនាំលោកស្រី មាស ម៉ូរិន អនុរដ្ឋលេខាធិការនៃក្រសួងបរិស្ថាន និងជាប្រធានក្រុមការងារបច្ចេកទេសសម្របសម្រួលការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយមានការចូលរួមពីតំណាងមកពីអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងបរិស្ថានដែលជាសមាជិកក្រុមការងារតំណាងមកពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មន្ទីរបរិស្ថានខេត្តព្រះសីហនុ រដ្ឋបាលខេត្តព្រះសីហនុ និងនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន ដែលជាលេខាធិការដ្ឋាននៃក្រុមការងារ តំណាងក្រុមហ៊ុនម្ចាស់គម្រោង និងក្រុមហ៊ុនទីប្រឹក្សា។




រូបភាពពី Google Earth

កិច្ចប្រជុំនេះ ផ្តោតសំខាន់លើការពិនិត្យ និងពិភាក្សាលើចំណុចសំខាន់ៗមួយចំនួន ដូចជា ការរៀបចំផែនការមេ, ការគ្រប់គ្រងសំណល់រឹង-រាវ, ការប្រើប្រាស់ទឹកជាពិសេសទឹកក្រោមដី, ហានិភ័យ និងសុវត្ថិភាពបុគ្គលិក-កម្មករ, ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ,ផែនការគ្រប់គ្រងបរិស្ថាន, ការអភិរក្សធនធានជីវសាស្ត្រ និងវប្បធម៌នៅក្នុងតំបន់គម្រោង, និង ការបង់ពន្ធលើការជួលទីតាំងគម្រោង។

ប្រភពដដែលបានបន្តថា នៅក្នុងកិច្ចប្រជុំនោះ ក្រុមហ៊ុនការងារ បានស្នើឱ្យក្រុមហ៊ុនម្ចាស់គម្រោងសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដើម្បីកែសម្រួលឡើងវិញនូវចំណុចខ្វះខាតទាំងអស់ដលែសមាជិកក្រុមការងារ បានផ្តល់ជាមតិយោបល់នៅក្នុងកិច្ចប្រជុំនេះ។

កោះប្រឹស ត្រូវបានគេដឹងថា គឺជាកោះតូច មួយដែលមានចម្ងាយប្រមាណជា ៣គីឡូម៉ែត្រពីឆ្នេរអូត្រេះ ហើយ ប្រហែលជា ៦ គីឡូម៉ែត្រ ពីក្រុងព្រះសីហនុ។

រហូតមកដល់ពេលនេះ កម្ពុជាត្រូវបានគេដឹងថាមានកោះទាំងតូចទាំងធំជាងច្រើនកន្លែង ដែលកោះ ទាំងនេះ ខ្លះនៅក្នុងការគ្រប់គ្រងនៅក្នុងរដ្ឋបាលនៃខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកែប និងកំពត ។

នៅក្នុងចំណោមកោះទាំងនោះ មានកោះធំៗជាច្រើននៅក្នុងតំបន់ដែនរដ្ឋបាលនៃខេត្តព្រះសីហនុ និងកែប ត្រូវបានរាជរដ្ឋាភិបាលប្រគល់សិទ្ធិវិនិយោគទៅឲ្យក្រុមហ៊ុនឯកជនអភិវឌ្ឍន៍ ហើយកោះមួយចំនួន ក៏មានប្រជាពលរដ្ឋទៅវិនិយោគនៅក្នុងលក្ខណៈតូចតាច ដូចជា នាំភ្ញៀវទេសចរ ការផ្តល់សេវាកំសាន្តស្នាក់នៅជាដើម ។

ដោយសារតែភាពស្រស់ស្អាតនៃសក្តានុពលនៅកោះទាំងនោះ មានកោះចំនួន៧ ដែលត្រូវបាន គេល្បីថា ជាគោលដៅទេសចរណ៍ដ៏ល្អនៅក្នុងក្រសែភ្នែកភ្ញៀវទេសចរ។

កោះទាំងនោះ មានដូចជា កោះរ៉ុង កោះរ៉ុងសន្លឹម កោះសង្ឃ កោះថ្មី កោះតាគៀវ កោះតាង និងកោះតូតាង ។

កោះទាំងនោះ ត្រូវបានគេដឹងថា ត្រូវបានអភិវឌ្ឍន៍ដោយប្រជាពលរដ្ឋ និងអ្នកវិនិយោគ បោះបីជា កោះខ្លះទទួលគម្រោងវិនិយោគធំ ប៉ុន្តែសកម្មភាពដូចជាមិនសូវមមាញឹក តែភ្ញៀវទេសចរជាតិ និងអន្តរជាតិនិយមទៅ ដោយសារតែទីនោះ មានអាហារសមុទ្រស្រស់ៗ មានខ្យល់អាកាសបរិសុទ្ធ មានសេវាកម្មទេសចរណ៍ល្អៗ មានឆ្នេរសមុទ្រស្អាត ប៉ុន្តែផលប៉ះពាល់បរិស្ថានជាពិសេស គឺទឹកសំអុយ សំណល់ពីសេវាកម្មទេសចរណ៍ ផលប៉ះពាល់ដល់អេកូឡូស៊ីធម្មជាតិ ក៏កំពុងតែ ជាចំណុចដ៏រសើបមួយសម្រាប់កោះ ទាំងនោះផងដែរ។

ដោយ អរិយបុត្រ

# វាចារបស់និស្សិតបច្ចុប្បន្ន៖ សូមកុំមើលរំលងការងារស្ម័គ្រចិត្ត

ការងារស្ម័គ្រចិត្តក៏ជាការងារមួយ ដែលអាចជួយជំរុញ នូវឱកាសនៃភាពជោគជ័យនៅក្នុងសង្គមការងារសម្រាប់ជីវិតមនុស្សនាពេលសព្វថ្ងៃ ខណៈដែល បុគ្គលល្បីៗជាច្រើនដែលទទួលបាននូវភាពជោគជ័យច្រើនផ្តើមចេញពីការងារស្ម័គ្រចិត្តនេះ។

អ្នកជំនាញនិងអ្នកទទួលជោគជ័យជាច្រើនធ្លាប់បានអះអាងថា ការងារស្ម័គ្រក៏ជាចលករមួយដែលអាចជួយជំរុញ នូវភាពជោគជ័យសម្រាប់ការងារពិតប្រាកដ ដោយសារ វាបង្កឲ្យយុវជននិងយុវនារីម្នាក់ៗ អាចទទួលបាននូវបទពិសោធ ចំណេះដឹងបន្ថែមលើសីលធម៌ក្នុងការរស់នៅប្រចាំថ្ងៃ ថែម បែបបទការងារ និងខ្សែសង្វាក់និងបរិយាកាស ភាពបទបែននៅក្នុងកន្លែងធ្វើការ។ ពួកគេបានអះអាងថា ជាមួយនឹងការងារស្ម័គ្រចិត្តបើទោះបីជាវា មិនបានផ្តល់នូវផលកម្រៃសម្រាប់ជីវិត តែវាបានផ្តល់នៅការអប់រំ បទពិសោធជីវិត និងប្រែក្លាយខ្លួនមនុស្សទៅកាន់ការងារពិតប្រាកដមួយ នាពេលអនាគត។ ការងារស្ម័គ្រចិត្ត គឺជាស្ពានចម្លងដែលអាចជួយឱ្យយុវនិស្សិតនានា អាចទទួលបាននូវឱកាសទទួលបានការងារដែលអាចរកប្រាក់ចំណូល សម្រាប់ផ្គត់ផ្គង់ការសិក្សា។ ការងារស្ម័គ្រចិត្ត ជាការងារក្រៅម៉ោងសិក្សា ជាឱកាសដ៏ល្អ សម្រាប់និស្សិតស្វែងយល់ និងសន្សំនូវបទពិសោធន៍ បង្កើតនូវទំនាក់ទំនងល្អ ជាមួយស្ថាប័នខាងក្រៅ បង្កនូវភាពងាយស្រួលក្នុងឱកាសរកការងារធ្វើនៅពេលដែលបញ្ចប់ការសិក្សា។

កញ្ញា ឡាយ ឌីនណា ជាយុវតីម្នាក់ក្នុងចំណោមយុវជនច្រើននាក់ទៀត ដែលមានទីលំនៅក្នុងខេត្តកំពង់ធំ ហើយដែលបានមកបន្តការសិក្សានៅរាជធានីភ្នំពេញ។ គឺជាយុវតីមួយរូប ដែលមានឱកាសអាចបានក្លាយខ្លួនជាមន្ត្រីបណ្តុះបណ្តាលរបស់អង្គការក្តីករុណាមួយរូបនាពេលបច្ចុប្បន្ន ដោយសារតែការស្ម័គ្រចិត្តនេះឯង។

ឌីនណា ជាកូនទីពីរក្នុងចំណោមបងប្អូនបីនាក់ក្នុងគ្រួសារ ដែលម្តាយឪពុកជាគ្រូបង្រៀនហើយ បានចាប់ផ្តើមការងារដំបូងជាអ្នកធ្វើការងារស្ម័គ្រចិត្តជួយកិច្ចការសង្គមតាមរយៈអង្គការសង្គមស៊ីវិលក្នុងស្រុកចាប់តាំងពីចុងឆ្នាំ២០១២ ទន្ទឹមនឹងការសិក្សាឆ្នាំទី៣ នៅសាកលវិទ្យាល័យ។

អ្នកខេត្តកំពង់ធំ មានអាយុ ២៥ឆ្នាំរូបនេះ បានចំណាយពេលវេលាធ្វើការងារស្ម័គ្រចិត្តជាមួយនឹងអង្គការសង្គមស៊ីវិលផ្សេងៗយ៉ាងច្រើន ដោយផ្តោតទៅលើបញ្ហាសុខភាពយុវជន ការផ្សះផ្សារផ្លូវចិត្តជនរងគ្រោះក្នុងសម័យខ្មែរក្រហម ការកសាងសន្តិភាពសង្គម និងបញ្ហាលើកកម្ពស់សិទ្ធិស្ត្រីជាដើម ។

កញ្ញាបានបញ្ជាក់ថា "ការងារដែលខ្ញុំធ្វើភាគច្រើន គឺចុះទៅតាមបណ្តាខេត្តផ្សេងៗជួបប្រជាពលរដ្ឋនៅក្នុងសហគមន៍"។

កញ្ញាបានឲ្យដឹងថា ទោះការងារទាំងនោះជួបបញ្ហាលំបាកយ៉ាងណាក៏ដោយ ក៏នាងព្យាយាមធ្វើកិច្ចការធ្វើមិនរាថយឡើយ។ តាមរយៈបទពិសោធន៍ធ្វើការងារស្ម័គ្រចិត្តនេះ បានធ្វើឲ្យកញ្ញាសម្រេចគោលបំណងការងារ និងមានជំហររឹងមាំក្នុងជីវិត ខណៈមានការគាំទ្រលើកទឹកចិត្តពីសមាជិកក្រុមគ្រួសារ និងមិត្តភក្តិរួមការងារ។

កញ្ញា ឡាយ ឌីនណា បានចែករំលែកដោយបញ្ជាក់ថា "ខ្ញុំចង់ឲ្យម្តាយឪពុកអាណាព្យាបាលយុវជនផ្សេងៗទៀតលើកទឹកចិត្តឲ្យកូនស្រីបន្តការសិក្សាឲ្យបានខ្ពស់ និងមានសិទ្ធិក្នុងការសម្រេចចិត្តក្នុងការ-ងារផ្សេងៗ ហើយស្ត្រីខ្លួនឯងក៏ត្រូវបើកឱកាស បើកចិត្តទទួលធ្វើកិច្ចការអ្វីដែលខ្លួនកំពុងធ្វើ"។

ដោយឡែក កញ្ញា ណយ ស៊ីណាត និស្សិតឆ្នាំទី២ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកអក្សរសាស្ត្រខ្មែរ ដែលមានស្រុកកំណើតនៅឯភូមិផ្សារស្លាបលែង ឃុំស្វាយអំពារ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ដែលបានធ្វើការងារក្រៅម៉ោងសិក្សាតាំងពីសិក្សានៅឆ្នាំទី១មកនោះ បាននិយាយថា ការងារក្រៅម៉ោងសិក្សានេះ ពិតជាមានសារៈប្រយោជន៍ណាស់សម្រាប់និស្សិត ពិសេសកូនកសិករមកពីតាមបណ្តារខេត្ត ដូចជារូបនាង។

កញ្ញាបានបន្តថា នាងបានមកសិក្សានៅភ្នំពេញ បន្ទាប់ពីប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយបានសម្រេចចិត្តចូលរួមក្នុងការងារស្ម័គ្រចិត្ត និងបានប្រឡូកការងារក្រៅម៉ោងសិក្សា បន្ទាប់ពីសិក្សានៅសាកលវិទ្យាល័យ។ នាង បានឱ្យដឹងថា "ការងារដំបូងគឺ ខ្ញុំធ្វើជាអ្នកស្ម័គ្រចិត្តឱ្យអង្គការបណ្តាញកសិផលធម្មជាតិ រួចក៏ចូលធ្វើជាបុគ្គលិកក្រៅម៉ោង នៅក្នុងភោជនីយដ្ឋានមួយ ទទួលបានប្រាក់កម្រៃសមរម្យ គឺបានជំរុញឱ្យការសិក្សារបស់ខ្លួនកាន់តែមានភាពរីកចម្រើន ហើយបានជួយរកប្រាក់ចំណូលសម្រាប់ទ្រទ្រង់ ដល់ការចំណាយទៅលើការស្នាក់នៅ និងការហូបចុក ព្រមទាំងការសិក្សា ដោយពុំចាំបាច់ពឹងលើការឧបត្ថម្ភពីសំណាក់ឪពុកម្តាយដូចមុនទៀតឡើយ។ ការងារក្រៅម៉ោងរបស់នាង ថែមទាំងជួយទំនុកបម្រុងប្អូនប្រុសម្នាក់ ដែលកំពុងរៀននៅមហាវិទ្យាល័យ ក៏ដូចជួយសម្រាលបន្ទុកលោកអ្នកមានគុណ បានមួយកម្រិតទៀតផង។

ទាក់ទងជាមួយនិងរឿងនេះដែរ បើតាមអ្នកជំនាញផ្នែកនេះ លោកបណ្ឌិត កង ច័ន្ទតារារ័ត្ន សាកលវិទ្យាការរងនៃសាកលវិទ្យាល័យពុទ្ធិសាស្ត្រ បានមានប្រសាសន៍ថា ការងារក្រៅម៉ោងសិក្សា គឺមានប្រយោជន៍ច្រើនសម្រាប់និស្សិតដែលកំពុងសិក្សា ពិសេសចំពោះការងារដែលត្រូវនឹងមុខវិជ្ជាដែលខ្លួនកំពុងសិក្សា។ លោកបានបន្តថា ការងារស្ម័គ្រចិត្តគឺអាចផ្តល់នូវប្រាក់ចំណូល សម្រាប់ផ្គត់ផ្គង់ទៅលើការសិក្សា និងផ្តល់នូវបទពិសោធន៍យ៉ាងប្រសើរ ចំពោះមុខជំនាញរបស់ខ្លួនតាមរយៈការអនុវត្ត គួបផ្សំរវាងការងារទៅនឹងទ្រឹស្តីដែលរៀននៅសាលាថែមទៀតផង។

លោកបណ្ឌិត ក៏បានមានប្រសាសន៍ផងដែរថា ការងារក្រៅម៉ោងនេះ ក៏បានផ្តល់នូវគុណវិបត្តិតិចតួចដែរ ខណៈ ដែលយើងមិនបានបែងចែកនូវពេលវេលា ឱ្យបានត្រឹមត្រូវ។ តែទោះជាយ៉ាងណា ការងារស្ម័គ្រចិត្ត ការងារក្រៅម៉ោងសិក្សានេះ ពិតជាបានផ្តល់នូវគុណប្រយោជន៍ច្រើនសម្រាប់និស្សិត ដែលផ្តល់ឱ្យទាំងចំណេះដឹង និងចំណេះធ្វើ ព្រមទាំងបានផ្តល់នូវប្រាក់ចំណូលសម្រាប់ការសិក្សា ថែមទៀតផង។

លោកបានបញ្ជាក់ថា "បើការងារក្រៅម៉ោងសិក្សានោះ ត្រូវហ្នឹងមុខវិជ្ជាដែលយើងកំពុងតែសិក្សាទៀតនោះវាកាន់តែប្រសើរ ព្រោះវាមិនត្រឹមតែអាចរកចំណូលបានតែប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវបទពិសោធន៍ចំពោះការអនុវត្តន៍ផ្ទាល់ថែមទៀតផង។ តែបើការងារមិនត្រូវហ្នឹងជំនាញវិញនោះ វាអាចបានផ្តល់ឱ្យនូវប្រាក់សម្រាប់ចំណាយទៅលើការបង់ថ្លៃសាលា ហូបចុក ប្រចាំថ្ងៃ ដោយមិនបាច់ពឹងលើការឧបត្ថម្ភ របស់ឪពុកម្តាយ ដូចពីពេលមុនទៀតទេ។

*ដោយ ផល សុផានិត*



*ថតដោយ: សហការី ស៊ីអេសស៊ី*

# កម្មករនិងកម្មការិនីនៅតែមន្ទិលនឹងកញ្ចប់សេវាសុខភាពពីរដ្ឋាភិបាលដោយមិនគិតថ្លៃនាឆ្នាំក្រោយនេះ

បងប្អូនកម្មករនិងកម្មការនីមួយចំនួនបានទទួលសាររួចហើយអំពីការធានាពីសំណាក់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាចំពោះការផ្តល់ជូននូវកញ្ចប់សេវាសុខភាពពីរដ្ឋដោយមិនគិតថ្លៃ ហើយមួយចំនួនតូចនៅតែមិនទាន់ទទួលបាននូវសារនេះនៅឡើយទេ ប៉ុន្តែទាំងអ្នកទទួលបាននូវសារនេះ និងអ្នកដែលមិនទាន់ទទួលបានគឺនៅតែមានមន្ទិលនឹងការសន្យានេះនៅឡើយ។

កម្មការនីរោងចក្រកាត់ដេរអាយុ ៣៦ ឆ្នាំមួយរូបដែលនិយាយនៅក្នុងលក្ខខណ្ឌមិនបញ្ចេញអត្តសញ្ញាណ បានឲ្យដឹងថាវាគឺជារឿងល្អមែនទែនប្រសិនបើរាជរដ្ឋាភិបាល ជាពិសេសគឺសម្តេចតេជោ ហ៊ុន សែន លោកពិតជាផ្តល់កញ្ចប់សេវាសុខភាពដោយមិនគិតថ្លៃដល់ពួកគាត់ជាកម្មករដែលមានជីវភាពកំពុងតែខ្វះខាត។ លោកស្រីបានបញ្ជាក់ថា "សុខភាពហ្នឹងសំខាន់ណាស់! បើសម្តេចគាត់អាចផ្តល់ឲ្យយើងបានគឺល្អមែនទែន ពីព្រោះយើងហត់ណាស់ ប្រាក់ខែបន្តិចបន្តួច ស៊ីចុកក៏វារឹតត្បិត កន្លែងស្នាក់នៅក៏វាមានបរិយាកាសមិនល្អ ហើយម្នាក់ៗឧស្សាហ៍ឈឺណាស់ គ្រាន់តែម្នាក់ៗមិនហ៊ានទៅពេទ្យ"។

លោកស្រីបានបន្តថា កម្មករយើងឥឡូវនេះ គ្មាននរណាចង់ទៅពេទ្យ ចង់ទៅពិនិត្យសុខភាពស្អីគេទេ ដោយសារតែវាគ្មានលុយ។ ម្នាក់ៗទោះមានជំងឺនេះ មានជំងឺនោះ ប៉ុន្តែបើសួរទៅពេទ្យគឺគ្មានទេ ទាល់តែសន្លប់ ឬដួលភីង គេសែងទៅពេទ្យបានទៅ បើឲ្យទៅខ្លួនឯង គឺមិនងាយទេ ដោយសារតែម្នាក់ៗខ្លាចពេទ្យ ខ្លាចអស់លុយ ។

លោកស្រីបានបញ្ជាក់ថា "ដូចជាខ្ញុំអីចឹងតាំងពីកើតមកទល់ប៉ុណ្ណេះមិនដែលបានទៅមន្ទីរពេទ្យស្អីទេ។ ពេលក្តៅពេលរងារ វិលមុខ ស្រៀវស្រាញអី គឺបានតែទៅជួបពេទ្យតាមរោងចក្រ ឬទៅឲ្យគេផ្សំថ្នាំមក ផឹកម្តង ៤.០០០ ទៅ ៥.០០០រៀល ប៉ុណ្ណឹង តែមិនដែលបានពិនិត្យឈាម ពិនិត្យស្អីដុំកំភួននឹងគេទេ"។

តាមការរៀបរាប់របស់ស្ត្រីកម្មការិនីរូបនេះ ស្ត្រីជាកម្មការិនីនានា ប្រហែលជាមានស្ថានភាពមិនខុសពីលោកស្រីឡើយ ដោយម្នាក់ៗអាចមានបញ្ហាផ្លូវដង្ហើម ជំងឺរោគស្ត្រី កង្វះអាហារូបត្ថម្ភ ឈឺចង្កេះ ឈឺធ្មេង ... ដោយសារតែ ពួកគេអង្គុយ និងធ្វើការនៅក្នុងបរិយាកាសការងារដែលពោរពេញទៅដោយគីមី និងកំទេចកំទីក្រណាត់ ...។

យុវតីមួយរូប ដែលអះអាង ត្រឹមឈ្មោះថា សុផា ជាកម្មការិនីរោងចក្រកាត់ដេរ នៅម្តុំព្រែកអញ្ចាញបានអះអាងពេលរៀបឡើងជិះឡានត្រឡប់ទៅផ្ទះសម្រាក ក្រោយពេលបំពេញការងារចប់បានថ្លែងថា កញ្ញាក៏នៅមិនទាន់បាន ទទួលព័ត៌មាន ឬក៏សារអ្វីពីនាយករដ្ឋមន្ត្រីនៅឡើយដែរ។ កញ្ញាបានរៀបរាប់ថា មនុស្សម្នាក់ៗបើទៅពិនិត្យវាមិនអត់ទេ រឿងជំងឺនោះ បើម្នាក់ៗនៅតែជាមួយនឹងកន្លែងដែលមិនសូវស្អាត ស៊ីរ៉េះស៊ីថាំ រាល់តែថ្ងៃបែបនេះ ប៉ុន្តែវាគ្មានលុយទៅពិនិត្យ។ កញ្ញា បានបញ្ជាក់ថា "ពេលក្តៅរងារ គ្រុនស្អី មិនដែលទៅពេទ្យទេ ទិញតែថ្នាំលេបខ្លួនឯង។ ហ៊ានតែចូលពេទ្យគេទារមើលឈាម ថតនេះថតនោះ អស់លុយងងឹតមុខឈឹងឥឡូវហើយ"។

សុផា បានបន្តថា រឿងចូលពេទ្យគឺរាងតែម្តង។ កញ្ញា បានបន្ថែមថា ពេលចូលពេទ្យគឺគេគ្មានគិតថា យើងអ្នកក្រីក្រ យើងជាកម្មករជាអ្នកស្រែ អ្នកចំការស្អីនោះទេ គឺដឹងតែពីលុយតែម្តង ដូច្នេះហើយបានជាកញ្ញារាងតែម្តងរឿងចូលពេទ្យ។ សុផាបានរៀបរាប់ទៀតថា កាលពីប្អូនកញ្ញាគ្រោះថ្នាក់ចរាចរណ៍ ៤ ទៅ៥ ខែមុន គ្រាន់តែចូលពេទ្យ គឺអស់លុយជិត ២.០០០ ដុល្លារ។

កញ្ញាបានបញ្ជាក់ថា "ស្អីក៏លុយដែរនៅមន្ទីរពេទ្យ! តាំងពិនិត្យឈាម ថតនេះថតនោះ... ចឹងបានខ្ញុំរាងតែម្តងរឿងចូលពេទ្យនេះ"។ កញ្ញាបានបន្តទៀតថា មកដល់ឥឡូវនេះកញ្ញា និងគ្រួសារនៅមិនទាន់បានសងបំណុលគេអស់នៅឡើយទេ ដោយសារតែរឿងចូលពេទ្យនេះ ។

សុផា បានអះអាងថា នាងបានទទួលព័ត៌មានថា សម្តេចបានជួបជាមួយនឹងកម្មករនិងកម្មការិនីជាច្រើនរួចមកហើយ តែកញ្ញានៅមិនទាន់បានជួបនឹងគេទេ ហើយសង្ឃឹមថា ថ្ងៃណាមួយនឹងបានជួបសម្តេច បានស្តាប់ បានទទួល នូវពត៌មានដែលមានប្រយោជន៍។

កញ្ញា សៀងឡេង ដែលជាកម្មការិនីរោងចក្រនៅសូនឧស្សាហកម្មកាណាឌីយ៉ា នៅម្តុំផ្លូវវែងស្រេង ដែលបានទទួលសារនេះរួចហើយ នៅមានមន្ទិលច្រើនរឿងការទទួលបាននូវកញ្ចប់សេវាសុខភាពដែលសម្តេចបានប្រកាស។ កញ្ញា បាន តាមរយៈជំនួបនៅសួនកាណាឌីយ៉ា កាលពីប៉ុន្មានថ្ងៃមុននេះ សម្តេចក៏បានសន្យាឲ្យយើងជាកម្មការិនីនូវប្រាក់ខែ ១២០ ភាគរយ នៅពេលយើងឆ្លងទន្លេ ហើយសម្រាកបីខែ ព្រមទាំងបាន សន្យាផ្តល់ប្រាក់ដល់អ្នកណា ដែលឆ្លងទន្លេម្នាក់ដូចជា ៤០០.០០០រៀល សម្រាប់អ្នកកូនមួយ បើភ្លោះគឺអាចទទួលបាន ៨០០.០០០ រៀល ហើយបើភ្លោះបី ក្រៅពីទទួលបានប្រាក់ផ្សេងៗដែលសម្តេចធ្លាប់បានប្រកាសពីមុនមកនោះ គឺថែមទាំងទទួលបានការឧបត្ថម្ភបន្ថែមទៀត ប្រមាណជា ១.២០០.០០០ រៀលថែមទៀត។ ក្រៅពីនេះ ប្រសិនបើយើងមានបញ្ហាសុខភាពអី គឺយើងអាចទៅពេទ្យព្យាបាលបាន ហើយពេទ្យមិនអស់ថ្លៃព្យាបាលអ្វីនោះទេ ប៉ុន្តែកញ្ញា បានរៀបរាប់ថា មិនដឹងថា យ៉ាងម៉េចទេ ការសន្យានេះ ។

កញ្ញា បានបន្តថា កញ្ញាមិនដែលបានចូលមន្ទីរពេទ្យទេ តាំងតែពីបានក្លាយជាកម្មការិនីរោងចក្រប្រហែលជាជិត ២ឆ្នាំមកនេះ ប៉ុន្តែធ្លាប់ឮគេនិយាយថា អ្នកខ្លះដែលឈឺ ហើយទៅពេទ្យ គឺពេទ្យខ្លះដូចជាមិនសូវយកចិត្តទុកដាក់ទេ ជាពិសេសអ្នកជំងឺជាកម្មករដូចជាកញ្ញា ដែលទៅស្វែងរកសេវាសុខភាព ជាមួយនឹងប័ណ្ណ ប.ស.ស. (ប័ណ្ណបេឡាជាតិរបបសន្តិសុខសង្គម)។ កញ្ញាបានបញ្ជាក់ថា "ខ្ញុំមិនដែលឈឺ នៅមិនទាន់ដឹងយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំឮថា អ្នកដែលកាន់ប័ណ្ណ ប.ស.ស. នេះទៅ គេឮថា ពេទ្យមិនចង់មើលមុខ ហើយពិនិត្យរាងចុងដៃចុងជើង និយាយស្តីចុងមាត់ចុងក ពោលគឺពិនិត្យឲ្យតែបានៗ" ។

នេះគឺជាការយល់ឃើញរបស់បងប្អូនកម្មការិនីមួយចំនួន ប៉ុន្តែកន្លងមកនៅពេលដែលជួបជាមួយនឹងបងប្អូនកម្មករ និងកម្មការិនីរោងចក្រនៅរៀងរាល់សប្តាហ៍ សម្តេចតែងតែបញ្ជ្រាប រឿងព្រួយបារម្ភទាំងនេះ ព្រមទាំងសម្រួលជូនកម្មករនិងកម្មការិនីដោយប្រកាសថាការផ្តល់របបគាំពារសន្តិសុខសង្គម ដែលកម្មករស្គាល់ថា ប.ស.ស. នេះ គឺកម្មករ និងកម្មការិនីលែងបង់ដោយខ្លួនឯងហើយ។ សម្តេចបានប្រកាសថា គឺចាប់ពីខែមករា ឆ្នាំ២០១៨ នេះ គឺម្ចាស់ក្រុមហ៊ុនរោងចក្រជាអ្នកបង់ថ្លៃរបបសន្តិសុខសង្គម ១០០% ដល់កម្មករនិងកម្មការិនី ដូច្នេះពួកគេអាចនៅសល់ប្រាក់ ប្រមាណពី ៨,០០០៛-១២,០០០៛ ក្នុង១ខែ។ ជាមួយគ្នានេះដែរ កម្មករនិងកម្មការិនីទាំងអស់ (រួមទាំងកម្មករសំណង់ សណ្ឋាគារ ដឹកជញ្ជូនបើកបរ កសិកម្ម...) គឺទទួលបានការពិនិត្យព្យាបាលជំងឺ នៅមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃតាមរយៈមូលនិធិសមធម៌។ សម្តេចតេជោ ហ៊ុន សែន ក៏បានណែនាំអោយក្រុមហ៊ុន រៀបចំបង្កើតនិងពង្រឹងគ្លីនិក នៅតាមរោងចក្ររបស់ខ្លួនបន្ថែមទៀតដើម្បីជួយដល់កម្មករ។

*ដោយ អរិយបុត្រ*



*ថតដោយ: សហការី ស៊ីអេសស៊ី*

# លំនៅស្ថាន ឬផ្ទះបុរាណខ្មែរអាចនឹងបាត់បង់ប្រសិនបើគ្មានការអភិរក្ស



ថតដោយៈ ផានិត

សំណង់នៅកម្ពុជារីកព្រោងព្រាត ខណៈពលរដ្ឋកំពុងតែសម្រុកប្តូរផ្ទះស្លាបត្យកម្មចាស់ស្រវេស្រវារកស្លាបត្យកម្មថ្មី ដើម្បីឲ្យទាន់សម័យ ដែលនាំឲ្យបាត់បង់អត្តសញ្ញាណវប្បធម៌ខ្មែរ ដូច្នេះដើម្បីឲ្យ សាធារណជនមានចំណេះដឹងត្រួសៗអំពីប្រវត្តិ និងគុណតម្លៃនៃផ្ទះបុរាណ អ្នកនាំសារសូមណែនាំមិត្តអ្នកអាន ឲ្យជួបជាមួយនឹងលោក សាស្ត្រាចារ្យ **ជុំ សេរីវង្សា** ជាសាស្ត្រាចារ្យផ្នែកនគរូបនីយកម្ម និងសំណង់បុរាណមួយរូប។

**អ្នកនាំសារ៖** តើលំនៅស្ថាន ឬផ្ទះខ្មែរបុរាណ មានការប្រែប្រួលឬទេ ទៅតាមតំបន់ ឬទីតាំងនៃការសាងសង់របស់ពលរដ្ឋខ្មែរសម័យនេះ?

**សាស្ត្រាចារ្យ ជុំ សេរីវង្សា៖** ជាការពិតណាស់ លំនៅស្ថានមានការប្រែប្រួលលក្ខណៈទ្រង់ទ្រាយផ្សេងៗគ្នាទៅតាមតំបន់នីមួយៗ ហើយពឹងផ្អែកលើមូលដ្ឋានគ្រឹះសំខាន់ៗដូចជា វប្បធម៌ ទំនៀមទំលាប់ប្រពៃណី អាកាសធាតុជាដើម។ ហើយមិនត្រឹមតែមានការប្រែប្រួលនោះទេ វាត្រូវបានបញ្ជាក់ពីតំបន់ភូមិសាស្ត្រថែមទៀតផង។

**អ្នកនាំសារ៖** តើជាការពិតឬទេ ដែលយើងធ្លាប់ឮថា ផ្ទះខ្មែរសម័យបុរាណបញ្ជាក់ពីឋានៈតួនាទី របស់បុគ្គលជាម្ចាស់ផ្ទះ?

**សាស្ត្រាចារ្យ ជុំ សេរីវង្សា៖** ពិតណាស់ លំនៅស្ថានខ្មែរសម័យបុរាណ ឆ្លុះបញ្ចាំងពីសភាពតួនាទី ឬឋានន្តរស័ក្តរបស់ម្ចាស់ផ្ទះផងដែរ។ ផ្ទះធំភាគច្រើនបញ្ជាក់ពីតួនាទីធំ ក្នុងសង្គមខ្មែរ ឬក៏ក្នុងសកម្មភាពនយោបាយ និងបញ្ជាក់ពីភាពស្តុកស្តម្ភខាងទ្រព្យសម្បត្តិរបស់បុគ្គល ចំណែកឯផ្ទះតូចៗ ដែលសង់ដាច់ពីគ្នានោះ ភាគច្រើនជាផ្ទះរបស់ពលរដ្ឋទូទៅ ឬប្រជាពលរដ្ឋសាមញ្ញ និងការប្រកបរបរក្នុងជីវិតប្រចាំថ្ងៃ។

**អ្នកនាំសារ ៖** តើសំណង់ផ្ទះខ្មែរសម័យបុរាណ ខ្មែរមានការបែងចែកជាប៉ុន្មានប្រភេទ ហើយការសាងសង់នោះមានលក្ខណៈដូចម្តេច?

**សាស្ត្រាចារ្យ ជុំ សេរីវង្សា ៖** លំនៅស្ថានខ្មែរមាន៥ប្រភេទគឺ ផ្ទះខ្មែរ ផ្ទះរោង (ផ្ទះកន្តាំង) ផ្ទះរោងដោល ផ្ទះរោងឡើង និងផ្ទះប៉ិត។ ផ្ទះខ្មែរ ត្រូវបានគេសាងសង់ឡើងដោយមានដំបូលមួយខ្ពស់ហើយចោទដើម្បីឲ្យរូបភាពខាងមុខមានសោភ័ណ្ឌភាព និងធ្វើឲ្យមើលឃើញកំពូលដំបូលផ្ទះពីចំងាយមានលក្ខណៈជាកំពូលប្រាសាទ។

**អ្នកនាំសារ៖** ជាទូទៅផ្ទះខ្មែរយើងសម័យអតីតកាលមានការបែងចែកជាប្រភេទ។ តើប្រភេទផ្ទះនីមួយៗ មានការនិយមដូចម្តេច និង ការសាងសង់បែបនេះ ដើម្បីបញ្ជាក់ពីអ្វីខ្លះដែរ?

**សាស្ត្រាចារ្យ ជុំ សេរីវង្សា៖** ជាការពិតទៅ ផ្ទះរោង ឬកន្តាំង គេសង់ជាមួយដំបូលយ៉ាងទាប ហើយពុំសូវស្រួច ដើម្បីការពារនិងឲ្យមានភាពងាយស្រួល កុំឲ្យមានការបារម្ភក្នុងការរកមើលផ្លោង ឬគ្រឿងបង្គុំដំបូលវែង។ ផ្ទះរោងដោល គេសង់ដោយមានដំបូលធំដែលពង្រីកជាសំយ៉ាបមកលើរានហាល។ ផ្ទះរោងឡើង គេសង់ដោយមានដំបូលធំមួយ និងមានសំយ៉ាបនៅផ្នែកខាងមុខ និងក្រោយផ្ទះ។ ផ្ទះប៉ិត គេសាងសង់ឡើងជាមួយនឹងដំបូលដែលមានរាងបួនស្មើគ្នា ដោយគេពុំចាំបាច់ធ្វើផ្នែកខាងមុខ និងខាងក្រោយនៃដំបូលឡើយ។

**អ្នកនាំសារ៖** បើមើលពីទិដ្ឋភាពជាក់ស្តែង សំណង់ខ្មែរបុរាណ ឬផ្ទះសម្បែងច្រើនតែត្រូវបានសាងសង់ ឡើងដោយមានសរសរខ្ពស់ៗ ហេតុអ្វីបានជាខ្មែរសម័យនោះច្រើនតែសាងសង់វាឡើងបែបនេះ ឬមានបង្កប់អត្ថន័យពិសេស យ៉ាងណា?

**សាស្ត្រាចារ្យ ជុំ សេរីវង្សា ៖** ការសង់ផ្ទះផុតពីដីរបស់ខ្មែរ គឺដើម្បីគេចពីការជន់លិចនិងសត្វសាហាវផ្សេងៗ។ ក្រៅពីនេះ គេអាចប្រើប្រាស់ទីធ្លារខាងក្រោមផ្ទះសម្រាប់ដាក់សត្វ និងធ្វើកិច្ចការប្រចាំថ្ងៃ ដូចជាត្បាញរវៃ ឬធ្វើជង្រុកស្រូវជាដើម តែបើក្រឡេកមើលពីភូមិសាស្ត្រ សម័យនោះសណ្ឋានដីមានរាងជាទំនាប និងងាយរងគ្រោះដោយទឹកជំនន់ នឹងម្យ៉ាងទៀតនោះខ្មែរនិយមសាងសង់ផ្ទះ ក្បែរៗនឹងប្រភពទឹក ដូចជា ទន្លេ ស្ទឹង ជាដើម វាងាយរងទទួល ទឹកជំនន់ នារដូវវស្សា ដែលធ្វើឲ្យលិចលង់ ផ្ទះសម្បែង។ល។ ក៏ប៉ុន្តែមួយវិញទៀត ខ្មែរយើងសម្បូរព្រៃនាម ជាដើមដែលជាជម្រកសត្វផ្សេងៗ ដែលពពួកសត្វទាំងនោះអាចនឹង បង្កគ្រោះថ្នាក់ដល់ កូនចៅរបស់ពួកគាត់ ទើបបានជាមានការសាងសង់ ផ្ទះដែលមានសរសរខ្ពស់ៗបែបនេះ។

**អ្នកនាំសារ៖**តើអាចប្រៀបធៀបបានទេ ឬមានលក្ខណៈពិសេស ដូចម្តេច ដែលយើងគ្រាន់តែមើលផ្ទះយើងអាចសម្គាល់បានថា ម្ចាស់ផ្ទះ មានតួនាទី និង ឋានៈបែបណាក្នុងសង្គម?

**សាស្ត្រាចារ្យ ជុំ សេរីវង្សា៖** ទម្រង់ផ្ទះខ្មែរ អ្នកមានលទ្ធភាពខ្ពស់ ភាគច្រើន គឺប្រើដំបូលប្រក់ក្បឿង រីឯប្រជាពលរដ្ឋដែលមានលទ្ធភាពតិចតួច វិញច្រើនប្រើស្បូវ ឬស្លឹកត្នោត សម្រាប់ធ្វើ និង មិនមានរាងខ្ពស់ៗដូច ផ្ទះដែលសាងសង់អំពីក្បឿងនោះទេ។ បើយើងមើលមកក្បឿងមានបីប្រភេទ គឺក្បឿងស្រការលិញ ឬស្រការពស់នាគរាជ ក្បឿងក្បាច់ និងក្បឿងស្រទបចេកផ្កាប់ ដែលភាគច្រើនយកលំនាំតាមប្រាសាទខ្មែរ នានាជាដើម។

ផ្ទះមន្ត្រី សេដ្ឋី សម័យនោះយើងអាចមើលឃើញថា មានទីធ្លារស្ទួនច្បារជាដើម និងមានរបងព័ទ្ធជុំវិញ ជាលក្ខណៈឆ្លុះបញ្ចាំងពីឥទ្ធិពលរបស់ម្ចាស់ផ្ទះ តែបើសម្រាប់មនុស្សធម្មតាវិញ ច្រើនផ្តុំៗគ្នានៅតាមដងទន្លេ ឬជិតនឹងវាលស្រែ ចម្ការរបស់ពួកគាត់៕

*ដោយ សុផានិត និងអរិយបុត្រ*

## បច្ចុប្បន្នភាពនៃផ្ទះបុរាណខ្មែរ

ដោយសារតែការរីកចម្រើននៃសេដ្ឋកិច្ច និងការផ្លាស់ប្តូរផ្នត់គំនិតនិងបែបបទនៃការរស់នៅបច្ចុប្បន្ន ផ្ទះប្រភេទបុរាណៗ ស្ទើរតែបាត់បង់ បើទោះបីវាគឺជា ជាផ្នែកមួយនៃអត្តសញ្ញាណរបស់ខ្មែរ ក៏ដោយ។

ដើម្បីទប់ស្កាត់ការបាត់បង់អត្តសញ្ញាណ កាលពីចុងឆ្នាំ២០១៦ លោក ទេសរដ្ឋមន្ត្រី ជា សុផារ៉ា រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម បានស្នើឲ្យក្រុមវិស្វករកម្ពុជាធ្វើយ៉ាងណារចនាប្លង់សំណង់អគារនានាត្រូវរក្សារចនាបទទម្រង់ជាខ្មែរ។

ក្រោយមក កាលពីអំឡុងពាក់កណ្តាលខែមិថុនា ឆ្នាំ២០១៧កន្លងទៅថ្មីៗនេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី មានប្រសាសន៍ថា ការអភិរក្សប្រកាន់តឹងមិនអាចធ្វើឲ្យប្រទេសជាតិរីកចម្រើនបានទេ ប៉ុន្តែ ការធ្វើឲ្យស៊ីវិល័យគ្មានព្រំដែន ក៏នឹងធ្វើឲ្យប្រទេសជាតិ បាត់បង់អត្តសញ្ញាណផងដែរ។

សព្វថ្ងៃនេះ ផ្ទះបុរាណដែលអាចរក្សាបាននៅក្នុងតំបន់ទីក្រុង ជាពិសេស គឺនៅរាជធានីភ្នំពេញតែម្តង គឺពិបាករកហើយបើមាន ក៏ម្ចាស់ផ្ទះបុរាណនេះ ក៏ជាកម្មសិទ្ធិរបស់អ្នកដែលមានគំនិតអភិរក្ស ឬចាស់ ព្រឹទ្ធាចារ្យ ដែលនៅសេសសល់ពីសង្គម។

ឧបាសិកា វ៉ា ម៉ុន ដែលមានអាយុ៩០ ឆ្នាំ និងជាម្ចាស់ផ្ទះ ផ្ទះប៉ិតដែលសាងសង់ឡើងក្នុងឆ្នាំ១៩២០ បានមានប្រសាសន៍ថា ជំនាន់ដែលសាងសង់ផ្ទះនេះបានធំ ដោយសារតែតម្លៃរបស់ឈើមានតម្លៃធូរថ្លៃ។ លោកយាយ បានរៀបរាប់បន្តទៀតថា ផ្ទះនេះសង់អស់រយៈពេល ៣ឆ្នាំ អស់ថវិការប្រហែលជា ៥.០០០រៀល ។ លោកយាយបានបន្តថា អ្វីដែលជារបស់ចាស់ជាងគេនៅក្នុងផ្ទះនេះ គឺ គ្រែក្តារដែលជាប្រភេទឈើបេង និងកញ្ចក់ទូសម្អាងកាយ ដែលជារបស់ដែលឪពុកម្តាយរបស់លោកយាយបានបន្សល់ទុកឲ្យ។

លោកយាយបានបន្តថា ផ្ទះនេះពុំមានអាកាសធាតុក្តៅស្ពុះស្ពាប់ ដោយគ្រាន់តែបើកបង្អួចត្រជាក់គេងបាន ដែលអារម្មណ៍នេះ គឺមិនអាចពិពណ៌នាបាន ។

# មេដឹកនាំកូរ៉េខាងត្បូងថា អាស៊ានជាដៃគូដ៏ចម្បងរបស់ខ្លួន

លោក មូន ជេអ៊ីន ប្រធានាធិបតីនៃប្រទេសកូរ៉េខាងត្បូង បានអះអាងថា អាស៊ាន គឺជាដៃគូដ៏មានសក្តានុពលរបស់កូរ៉េខាងត្បូង ដោយសារតែអាស៊ានបានកំពុងតែប្រែក្លាយទៅជាតំបន់មួយដែលមានជោគជ័យខាងផ្នែកយន្តការសេដ្ឋកិច្ចដ៏ចម្បងមួយនៅលើពិភពលោក។

នៅក្នុងសារមួយ ដែលលោកបានសរសេរនៅមុនពេលលោកចូលរួមនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ នៅហ្វីលីពីន លោក មូន បានអះអាងថា មកដល់ពេលនេះមានពលរដ្ឋកូរ៉េខាងត្បូងប្រមាណជា៦ លាននាក់ បានធ្វើ ទេសចរណ៍ និងពាណិជ្ជកម្មក៏ដូចជាអាជីវកម្មនៅអាស៊ាន ដោយនៅក្នុងនោះ មានប្រជាជាតិអាស៊ានប្រមាណជា៥០០.០០០ នាក់ បានមករស់នៅនិងធ្វើការនៅក្នុងប្រទេសកូរ៉េ ខណៈដែលមានពលរដ្ឋកូរ៉េប្រមាណជា ៣០០.០០០ នាក់ ក៏បានមករស់នៅ និងធ្វើការនៅក្នុងបណ្តាប្រទេសអាស៊ានផងដែរ ។

លោកបានបន្តថា នយោបាយកូរ៉េខាងត្បូងឆ្ពោះមកអាស៊ានមានការប្រែប្រួលនៅក្នុងឆ្នាំ២០១០ ដោយកូរ៉េនិងអាស៊ានបានអភិវឌ្ឍន៍ទំនាក់ទំនងឲ្យក្លាយទៅជា ដៃគូយុទ្ធសាស្ត្រដ៏ចម្បងមួយដែលមានទំនាក់ទំនងល្អតាំងពី ផ្នែកពាណិជ្ជកម្ម ទាំងការទូត ប្រជាជននិងប្រជាជន សេដ្ឋកិច្ចនយោបាយជាដើម។

លោកមូន បានអះអាងថា កូរ៉េនឹងបន្តគាំទ្រអាស៊ានជាពិសេស គឺគាំទ្រនូវផែនការមេ ស្តីអំពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និងផែនការមេស្តីអំពីគំនិតផ្តួចផ្តើមដើម្បីសមាហរណកម្មអាស៊ាន ដើម្បីឲ្យប្រាកដថា អាស៊ាននិងកូរ៉េ គឺជាដៃគូសហប្រតិបត្តិការល្អ ហើយក៏រំពឹងថា កិច្ចសហប្រតិបត្តិការរវាងប្រជាជននិងប្រជាជនកាន់តែប្រសើរថែមទៀត។

# អាស៊ានប្តូរប្រធានហើយ តែបញ្ហាប្រហែលជានៅដដែល

ប្រជាជាតិអាស៊ានបានប្តូរប្រធានហើយ ពោលគឺពីប្រធានាធិបតីហ្វីលីពីន រ៉ូឌ្រីហ្គោ ឌូតែតេ មក លោកនាយករដ្ឋមន្ត្រីសិង្ហបុរី លី សៀនឡុង នៅក្នុងអាណត្តិជាប្រធាន ប្តូរវេនមួយឆ្នាំម្នាក់ ប៉ុន្តែបញ្ហាប្រហែលជា នៅដដែល គឺអាស៊ានត្រូវតែថ្លឹងថ្លែងអំពីតុល្យភាពមហាអំណាចពីសំខាន់ គឺ អាមេរិក ចិន និងបញ្ហាដែលសាំញ៉ាំ ដែលកំពុងតែលងអាស៊ាននៅឡើយនោះ គឺវិបត្តិនៅសមុទ្រចិនខាងត្បូង ។

ការផ្សព្វផ្សាយនិងជំរុញភាពជាគោលនៃអាស៊ាន និងស្ថិរភាពតំបន់ប្រកបដោយវឌ្ឍភាពអាចជារបៀបវារៈការងារដ៏ចម្បងរបស់លោក លី សៀនឡុង ដែលកំពុងតែទទួលភារៈនេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏លោកត្រូវ តែរែកពន្ធនូវតុល្យភាពនៃស្ថិរភាពរវាងមហាអំណាចទាំងពីរនេះផងដែរ ។

នៅមុនទទួលភារៈជាប្រធានអាស៊ាន ពោលគឺចន្លោះ ពីខែកញ្ញា និងតុលា នៅក្នុងនាមជានាយករដ្ឋមន្ត្រីនៃប្រទេសសិង្ហបុរី លោក លី សៀនឡុង បានទៅបំពេញទស្សនកិច្ចនៅក្នុងទីក្រុងប៉េកាំង និងទីក្រុងវ៉ាស៊ីនតោន ក្នុងឋានៈជាមេដឹកនាំប្រជាជាតិដ៏តូចមួយ ប៉ុន្តែជាប្រទេសដែលមានសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការល្អរវាងមហាអំណាចទាំងពីរនេះ ខណៈដែលមហាអំណាចទាំងពីរក៏ជា ដៃគូសន្ទនាដ៏ចម្បងរបស់ប្រជាជាតិអាស៊ានដែលលោកត្រូវ សម្របសម្រួល និងដឹកនាំកិច្ចការមួយចំនួនចាប់ពីពេលនេះដល់ឆ្នាំក្រោយ ។

នៅក្នុងឋានៈលោកជាប្រធានអាស៊ាននេះ កិច្ចការដែលជាបន្ទុក គឺអាចមានបញ្ហាធំៗមួយចំនួនដែលនៅក្នុងនោះ គឺរួមមានបញ្ហាសមុទ្រចិនខាងត្បូង។ នៅក្នុងឋានៈជារដ្ឋមួយដែលគ្មានជម្លោះ នៅក្នុងនោះ សិង្ហបុរីត្រូវបានគេរំពឹងថា នឹងមានលទ្ធភាពនៅក្នុងការរុញឲ្យចេញនូវដំណើរការពង្រាងនូវក្រមប្រតិបត្តិសម្រាប់សមុទ្រចិនខាងត្បូង ដែលចិនចង់បានបំផុតដើម្បីដោះស្រាយបញ្ហានេះ តាមគោលការទ្វេភាគី មិនឲ្យទំនាស់នេះក្លាយជាវិបត្តិអន្តរជាតិ។ ក្រៅពីនេះបន្ទុកមួយទៀតសម្រាប់លោកនោះ គឺអាចពាក់ព័ន្ធនឹងបញ្ហាវិបត្តិនៅរដ្ឋរ៉ាឃីននៅប្រទេសមីយ៉ាន់ម៉ា ដែលកំពុងតែជាចំណុចក្តៅមួយនៅឡើយ។ ក្រៅពីនេះ ក៏មានអ្នកវិភាគមួយចំនួនបានលើកឡើងថា ស្ថានភាពនយោបាយនៅកម្ពុជានៅក្នុងឆ្នាំក្រោយក៏អាចជាចំណុចបន្ទុកមួយរបស់លោកផងដែរ ដោយសារតែកម្ពុជានឹងរៀបចំការបោះឆ្នោត នៅឆ្នាំ២០១៨ ។

# អាស៊ានកំពុងតែសម្លឹងចិននៅក្នុងកែវភ្នែកមួយស្រទន់

វិបត្តិនៅសមុទ្រចិនខាងត្បូងបានធ្វើឲ្យមេដឹកនាំអាស៊ានមួយចំនួនច្រឡមខាងកាលពីកិច្ចប្រជុំកំពូលអាស៊ាននៅក្នុងឆ្នាំ២០១២ នៅពេលកម្ពុជាធ្វើជាប្រធានប្តូរវេនអាស៊ាន ប៉ុន្តែវាចាប់ផ្តើមស្រទន់បន្តិចម្តងៗក្រោយពេលដែលកិច្ចប្រជុំកំពូលនេះបានរសាត់ចេញពីកម្ពុជា រហូតដល់ទីក្រុងម៉ានីលប្រទេសហ្វីលីពីន កាលពីខែពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០១៧ កន្លងទៅនេះ។

មេដឹកនាំអាស៊ានមួយចំនួនជាពិសេស គឺហ្វីលីពីន វៀតណាម ដែលគេដឹងថា ជាបងធំមួយនៅក្នុងទំនាស់នោះ រួមជាមួយនឹងប្រទេសផ្សេងដែលមាននៅក្នុងជម្លោះទឹកដីនៅសមុទ្រចិនខាងត្បូងផ្សេងទៀត ដូចជា ប្រ៊ុយណេ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី លើកលែងកោះតៃវ៉ាន់ចេញ ដែលមិនមែនជាដៃគូរបស់អាស៊ានដោយសារនយោបាយចិនតែមួយ ដែលមានទំនាស់ទឹកដីជាមួយនឹងចិន គឺបានសម្លឹងចិននៅក្នុងកែវភ្នែកមួយដ៏ស្រទន់ ខុសប្លែកមែនទែនកាលពីឆ្នាំ២០១២ ដែលពេលនេះ មេដឹកនាំប្រទេសអាស៊ានដែលមានទំនាស់ទាំងនោះ សម្លឹងចិននៅក្នុងកែវភ្នែកមួយ ដែលពិបាកនឹងថ្លែង ប៉ុន្តែមិនហ៊ានបញ្ចេញឲ្យអស់កំហឹងដោយសារតែទំនើប កម្មយោធារបស់ចិននៅទឹកដីមាន ជម្លោះនោះ។

កាលពីឆ្នាំ២០១២ មេដឹកនាំអាស៊ានដែលមានទំនាស់ខ្លាំង គឺបានខិតខំចាប់បង្ខំកម្ពុជា រួមជាមួយគេ ឲ្យសម្លឹងចិននៅក្នុងកែវភ្នែកមួយដ៏មុតស្រួច ប៉ុន្តែមិនអាចទៅរួចដោយសារតែកម្ពុជា បានប្រកាសពីគោលនយោបាយមួយច្បាស់លាស់ដើម្បីឆ្លើយតបនឹងកំហឹងការទូតដ៏ខ្លាំងក្លារវាងហ្វីលីពីន វៀតណាម និងចិន ហើយបានព្យាយាមសម្របសម្រួល ដើម្បីកាត់បន្ថយភាពតានតឹងដើម្បីផលប្រយោជន៍ឈ្នះៗទាំងអស់គ្នា ដោយគ្មានសង្គ្រាម ឬវិបត្តិធ្ងន់ធ្ងរណាមួយបានកើតមានឡើង។

ចាប់តាំងពីឆ្នាំ២០១២ មក គឺទំនាស់នេះមានការស្រួចស្រាលខ្លាំង ប៉ុន្តែវាក៏ជាភ័ព្វសំណាងផ្នែកការទូតមួយរបស់កម្ពុជា នៅក្នុងវិបត្តិនៃសមុទ្រចិនខាងត្បូង ដោយសារតែរដ្ឋបាលថ្មីរបស់ប្រទេសហ្វីលីពីនបានបន្ធូរជំហរនៅក្នុងការដោះស្រាយវិបត្តិ ក្រោយពេលដែលរដ្ឋបាលថ្មី ដែលបានអូសទាញកម្ពុជាធ្លាក់ចូលទៅក្នុងវិបត្តិនោះ ដោយការប្តឹងចិនទៅកាន់តុលាការមជ្ឈការអន្តរជាតិនៅទីក្រុងឡាអេ ហើយត្រូវបានតុលាកានោះ សម្រេចទាត់ចោលរាល់ការកាន់កាប់ទឹកដីទាំងអស់របស់ចិននៅសមុទ្រចិនខាងត្បូងនេះ។

នៅក្រោមរដ្ឋបាលថ្មី ដែលបានឡើងមកដឹកនាំហ្វីលីពីន ចាប់តាំងពីឆ្នាំ២០១៦មក ហ្វីលីពីនបានប្តូរជំហរ ជាហេតុនាំឲ្យវៀតណាម ហេងហាងផ្នែកការទូត ដូច្នេះហើយវិបត្តិផ្នែកការទូតនៅសមុទ្រចិនខាងត្បូង ក៏លែងក្លាយជារឿងក្តៅនៅកិច្ចប្រជុំកំពូលអាស៊ានតទៅទៀត ជាពិសេស គឺកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ ថ្មីៗនេះ។ មេដឹកនាំអាស៊ានទាំងអស់ សុទ្ធតែសម្លឹងចិននៅក្នុងក្រសែភ្នែកជាដៃគូរពាណិជ្ជកម្ម ដៃគូវិនិយោគ ទេសចរណ៍និង បច្ចេកវិទ្យា ដ៏ចម្បងមួយ សម្រាប់អាស៊ាន។



# គ.ជ.ប. បែងចែកអាសនៈទំនេរ៥៥កៅអីនៅរដ្ឋសភាជូនគណបក្ស៥

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានធ្វើការបែងចែករួចរាល់ជាលទ្ធផលផ្លូវការនូវអាសនៈទាំង៥៥ របស់អតីតគណបក្សសង្គ្រោះជាតិ ទៅគណបក្សនយោបាយចំនួន៥ គឺគណបក្សហ្វ៊ុនស៊ិនប៉ិច គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ គណបក្សខ្មែរឈប់ក្រ គណបក្សសញ្ជាតិកម្ពុជា និងគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ ។

គ.ជ.ប បានប្រកាសកាលពីព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ថា តាមលទ្ធផលនៃការបែងចែកអាសនៈនៅថ្ងៃទី២២ វិច្ឆិកា គឺ គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលមានសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ជាប្រធានទទួលបានអាសនៈចំនួន៤១។ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ដែលដឹកនាំដោយលោក ខឹម វាសនា ទទួលបានចំនួន៦អាសនៈ។ គណបក្សខ្មែរឈប់ក្រ ដែលលោក គ្រ៉ាញ់ ដារ៉េន ជាប្រធាន ទទួលបានចំនួន៥អាសនៈ។ គណបក្សសញ្ជាតិកម្ពុជា ដែលមាន លោក សេង សុខេង ជាប្រធាន គឺបានចំនួន ២អាសនៈ និងគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ដឹកនាំដោយលោក ហួន រាជចំរើន បានចំនួន១អាសនៈ។ ចំណែកគណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ គឺមិនបានទទួលអាសនៈនោះទេដោយសារតែសម្លេងឆ្នោតមិនគ្រប់។

នេះគឺជាការប្រកាសនៃការបែងចែករបស់គ.ជ.ប. ប៉ុន្តែ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងគណបក្សខ្មែរឈប់ក្រ បានប្រកាសបដិសេធមិនទទួលយកអាសនៈដែលបានមកពីការបែងចែកអាសនៈរបស់អតីតគណបក្សសង្គ្រោះជាតិ នោះទេ។

ទាក់ទិននឹងចំណុចនេះ លោក សោម សូលីដា អគ្គលេខាធិការរងគ.ជ.ប បានបញ្ជាក់ប្រាប់អ្នកសារព័ត៌មាននៅក្នុងស្រុកមួយចំនួនថា តាមច្បាប់នៃមាត្រា១៣៨ស្ទួន គ.ជ.ប នឹងត្រូវបែងចែកអាសនៈដែលនៅទំនេរនោះ ឲ្យទៅគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា។

គួរលើកថា អាសនៈនៅក្នុងសភាដែលទំនេរទាំង៥៥ នេះគឺជារបស់អតីតគណបក្សសង្គ្រោះជាតិ ប៉ុន្តែគណបក្សនេះត្រូវបានតុលាការកំពូលសម្រេចរំលាយកាលពីថ្ងៃទី១៦ វិច្ឆិកា ២០១៧ និងផ្អាកសកម្មភាពនយោបាយថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិចំនួន១១៨រូប រយៈពេល៥ឆ្នាំ ដោយហាមឃាត់មិនឲ្យមានសកម្មភាពនយោបាយផ្សេងៗតាមបណ្តឹងរបស់ក្រសួងមហាផ្ទៃ កាលពីថ្ងៃទី០៦ តុលា ២០១៧ ពាក់ព័ន្ធនឹងករណីរៀបចំផែនការឃុបឃិតជាសម្ងាត់ជាមួយបរទេសក្នុងការផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ក្រោមទម្រង់នៃការធ្វើបដិវត្តន៍ពណ៌ដោយយកគំរូតាមប្រទេសយូហ្គោស្លាវី និងស៊ែប៊ី ក៏ដូចជាបណ្តាប្រទេសមួយចំនួននៅមជ្ឈិមបូព៌ា៕

# រាជរដ្ឋាភិបាលនឹងតែងតាំងអនុប្រធានក្រុមហ៊ុនអាមេរិកមួយរូបឲ្យធ្វើទីប្រឹក្សា

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានថ្លែង កាលពីថ្ងៃទី ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅវិមានសន្តិភាព នៅក្នុងជំនួបជាមួយនឹងលោក ចន រ៉ាយ អនុប្រធានក្រុមហ៊ុន ជីណឺរ៉ល អេឡិចទ្រិក របស់សហរដ្ឋអាមេរិកដែលបាន និងកំពុងវិនិយោគនៅកម្ពុជាថា ជនបរទេសរូបនេះនឹងទទួលការស្នើសុំតែងតាំងធ្វើជាទីប្រឹក្សារាជរដ្ឋាភិបាល។ នេះបើយោងតាមលោក កៅ គឹមហួន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានប្រាប់អ្នកយកព័ត៌មានក្រោយជំនួបនោះ។

លោកបានបញ្ជាក់ថា សម្តេចតេជោនឹងស្នើសុំដល់ព្រះមហាក្សត្រផ្តល់ឱ្យលោក ចន រ៉ាយ មានតួនាទីជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ដោយសារតែលោកជាជនបរទេស ដែលមានបទពិសោធន៍ច្រើនក្នុងកិច្ចការអភិវឌ្ឍន៍នៅកម្ពុជា និងដោយសារលោកនឹងត្រូវចូលនិវត្តន៍ពីការងារនៃក្រុមហ៊ុនជីណឺរ៉ល អេឡិចទ្រិក ផងដែរនោះ ។

លោកបានបន្តទៀតថា ជាការឆ្លើយតប លោក ចន រ៉ាយ បានសម្តែងនូវមោទនភាពក្នុងការទទួលយកតួនាទីនេះ ហើយលោកបានសន្យាថានឹងខិតខំចូលរួមបម្រើដល់ការអភិវឌ្ឍរបស់កម្ពុជា។

បច្ចុប្បន្នក្រុមហ៊ុន ជីណឺរ៉ល អេឡិចទ្រិក មានគម្រោងវិនិយោគលើវិស័យសំខាន់ៗចំនួន២ គឺវិស័យអគ្គិសនី និងវិស័យសុខាភិបាលដែលទាក់ទងនឹងការផ្តល់នូវទឹកស្អាតដល់មន្ទីរពេទ្យ ដែលកន្លងមកត្រូវបានប្រើប្រាស់ក្នុងមន្ទីរពេទ្យជាច្រើនមកហើយ។

ក្រុមហ៊ុននេះក៏កំពុងសិក្សាលើការផលិតថាមពលអគ្គិសនីដើរដោយធ្យូងថ្មក្នុងខេត្តព្រះសីហនុផងដែរ ទន្ទឹមនឹងនេះ ក្រុមហ៊ុនក៏កំពុងសិក្សាលើបណ្តាញអគ្គិសនី និងការបែងចែកអគ្គិសនី ទៅកាន់ប្រជាពលរដ្ឋផងដែរ ដែលគម្រោងនេះនឹងបញ្ចប់នាចុងឆ្នាំ២០១៧នេះ។

# កម្ពុជានឹងចាប់ផ្តើមផលិតប្រេងនៅឆ្នាំ២០១៩នៅប្លុក A និងB

លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានថ្លែងថា កម្ពុជានឹងចាប់ផ្តើមផលិតប្រេងនៅឆ្នាំ២០១៩ខាងមុខនេះដោយក្រុមហ៊ុនសិង្ហបុរី ហើយរំពឹងថាអាចផលិតប្រេងកាតបាន៣១លានបារ៉ែល នៅដំណាក់កាលទី១ ពីប្លុកA និងB ខណៈប្លុកCក្រុមហ៊ុន ម៉ាឡេស៊ីកំពុងសិក្សាស្រាវជ្រាវនិងប្លុកផ្សេងទៀតមានក្រុមហ៊ុនបរទេសកំពុងដាក់ពាក្យសុំរុករកបន្ថែម។

ថ្លែងនៅក្នុងឱកាសធ្វើបាឋកថា ចែករំលែកចំណេះដឹងនិងបទពិសោធន៍ លើប្រធានបទស្តីពី "យន្តការគ្រប់គ្រងវិស័យរ៉ែ និងថាមពលនៅកម្ពុជា និងការបង្ការទប់ស្កាត់ផលប៉ះពាល់ធនធានធម្មជាតិ" ជូន សិក្ខាកាមនៃបណ្ឌិតសភានគរបាលកម្ពុជា នៅថ្ងៃទី២៣ វិច្ឆិកា ២០១៧ លោក ស៊ុយ សែម បានបញ្ជាក់ថា រហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាបានរកឃើញតំបន់មានប្រេងកាតទាំងសមុទ្រ និងលើគោកមានចំនួន ២៥ប្លុក ដែលអាចផលិតប្រេងបានចំនួន៥លានតោនក្នុងមួយឆ្នាំៗ។

លោកបានបន្តថា តំបន់ប្រេងក្នុងសមុទ្រ គឺមានចំនួន៦ប្លុក គឺប្លុក A.B.C.D.Eនិងប្លុកF ប៉ុន្តែប្លុកAនិងB នឹងចាប់ផ្តើមផលិតនៅឆ្នាំ២០១៩ខាងមុខ ដោយក្រុមហ៊ុនគ្រីសរបស់ប្រទេសសិង្ហបុរី ដែលអាចផលិតនូវដំណាក់កាលទី១បានចំនួន៣១លានបារ៉ែល។ លោកបានលើកឡើងថា ដោយឡែកសម្រាប់តំបន់ប្រេងនៅលើគោកវិញ គឺគេបានរកឃើញនៅ ខេត្តកំពង់ធំ ដោយមានចំនួន១៩ប្លុក ក៏ប៉ុន្តែនាពេលបច្ចុប្បន្ននេះមានក្រុមហ៊ុនភីត្រូរបស់វៀតណាម កំពុងបានដាក់ពាក្យសុំសិក្សាស្រាវជ្រាវ ហើយចំនួន១៨ប្លុកទៀត គឺពុំទាន់មានក្រុមហ៊ុនណាមួយស្ម័គ្រចិត្តចូលធ្វើការសិក្សានៅឡើយ។

លោកបានបន្ថែមទៀតថា អាជ្ញាធរនឹងរៀបចំឱ្យបានល្អប្រសើរ និងងាយស្រួលដល់ការ ដឹកជញ្ជូន ហើយធ្វើបំពង់បង្ហូរប្រេងពីខេត្តព្រះសីហនុមកកាន់រាជធានីភ្នំពេញ និងខេត្តមួយចំនួន ដែលពាក់ព័ន្ធផងដែរ។

# ប្រមុខរដ្ឋាភិបាលកម្ពុជាសំដែងការព្រួយបារម្ភអំពីកម្មវិធីអាវុធនុយក្លេអ៊ែរកូរ៉េខាងជើង

កាលពីព្រឹកថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានបញ្ចេញសម្លេងជាសាធារណៈអំពី កម្មវិធីអាវុធនុយក្លេអ៊ែររបស់ប្រទេសកូរ៉េខាងជើង ។

ថ្លែងនៅក្នុងពេលអញ្ជើញជាអធិបតីភាពនៅក្នុងមហាសន្និបាត វិសាមញ្ញកាយឫទ្ធិជាតិកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានបង្ហាញក្តីសង្ឃឹម យ៉ាងមុតមាំថា ពិភពលោកនឹង មានភាពស្ងប់ស្ងាត់ឡើងវិញ តាមរយៈការសន្ទនាដោយសន្តិវិធី ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា បន្ទាប់ពីកូរ៉េខាងជើង បានបាញ់មួយគ្រាប់ នាពេលថ្មីៗនេះ បណ្តាប្រទេសមួយចំនួន នាំគ្នាខ្លាចអាវុធ របស់កូរ៉េខាងជើង។

សម្តេចបានសម្តែងក្តីសង្ឃឹមថា "ពិភពលោក និងមានការស្ងប់ស្ងាត់ តាមរយៈនៃការសន្ទនា ដោយ ស្មារតីស្ថាបនា ហើយប្រហែលជាកម្ពុជា ជាប្រទេសតូចមួយ មិនមែនជាគោលដៅ វាយប្រហាររបស់នុយក្លេអ៊ែរ កូរ៉េខាងជើង ឬភេរវកម្មអីនោះទេ។ ខ្ញុំសង្ឃឹមយ៉ាងដូច្នេះ!"។

ការបញ្ចេញយោបល់នេះ បានកើតឡើងក្រោយពេលដែលកូរ៉េខាងជើងបានបាញ់សាកល្បងមីស៊ីល អន្តរទ្វីបវ៉ាសុង ១៥ កាលពីថ្ងៃពុធ សប្តាហ៍មុនបានជោគជ័យ។

ទាក់ទងនឹងភាពតានតឹងនៅឧបទ្វីបកូរ៉េនេះ កម្ពុជាតែងតែបានជំរុញឲ្យគ្រប់ភាគី វិលត្រឡប់មករកការចរចា ហើយសង្ឃឹមថា មានតែការចរចាទេ ដែលអាចរកដំណោះស្រាយអំពីបញ្ហានៅឧបទ្វីបកូរ៉េបាន មិនមែនការប្រឈមមុខដាក់គ្នាឡើយ ។

# កន្លងមកជិត៤០ឆ្នាំ របបប៉ុលពតនៅតែជាអតីតក



របប ប៉ុលពត គឺនៅតែជាថ្ងៃដ៏ មាន អត្ថន័យ និងជាថ្ងៃចងចាំមិនអាចបំភ្លេចបានសម្រាប់ប្រជាពលរដ្ឋកម្ពុជាភាគច្រើន ជាពិសេសអ្នកដែលស្ថិតនៅមជ្ឈឹមវ័យ ដែលបានរួចជីវិត រួចពីទុក្ខវេទនា ដែលពួកគេបានហែលឆ្លងនៅក្នុងសម័យនៃការគ្រប់គ្រងរបស់របបកម្ពុជាប្រជាធិបតេយ្យ ហើយ ត្រូវបានទទួលដឹងជាទូទៅថា ជារបបប្រល័យពូជសាសន៍ប៉ុល ពត ឬខ្មែរក្រហមនោះ។

លោក សេក ចម្រើន ជាប្រជាពលរដ្ឋដែលមានវ័យ ៤៩ឆ្នាំ បានថ្លែងថា បំភ្លេចមិនបានទេបើទោះបីជាវាគឺជារឿងរ៉ាវដែលបានកើតមានឡើងប្រហែលជាជិត ៤០ ឆ្នាំក៏ដោយ ។

លោកបានបញ្ជាក់ថា "បំភ្លេចម៉េចបាន បើកាលនោះ មុខម៉ែឪ អាពត (របបប៉ុល ពត) វាមិនទាំងឲ្យជួបផងនោះ"។ លោកបានបញ្ជាក់បន្តទៀតថា "បំភ្លេចមិនបានហ្មង កាលនោះព្រោះតែក្មេង ព្រោះតែឃ្លានគ្រាន់តែ បេះសណ្តែកមួយក្តួរយកមកទំពាចំអែតក្រពះ ឈ្លបវាឃើញ វាចាប់ខ្ញុំដាក់លើសំបុក ស្រម៉ោចភ្លើង ខាំឡើងពេញខ្លួនឡើងគ្រុន តែមិនដឹងយ៉ាងម៉េចចេះតែរស់បានឃើញសន្តិភាព ឃើញប្រទេសមកដល់បច្ចុប្បន្ននេះ នឹងគេ"។

លោកបានរៀបរាប់ថា អ្វីៗអាចបំភ្លេចបាន ប៉ុន្តែការឈឺចាប់ អាការៈស្រេកឃ្លាន ការរងទុក្ខវេទនា ការគ្មានភាពកក់ក្តៅ គឺវាពិបាកនឹងភ្លេចណាស់។ លោកបានបន្តថា វាដក់ជាប់នៅក្នុងខ្លួន នៅក្នុងការចងចាំរបស់យើងតែម្តង ។

បើតាមការអះអាងរបស់លោក ចម្រើន នៅក្នុងសម័យប៉ុល ពត លោក មានអាយុប្រហែលជា ៦ ទៅ ៧ឆ្នាំប៉ុណ្ណោះ ហើយលោកត្រូវបាន គេបំបែកចេញពីឪពុកម្តាយ ហើយឲ្យទៅរស់នៅក្នុងកងកុមារ ដើររើសអាចម៍គោ សែងដី រកក្តាម រកត្រី បេះបន្លែ ធ្វើនេះធ្វើនោះគ្មានពេលទំនេរ គ្មានបានទៅសាលារៀន គ្មានរបស់ស្អីហូបចុកបរិបូរណ៍ដូចក្មេងសម័យនេះទេ ។

លោកបានបន្តទៀតថា "សម្រាប់អ្នកណាមិនដឹងទេ ប៉ុន្តែខ្ញុំមិនអាចភ្លេចរឿងរ៉ាវដែលហែលឆ្លងសម័យនោះបានទេ។ ខែនេះ(រដូវរងា)ក្មេងៗដូចជាចៅខ្ញុំអីអាយុ ៦ ទៅ ៧ឆ្នាំអី នៅដេកអោបឪពុកម្តាយ មានភួយ មានទឹកក្តៅទឹកត្រជាក់មានគេថ្នាក់ថ្នម។ សម័យនោះវិញខ្ញុំចាំថា ខ្ញុំកតែអាវមកពាក់គ្មានផង យប់ឡើងដេកក្នុងពំនូកចំបើងទេ ឃ្លាងជាមួយគ្នាទៅវិញទៅមកទេ"។

លោក ពេជ្រ ឆារិទ្ធ ជាមន្ត្រីចូលនិវត្តន៍មួយរូប បានមានប្រសាសន៍ថា ទោះសម័យនេះ យើងមានហូបចុក មានឡានមានផ្ទះស្តុកស្តម្ភ មានសម្ភារប្រើប្រាស់ទំនើបៗ មានសេចក្តីសុខផ្លូវចិត្ត និងផ្លូវកាយគ្រប់យ៉ាងមែន ប៉ុន្តែលោកមានជំនឿថា គ្មាននរណាអាចភ្លេចអស់នូវទុក្ខវេទនាដែលបាន ហែលឆ្លងកន្លងមកបានទេ។ លោកបានបន្តថា ជាសញ្ជាតិញាណរបស់មនុស្ស ឲ្យតែធ្លាប់ហែលឆ្លងអារឿងទុក្ខវេទនានេះមិនងាយភ្លេចទេ។

លោកបានបញ្ជាក់ថា "ខ្ញុំជឿបែបនេះ! អាទុក្ខវេទនា អាភាពស៊ីអត់ស៊ីឃ្លាននេះ វាថិតជាប់ក្នុងអារម្មណ៍អាក្រក់ណាស់។ ដូចខ្ញុំចឹងចំណាស់ ៧០ជាងហើយ ពេលខ្លះភ្លេចនេះភ្លេចនោះច្រើន តែរឿងអាពតមួយ ដូចជាមិនភ្លេចទេ"។

លោកបានបន្តថា រៀបរាប់ដោយរំលេចចេញនូវទឹកភ្នែកព្រិចៗថា បំភ្លេចម៉េចបាន បើមួយគ្រួសារ រស់តែលោកម្នាក់គត់។ ដោយលោកបាត់បង់ប្រពន្ធ និងកូនប្រុសស្រី៣នាក់អស់រលីង។ លោកបានរៀបរាប់ទៀតថា នាសម័យនោះលោកមិនបានដឹងទេថា ពួកគេបាត់បង់ជីវិតនោះ ដោយលោកត្រូវគេបង្ខំទៅធ្វើការនៅបឹងទន្លេសាបឯណោះ។ លោកបានបន្តថា នៅក្នុងសម័យលុន ណុល លោក រស់នៅភ្នំពេញ ហើយក្រោយពេលបែក ទាហាន ប៉ុល ពត បានជម្លៀសលោក និងគ្រួសារ

# ាលឈឺចាប់របស់ពលរដ្ឋកម្ពុជា



ថតដោយ លីហៀង

ទៅរហូតដល់ពោធិ៍សាត់ ហើយក៏ឲ្យនៅភូមិស្រុកក្រគរ។ នៅទីនោះ លោក ត្រូវបែកគ្រួសារទាំងអស់ ដោយរូបលោកត្រូវគេបង្ខំឲ្យចុះទៅបឹងទន្លេសាប ហើយប្រពន្ធលោក ត្រូវបានគេបង្ខំឲ្យទៅកងចល័តផ្សេង ឯកូនៗគេយកទៅកងកុមារ លើកលែងអាពៅមួយ ដែលមានអាយុ ៥ខែ នៅតាមខ្លួន។ លោកបានបន្តទៀតថា លោកត្រូវបង្ខំនៅតែបឹងទន្លេសាបទេ យូរម្តងបានសុំគេឡើងមកភូមិមកលេងប្រពន្ធកូនបានម្តង តែក្រោយមក គឺត្រូវគេបង្ខំចុះទៅកណ្តាលបឹងទន្លេសាប ក៏ដាច់ការទាក់ទងរហូតដល់រំដោះ ៧ មករា នេះ បានមានឱកាសឡើង គោក ហើយជួបអ្នកភូមិគេប្រាប់ថា ពួកគេស្លាប់អស់ហើយ ដោយអាពៅនោះ គេថា វាឈឺ ហើយ អាទីពីរ និងអាស្រីបងនោះ ថា លង់ទឹក ដោយឡែកប្រពន្ធនោះ គឺឮថា បាត់ដំណឹងក្រោយពេលគេយកទៅកសាងរៀនសូត្រ ។

លោកបានបន្តទៀតថា គ្រួសារលោកសព្វថ្ងៃនេះ គឺរៀបការក្រោយបែករបបប៉ុលពតនេះទេ ដូច្នេះហើយបានជាអាយុជាង ៧០ឆ្នាំហើយ ទើបតែមានចៅបីនឹងគេនោះ។

លោកបានបន្តទៀតថា ភរិយាលោកសព្វថ្ងៃនេះ ក៏ជាស្ត្រីមេម៉ាយស្លាប់កូនស្លាប់ប្តីសម័យ ប៉ុល ពត ដែរ ហើយបើអត់មានរបបនោះ ប្រហែលជាកូនៗពួកយើងរៀបការមានកូនចៅ ហើយខ្ញុំ សង្ស័យ មានចៅទួតបាត់ហើយ ។

ក្រៅពីរឿងរ៉ាវឈឺចាប់ ទុក្ខវេទនា និងការនិរាសព្រាត់ប្រាស់ ដែលរៀបរាប់ខាងលើ លោក ឆាយ សូផាត ជាមន្ត្រីរាជការមួយរូប ក៏បានចូលរួមរំលឹកនូវព្រឹត្តិការណ៍ល្អៗចាប់ផ្តើមកើតមានជាថ្មី ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ ដោយថ្លែងថា ស្បែអន្ទកាល និងពពកខ្មៅនៅកម្ពុជាចាប់ផ្តើមរសាត់ ខណៈសកម្មភាពសេដ្ឋកិច្ច និងសង្គមដែលបានបំផ្លាញដល់ឫសគល់នៅក្នុងរបបខ្មែរក្រហមចាប់ផ្តើម។

លោកបានបញ្ជាក់ថា "សម័យអន្ធកាលនៃរបបខ្មៅងងឹត មនុស្សរបង់កក្រមាបានបញ្ចប់ ប្រវត្តិសាស្ត្រថ្មី ក៏ចាប់ផ្តើមកើតមាននៅកម្ពុជាចាប់តាំងពីពេលនោះមក។ ខ្ញុំធ្លាប់រកតែខោអាវខ្មៅបំណាស់ស្លៀកមិនបាន ប៉ុន្តែពេលនេះ ម៉ូតអីក៏មានដែរ"។

លោកបានបន្តទៀតថា ពពកខ្មៅក៏ចាប់ផ្តើមរសាត់បន្តិចម្តងៗ ជំនួសដោយពពកពណ៌ផ្ទៃមេឃ ស ប្រផេះ ហើយប្រទេសក៏បានរីកចម្រើនបន្តិចម្តងៗរហូតមកដល់សព្វថ្ងៃ ប៉ុន្តែលោកបានបង្ហាញនូវចម្ងល់មួយ ដែលអ្នកនយោបាយខ្លះចង់ឲ្យកូនខ្មែរបំភ្លេច អ្វីដែលបាន កើតឡើងនៅសម័យនោះទៅវិញ។ លោកបានបន្តថា នេះគឺជារឿងប្រវត្តិសាស្ត្រ ដែលយើងគួរតែចាំ និងគួរតែរំលឹកឲ្យកូនខ្មែរចាំ ដើម្បីទុកជាបទពិសោធ និងជាមេរៀនអំពីសង្គមប្រវត្តិ-សាស្ត្រដើម្បីឲ្យអនាគតសង្គមខ្មែរយើងកាន់តែ រុងរឿង ប៉ុន្តែមិនមែនយើងរុងរឿងហើយភ្លេចរឿងចាស់ ដល់អនាគតវាកើតរឿងឈឺចាប់ រឿងវេទនា រឿងព្រាត់ប្រាស់ជាថ្មីនោះទេ ។

យុវនិស្សិត ជុំ ឧត្តម ដែលមានវ័យ ២០ ឆ្នាំមួយរូប បានបញ្ចេញចំណាប់អារម្មណ៍ថា ប្រវត្តិសាស្ត្រទោះបីជាល្អ ឬអាក្រក់ ដាច់ខាតយើងត្រូវតែដឹង ត្រូវតែស្វ័យសិក្សាពីព្រោះវាសុទ្ធសឹងតែជាចំណេះដឹង និងបទពិសោធន៍ដែលមានប្រយោជន៍សម្រាប់អនាគតជានិច្ច ។

ឧត្តមបានបន្តទៀតថា ដោយសារតែបរិបទសង្គម សេដ្ឋកិច្ច និងនយោបាយកាន់តែទូលំទូលាយ ចំណេះដឹង គឺរឹតតែទាមទារឲ្យទូលំទូលាយ ដូច្នេះក្រៅពីប្រវត្តិសាស្ត្រកម្ពុជាខ្លួនឯង យើងក៏ត្រូវតែឈ្វេងយល់អំពីប្រវត្តិតំបន់ និងសាកលលោកសំខាន់ៗផងដែរ ។

ឧត្តមបានបញ្ជាក់ថា "សម័យនោះ ខ្មែរយើងជួបរបបប្រល័យពូជសាសន៍ ចុះប្រទេសគេ សម័យនោះ យ៉ាងណា ដូច្នេះបើយើងសិក្សា និងស្វែងយល់ យើងអាចដឹងស្រុកគេកាលនោះយ៉ាងម៉េច ហេតុអីបានជាស្រុកគេដល់ប៉ុណ្ណឹង ..." ។ល។

*ដោយ អរិយាបុត្រ*

## ពលរដ្ឋកម្ពុជាទទួលយុត្តិធម៌ខ្លះហើយពីរបបប៉ុលពត

ក្រោយពេលដែលរបបខ្មែរក្រហមបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយត្រូវទម្លាក់ពីអំណាចនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មកដល់ពេលនេះ គេប៉ាន់ប្រមាណថា មានប្រជាជនកម្ពុជាប្រមាណ ១,៧ លាននាក់ បានបាត់បង់ជីវិតនៅរបបនោះ។

ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងសាច់ញាតិ នៅឆ្នាំ១៩៩៧ រាជរដ្ឋា-ភិបាលកម្ពុជាបានសំណូមពរឲ្យអង្គការសហប្រជាជាតិជួយឧបត្ថម្ភបង្កើតសាលាជម្រះក្តី ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបនេះ។ ក្រោយមកអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរបបប៉ុលពត បានបង្កើតឡើង ក្រោយកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា ជាមួយអង្គការសហប្រជាជាតិ នៅខែមិថុនា ឆ្នាំ២០០៣ ។

មកដល់បច្ចុប្បន្ននេះ តុលាការនេះ បានកាត់ទោសរួចហើយ នូវបុគ្គលបីនាក់ គឺ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាមេគុកទួលស្លែង លោក ខៀវ សំផនជាអតីតប្រមុខរដ្ឋ និងលោក នួន ជា ជាអតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យឲ្យជាប់ពន្ធ-នាគារមួយជីវិត។ ដោយឡែកជនជាប់ចោទទី៣ គឺ លោក អៀង សារី អតីត រដ្ឋមន្ត្រីការបរទេសរបស់របបនេះ បានបាត់បង់ជីវិតមុនពេលកាត់ទោស ហើយភរិយារបស់ជនជាប់ ចោទ អៀង ធីរិទ្ធ ត្រូវបានដោះលែងដោយសារតែមានជំងឺ ប៉ុន្តែបានស្លាប់នៅឆ្នាំ២០១៥ ។

អាយុកាលរបស់តុលាកានេះនឹងបន្តរយៈពេល ២ ឆ្នាំទៀត ប៉ុន្តែកំពុងតែស្វែងរកថវិកាដោយរយៈ ពេលពីឆ្នាំ២០១៨ទៅ២០១៩ គឺត្រូវការ ថវិការ ប្រមាណជា ៤៦,១២ លានដុល្លារ ហើយរហូតមក ដល់ពេលនេះ គេដឹងថា សាលាក្តីនេះចាយលុយអស់២៩៣ លានដុល្លារហើយ ដោយលុយពីសហគមន៍អន្តរជាតិចំនួន ២២៤,៣ លានដុល្លា និង ពីជាតិ៦៨,៧ លានដុល្លារ ។

## សមិទ្ធិផលគ្រួសៗ មុនដំណើរការរៀបចំមីទ្ទិញរំលឹកខួបទី៣៩ឆ្នាំ នៃទិវាជ័យជម្នះ ៧ មករា

សេដ្ឋកិច្ច កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ និង វិស័យផ្សេងៗ កំពុងតែស្ថិតនៅក្នុងនិន្នាការរីកចម្រើនប្រកបដោយសុទិដ្ឋិនិយម ។

តាមរបាយការណ៍ដែលព្យាករណ៍ដោយស្ថាប័នហិរញ្ញវត្ថុធំៗ ដូចជាធនាគារពិភពលោកបានអះអាងថា កម្ពុជានៅក្នុងចំណោមប្រទេសដែលកំពុងតែងើបចេញពីខ្សែបន្ទាត់នៃភាពក្រីក្រ ដោយនៅក្នុងឆ្នាំគេព្យាករណ៍ថា សេដ្ឋកិច្ចកម្ពុជានឹងទទួលកំណើន ៦,៨ភាគរយ តែនឹងឡើងដល់ ៦,៩ នៅឆ្នាំ២០១៨។

ដោយឡែកវិស័យកសិកម្មវិញ ក៏ស្ថិតនៅក្នុងនិន្នាការវិជ្ជមាន ដោយក្រសួងកសិកម្ម និងក្រសួងពាណិជ្ជកម្មបានអះអាងថា ទំនិញកសិកម្មរបស់កម្ពុជា ដូចជា អង្កកៅស៊ូ ពោត ដំឡូងមី ផលិតផល នេសាទ ម្រេច គឺកំពុងតែទទួលបានចំណែកទីផ្សារអន្តរជាតិកាន់តែទូលាយ ។

សម្រាប់ឧស្សាហកម្មវិញ មកដល់ពេលនេះ ក្រសួងការងារបានប្រកាសថា កម្ពុជាមានរោងចក្រ និងសហគ្រាសសរុបទាំងអស់ ១១.១៦៨ កន្លែង ដែលផ្តល់ការងារដោយផ្ទាល់ដល់ពលរដ្ឋ ១,២ លាននាក់។

សម្រាប់វិស័យពាណិជ្ជកម្មវិញនាឆ្នាំ២០១៧នេះ ក្រសួងពាណិជ្ជកម្ម បានប្រកាសថាកម្ពុជាបាននាំចេញទំនិញសរុបរហូតដល់ទៅ ៩,៥៥ពាន់លានដុល្លារ ពោល គឺកើនឡើងប្រមាណជាជាង ១៩ ភាគរយបើធៀបនឹងឆ្នាំ២០១៦ ។ ខណៈដែលវិស័យទេសចរណ៍វិញ ក្រសួងបានព្យាករណ៍ថា កម្ពុជាអាចទាក់ទាញបានភ្ញៀវអន្តរជាតិ ៥,៦ លាននាក់ ។

# រីករាយបុណ្យ


ព្រះសហគមន៍កាតូលិក ពាក់ស្មែងចាស់


ព្រះសហគមន៍កាតូលិក ដាក់ដាំមណ្ឌលគិរី ស្ថិតក្នុងព្រះសហគមន៍កាតូលិក ៨ក ភូមិភាគកំពង់ចាម


ព្រះសហគមន៍កាតូលិក ព្រះកុមារយេស៊ូ បឹងទំពុន


ព្រះសហគមន៍កាតូលិក


ព្រះសហគមន៍កាតូលិក ខេត្តព្រះវិហារ



ព្រះសហគមន៍កាតូ


ព្រះសហគមន៍កាតូលិក ព្រះវិហារគ្រួសារដ៏វិសុទ្ធ ព្រៃកក្បួរ ខេត្តកំពង់ធំ

# ព្រះយេស៊ូប្រសូត



ព្រះសហគមន៍កាតូលិក ទំពូង





ព្រះសហគមន៍កាតូលិក ត្រែងត្រយឹង



ន្តីម៉ារី ញញឹម ចំការទៀង



ព្រះសហគមន៍កាតូលិក កោះស្លា ខេត្តកំពត



ព្រះសហគមន៍កាតូលិក ព្រះវិហារ សន្តយ៉ូសែប ផ្សារតូច





លិក បាត់ដំបង



ព្រះសហគមន៍កាតូលិក ព្រះវិហារសន្តសិលា សន្តប៉ូល ភ្នំពេញថ្មី

# ព្រះសហគមន៍កាតូលិកតំបន់កំពតសួរសុខទុក្ខទណ្ឌិតក្នុងពន្ធនាគារ

នៅព្រឹកថ្ងៃទី១២ ខែធ្នូនេះ ព្រះសហគមន៍កាតូលិកតំបន់កំពត បានរៀបចំកម្មវិធីសួរសុខទុក្ខ និងចែកអាហារ ព្រមទាំងសម្ភារៈប្រើប្រាស់ ដល់ទណ្ឌិត និងជនត្រូវចោទក្នុងពន្ធនាគារ ខេត្តកំពត ចំនួនប្រមាណជាង ៧០០ នាក់ ។ ពិធីប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ និងការនិមន្ត និងអញ្ជើញ ចូលរួមពីសំណាក់ តំណាងពុទ្ធសាសនា និងឥស្លាមសាសនា លោកបូជាចារ្យ និងគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។ ជាកិច្ចចាប់ផ្តើមលោក អែម បូរ ប្រធានពន្ធនាគារខេត្តកំពត បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះគណប្រតិភូសាសនាទាំងអស់ដែលបានមកសួរសុខទុក្ខ ដល់បងប្អូនក្នុងពន្ធនាគារនៅថ្ងៃនេះ។ លោកក៏បានណែនាំឲ្យបងប្អូនទាំងអស់យកចិត្តទុកដាក់ស្តាប់ពាក្យប្រៀនប្រដៅពីសាសនាទាំងអស់។

ក្នុងឱកាសដ៏វិសេសវិសាលនេះ លោក យ៉ាំងលូកា ក្នុងនាមជាអ្នករៀបចំកម្មវិធីបានប្រសាសន៍ថា៖ យើងទាំងអស់មានអំណរ ក្នុងឱកាសបុណ្យព្រះយេស៊ូប្រសូត។ យើងមកដើម្បីបង្ហាញ ចែករំលែក ភាពកក់ក្តៅជាមួយបងប្អូន គាំទ្រឲ្យបងប្អូនមានសេចក្តីសង្ឃឹម ក្នុងការខិតខំកែប្រែខ្លួន ជាពលរដ្ឋល្អ ពេលចេញទៅវិញចូលក្នុងសង្គម។ ក្នុងនោះដែរគណម្ចាស់ ចាន់ សុវណ្ណ មេគណ គណៈធម្មយុត្តកត្តនិកាយខេត្តកំពត បានមានថេរដីការ អប់រំរំលឹកដល់បងប្អូនទាំងអស់អំពីសីលប្រាំ ដើម្បីជាការពិចារណាបំភ្លឺផ្លូវជីវិត។

ចំណែកលោក សឹម ឡៃម៉ាណ តំណាងគណអ៊ីមាំ ខេត្តកំពត ក៏បានលើកទឹកចិត្តបងប្អូនកែខ្លួន រៀបចំខ្លួនឲ្យល្អសម្រាប់ជីវិតលោកខាងមុខ។ លោកភិបាលអូលីវីយេជាអធិបតីបានមានប្រសាសន៍ ទៅកាន់បងប្អូនអំពីតួនាទីរបស់សាសនានីមួយៗ។ លោកថា ៖ ពិតមែនសាសនាទាំងអស់ណែនាំជីវិតរបស់យើងម្នាក់ មានពន្លឺ។ លោកបន្តលើកទឹកចិត្តថា ជីវិតរបស់យើងពេលខ្លះស្រស់ស្រាយ ស្រស់បំព្រង ពេលខ្លះក្រៀមស្វិត។ តែកុំអស់សង្ឃឹម! សូមយកពេលពិចារណា សមាធិខ្លះ រិះគិតថា តើពេលចេញទៅខាងក្រៅនឹងធ្វើអ្វី? ត្រូវមានកម្លាំងទៅមុខជានិច្ច។ មនុស្សត្រូវមានសេចក្តីសង្ឃឹម ត្រូវមានពន្លឺជានិច្ច។ ត្រូវខិតខំធ្វើយ៉ាងណា ដើម្បីឲ្យមានជីវិតល្អ។ លោកបន្តថា ពេលចេញទៅវិញ ត្រូវស្រលាញ់គ្រួសា ស្រលាញ់កូន និងជួយឲ្យប្រទេសមានសុខសន្តិភាព និងសេចក្តីសុខ។ បន្ទាប់ពីសំណេះសំណាល់ជាមួយបងប្អូនជាប់ឃុំរួចមក គណប្រតិភូបានអធិដ្ឋា ប្រសិទ្ធពរជ័យតាមជំនឿរៀងៗខ្លួន។

កម្មវិធីបានបញ្ចប់ដោយការចែកម្ហូបអាហារ និងក្តួយដល់បងប្អូនជាប់ឃុំ តាមអាគារនីមួយៗ បងប្អូនទទួលដោយអំណរសប្បាយ។ ព្រះសហគមន៍កាតូលិកតំបន់កំពត តែងរៀបចំការជួបជុំបែបនេះ ជាលក្ខណៈអន្តរសាសនា អស់រយៈពេលប្រមាណជា១០ឆ្នាំមកហើយ។

*ដោយ លី សុវណ្ណា*


photo supply

# ព្រះសហគមន៍មិនអាចឲ្យគូស្វាមីភរិយាលែងលះបានទេ តែមានមោឃភាព


**លោកបូជាចារ្យ រឿង ឆ័ត្តសិរី**

នៅក្នុងសង្គម គេមានការលែងលះគ្នាដែលមានការទទួលស្គាល់ពីច្បាប់ ឬរដ្ឋអំណាច។ ប៉ុន្តែសម្រាប់យើងជាព្រះសហគមន៍កាតូលិកពាក្យលែងលះ យើងមិនអាចប្រើបានទេ។ ហេតុអ្វី? ព្រោះមូលដ្ឋានគ្រឹះនៃការអប់រំណែនាំ ព្រះសហគមន៍យើងក៏មានតាំងពីជំនាន់ព្រះយេស៊ូ ដែលពួកផារីស៊ីបានសួរ។ ព្រះយេស៊ូតបថា "អ្នករាល់គ្នាធ្លាប់អានគម្ពីររួចហើយថា កាលពីដើមដំបូងព្រះអាទិករបានបង្កើតបុរស និងស្ត្រី។ ហេតុនេះហើយទើបបុរសត្រូវចាកចេញពីឪពុកម្តាយទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ។ មនុស្សមិនត្រូវបំបាក់បំបែកគូស្រករដែលព្រះជាម្ចាស់ត្រូវផ្សំផ្គុំនោះឡើយ"។ ហេតុនេះហើយអាពាហ៍ពិពាហ៍ក្នុងព្រះសហគមន៍យើងចាត់ទុកថាជាចំណងដ៏វិសុទ្ធ ដែលកើតឡើងហើយគ្មាន អ្នកណាបំបាក់បំបែកវាបានឡើយ។ ជាពិសេសក្នុងច្បាប់ព្រះសហគមន៍ក៏បានបញ្ជាក់ក្នុងមាត្រា១១៤១ ដែលចែងថា អាពាហ៍ពិពាហ៍ដែលកើតឡើងដោយសច្ចានុម័ត និងពេញលក្ខណៈ។ សច្ចានុម័ត មានន័យថា មានពិធីត្រឹមត្រូវ ស្របតាមច្បាប់ព្រះសហគមន៍ និងពេញលក្ខណៈគឺ មានការរួមដំណេកជាមួយគ្នា ដែលកត្តានេះមិនអាចមានមនុស្សណាអាចផ្តាច់ចំណងនេះបានឡើយ លើកលែងតែសេចក្តីស្លាប់។ ចំណងនេះគេហៅថា ជាចំណងធម្មជាតិ គឺមានទាំងគ្រីស្តបរិស័ទនិងគ្រីស្តបរិស័ទ គ្រីស្តបរិស័ទនិងសាសនាដទៃផងដែរ ដែលយើងមិនអាចបំបែកបំបាក់បានឡើយ។

រីឯគ្រីស្តបរិស័ទនិងគ្រីស្តបរិស័ទដែលមានពិធីជ្រមុជទឹក មានលក្ខណៈពិសេស គឺមិនគ្រាន់តែមានចំណងធម្មជាតិនេះទេ គឺជាចំណងមកពីច្បាប់របស់ព្រះជាម្ចាស់ ដែលក្រោយមកព្រះសហគមន៍បានយកជាច្បាប់មួយរបស់ព្រះសហគមន៍ផ្ទាល់។

**ចំណុចសំខាន់ៗនៃមោឃភាពលើចំណងអាពាហ៍ពិពាហ៍**

ប្រសិនបើចំណងនោះគ្មានឧបសគ្គអ្វីជាមួយគូស្រករទេ ចំណងនោះនៅគង់ លុះត្រាតែយើងមានបញ្ហាអ្វីមួយ។ យើងត្រូវពិនិត្យពិចារណាម្តងទៀត តើចំណងនោះកើតឡើងត្រឹមត្រូវពិតប្រាកដ ឬក៏មានសុពលភាពឬអត់? ហេតុនេះហើយព្រះសហគមន៍ក៏មានផ្លូវមួយជួយដល់គូស្រករ គឺជាចំណុចខ្សោយដែលធ្វើឲ្យអាពាហ៍ពិពាហ៍របស់ពួកគេមិនអាចជាពាហ៍ពិពាហ៍ពេញលក្ខណៈបាន គឺមានឧឧបសគ្គ។ ក្នុងនោះរួមមានចំណុចមួយចំនួនដូចជា ទី១អាពាហ៍ពិពាហ៍នោះ ឆ្លងកាត់ការលើកលែងហើយឬនៅ? ទី២ តើមានការយល់ព្រមទាំងសងខាង( ស្វាមីភរិយា ) គឺចេញដោយចិត្តស្មោះ គឺទាមទារឲ្យបង្ហាញឲ្យស្តែងឃើញជាពាក្យសំដី ឬកាយវិការ និងទី៣ ត្រូវមានទម្រង់ ឬរបៀបដែលប្រារព្ធពិធី តើវាកើតឡើងត្រឹមត្រូវ ឬក៏អត់?។ ក្រៅពីចំណុចទាំងបីខាងលើនេះ គឺយើងត្រូវពិនិត្យលើកត្តាមួយចំនួនទៀតដូចជា៖

១.អសមត្ថភាពផ្លូវភេទមិនអាចបង្កើតកូនបាន

២.ជាទូទៅអាពាហ៍ពិពាហ៍របស់គ្រីស្តបរិស័ទគឺត្រូវរៀបការជាមួយគ្រីស្តបរិស័ទដូចគ្នា។ តែបើគ្រីស្តបរិស័ទជាមួយសាសនាដទៃ គឺត្រូវមានការអនុញ្ញាតពីលោកអភិបាលដោយចាំបាច់។ ប្រសិនបើអត់មានទេ គឺអាពាហ៍ពិពាហ៍នោះមិនស្របច្បាប់ព្រះសហគមន៍ឡើយ។

៣. អាពាហ៍ពិពាហ៍ជាមួយអ្នកដែលមានអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ឬអ្នកថ្វាយពាក្យសច្ចានិរន្តរ៍ ឬជាមួយបងប្អូនជីដូនមួយ

៤. អាយុដែលមានគម្លាតឆ្ងាយពេក

៥.របៀបនៃការប្រារព្ធពិធីនោះ គឺត្រូវមានសាក្សីពីរនាក់ ហើយត្រូវប្រារព្ធនៅក្នុងព្រះវិហារ និងអនុវត្តតាមពិធីបុណ្យរបស់ព្រះសហគមន៍កាតូលិក។

៦. កាបង្ហាញពាក្យសន្យារបស់គូស្វាមីភរិយាត្រូវស្តែងចេញជាពាក្យសំដីផ្ទាល់បើមនុស្សគ អាចមានសរសេរ ឬមានរបៀបផ្សេង ឬប្រសិនបើអត់ចេះភាសាតំបន់យើងត្រូវធ្វើតាមរយៈអ្នកបកប្រែ។

កត្តាទាំងអស់ខាងលើនេះ មួយណាក៏បាន គឺជាចំណុចខ្សោយដែលធ្វើឲ្យអាពាហ៍ពិពាហ៍របស់គូស្វាមីភរិយានេះអាចក្លាយជាមោឃៈបាន។ ប៉ុន្តែព្រះសហគមន៍មិនអនុញ្ញាតឲ្យមានមោឃភាពដោយសាមីខ្លួនបានឡើយ លុះត្រាតែឆ្លងកាត់ប្រព័ន្ធតុលាការរបស់ព្រះសហគមន៍កាតូលិក ដោយមានការស៊ើបអង្កេត និងកាត់សេចក្តីត្រឹមត្រូវ ទើបអាពាហ៍ពិពាហ៍នោះចាត់ទុកថាជាមោឃៈបាន។

# អង្គការការីតាស់កម្ពុជា "ដំណើរនៃមេត្តាករុណា យើងស្រឡាញ់បរិស្ថាន"

អង្គការការីតាស់កម្ពុជា "ដំណើរនៃមេត្តាករុណា យើងស្រឡាញ់បរិស្ថាន" ជាប្រធានបទយ៉ាងសំខាន់ក្នុងការរិះគិត នៅក្នុងការជួបជុំប្រចាំឆ្នាំ លើកទី២៤ របស់អង្គការការីតាស់កម្ពុជា ដែលការជួបជុំនេះ បានប្រព្រឹត្តទៅនៅព្រះវិហារសន្តមីកាអែល ក្នុងព្រះសីហនុ កាលពីថ្ងៃទី០៤ ដល់ថ្ងៃទី០៧ ខែធ្នូនេះ។

មានមតិស្វាគមន៍ក្នុងពេលនោះលោក គីមរតនានាយកប្រតិបត្តិនៃអង្គការការីតាស់កម្ពុជា បានថ្លែងកោតសរសើរដល់សមាជិកនៃអង្គការការីតាស់កម្ពុជា ដែលបានខិតខំបំពេញការងារ និងខិតខំបង្ហាញមេត្តាករុណា គឺបំពេញកិច្ចការប្រកបដោយមេត្តាករុណា។ លោកថា ការីតាស់មានន័យថា "មេត្តាករុណា"។ យើងធ្លាប់ធ្វើសកម្មភាពមេត្តាករុណា ហើយបងប្អូនចូលរួមជាមួយការីតាស់ ដើម្បីធ្វើសកម្មភាពមេត្តាករុណា..។

លោកបន្តថា យកពេលនេះចូលរួមជាមួយការីតាស់ មិនត្រឹមតែសកម្មភាពនេះ តែសូមចូលរស់នៅក្នុងមេត្តាករុណា។ អរគុណបងប្អូនដែលចូលរួម ។

លោកបន្តថា ក្នុងរយៈពេលប៉ុន្មានថ្ងៃក្នុងពេលយើងជួបជុំគ្នានេះ យើងបន្តរិះគិត តើត្រូវរស់នៅក្នុងសេចក្តីមេត្តាករុណាយ៉ាងដូចម្តេចទៀត? លោកថា ជាការពិតណាស់បងប្អូនវវល់ ក្នុងកិច្ចការចិញ្ចឹមជីវិត យើងព្រួយបារម្មណ៍អំពីជីវភាពរបស់ខ្លួន។ ខិតខំធ្វើយ៉ាងណាដើម្បីឲ្យការរស់នៅរបស់ខ្លួនពោរពេញដោយសុភមង្គល។ តើយើងរស់នៅ ដោយសុភមង្គលក្នុងគ្រួសាររបស់ខ្លួនស្រួលយ៉ាងដូចម្តេច បើបងប្អូនយើងជាច្រើនទៀត ត្រូវរស់ក្នុងភាពឈឺចាប់ វេទនាខ្លោចផ្សានោះ? លោកសូមឲ្យសមាជិកការីតាស់ទាំងអស់យកចិត្តទុកដាក់ជាមួយបងប្អូនឯទៀតៗដែលទន់ខ្សោយ និងងាយរងគ្រោះធ្វើដំណើរទៅមុខទាំងអស់គ្នា។

កិច្ចការមេត្តាករុណាមិនមែនគ្រាន់តែធ្វើកិច្ចការចំពោះតែមនុស្សដោយផ្ទាល់នោះទេ គឺស្រឡាញ់ថែទាំបរិស្ថានក៏ជាកិច្ចការមួយដ៏សំខាន់ដែរក្នុងការបង្ហាញមេត្តា-ករុណា។

លោកអភិបាលគីគេ ហ្វីការេដូ ប្រធានក្រុមប្រឹក្សាភិបាលអង្គការការីតាស់កម្ពុជាបាន លើកទឹកចិត្តអ្នកចូលរួមក្នុងអង្គប្រជុំទាំងអស់ត្រូវស្រឡាញ់បរិស្ថាន ប្តូរទម្លាប់នៃការរស់នៅរបស់ខ្លួន ដោយយកចិត្តទុកដាក់មានចិត្តការពារថែរក្សា និងស្រឡាញ់បរិស្ថាន។ ដោយចាប់ផ្តើមពីខ្លួនយើង គ្រួសារ...។ ដើម្បីដល់ដំណាក់កាលនេះត្រូវការពេល។ យើងត្រូវបង្កើតទម្លាប់កែរបៀបយើងរស់នៅ។ សូមបន្ថយការប្រើទូរស័ព្ទខ្លះ ម៉ាស៊ីនត្រជាក់ខ្លះ។

អង្គប្រជុំក៏បានសិក្សាឈ្វេងយល់អំពីការថែទាំបរិស្ថាន ដែលធ្វើបទបង្ហាញដោយលោកបូជាចារ្យ កាព្រីអែល ជាប្រធានទទួលខុសត្រូវផ្នែកបរិស្ថាននៃអង្គការមេត្តាករុណាកម្ពុជា។

ក្នុងបទបង្ហាញលោកបានបង្ហាញ ពីផលប៉ះពាល់នានាដែលបង្កឡើងដោយមនុស្សចំពោះបរិស្ថានធម្មជាតិ។ ផលប៉ះពាល់ពីការប្រើប្រាស់ថង់ផ្លាស្ទិក បំពង់បឺតជ័រជាដើម។ លោកបានលើកទឹកចិត្តដល់ អ្នកចូលរួមទាំងអស់ឲ្យយកចិត្តទុកដាក់ និងកាត់បន្ថយ ឈប់ប្រើរបស់ទាំងនោះ។ អាចធ្វើការកែច្នៃប្រើប្រាស់ឡើងវិញជាដើម។

ក្នុងនោះដែរលោកបូជាចារ្យ កាព្រីអែល ក៏បានបង្ហាញនូវចំណុចមួយចំនួន ក្នុងលិខិតរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ដែលមានចំណងជើងថា "ឡូដាតូស៊ី" ដែលបានណែនាំឲ្យយកចិត្តទុកដាក់ និងថែរក្សាបរិស្ថានធម្មជាតិ។ ខ្លឹមសារដូចជា៖

រុក្ខជាតិ សត្វ និងអ្វីៗទាំងអស់ ដែលព្រះ-ជាម្ចាស់បានបង្កើតមក វាមានតម្លៃ ឯក-រាជ្យរបស់វា។ ហើយវាមានតម្លៃ ព្រោះព្រះ-ជាម្ចាស់បង្កើត ដោយសេចក្តីស្រលាញ់។ យើងត្រូវតែយកពេលវេលាខ្លះគយគន់សោភ័ណ ដែលនៅជុំវិញខ្លួនយើង។ កត្តាមួយយើងគួរធ្វើ គឺឆ្ពោះទៅកាន់ស្នាព្រះហស្តព្រះជាម្ចាស់ ដោយគ្មានការភ័យខ្លាចឬការគាបសង្កត់ ប៉ុន្តែជាការដឹងគុណ។ យើងត្រូវយល់ថា ពិភពលោក និងអ្វីៗទាំងអស់នេះ ជាអំណោយទានរបស់ព្រះជាម្ចាស់សម្រាប់យើងទាំងអស់គ្នា។ សូមពិនិត្យមើលវប្បធម៌ទំនើប និងកុំឆាប់ទទួលយកអ្វី ដែលអ្នកមើលឃើញនៅក្នុងសង្គមថាល្អ និងសូមពិនិត្យមើលបែបផែននៃជីវិតរស់នៅផ្ទាល់ខ្លួន។ តើរបៀបអ្នកធ្វើ បានប៉ះពាល់ដល់បរិស្ថានឬអ្នកដទៃដែរទេ?

ការជួប ឈ្វេងយល់ ដើម្បីទទួលចំណេះពិតជាមានសារៈសំខាន់។ ប៉ុន្តែដើម្បីឲ្យមេរៀនដែលទទួលកាន់តែមានប្រសិទ្ធភាព អង្គការការីតាស់បានរៀបចំកម្មវិធីជាមួយនាយកសាលាបឋមសិក្សាមួយក្នុងស្រុកព្រៃនប់ ដើម្បីអនុវត្តន៍កម្មវិធីសាលាបៃតង ដោយមានការដាំកូនឈើ និងចែកសម្ភារសិក្សាដល់សិស្សានុសិស្ស ព្រមទាំងជួយពិនិត្យភ្នែកជូនដោយឥតបង់ថ្លៃផងដែរ។ ថ្ងៃបន្ទាប់ក៏មានកម្មវិធីដាំកូនដើមកោងកាងរួមគ្នានៅក្នុងស្រុកព្រៃនប់។

កម្មវិធីជួបជុំនេះបានបញ្ចប់ដោយការប្រារព្ធបុណ្យអបអរសាទរព្រះយេស៊ូប្រសូតដោយមានជប់លៀង ចែកអំណោយគ្នាចែកអំណរសប្បាយទៅវិញទៅមកប្រកបដោយភក្តីភាព មិត្តភាពក្នុងភាពស្និទ្ធស្នាលជាបងប្អូន។

*ដោយ លី សុវណ្ណា*







ថតដោយ សម្បត្តិ

# និស្សិតវិទ្យាស្ថានសន្តប៉ូលទទួលសញ្ញាបត្របញ្ចប់ការសិក្សា



ថតដោយ លី សុវណ្ណា

និស្សិតនៃវិស្ថានសន្តប៉ូល ចំនួន៧៥ នាក់បានបញ្ចប់ការសិក្សាដោយជោគជ័យ និងបានទទួលសញ្ញាប័ត្របរិញ្ញាបត្រ គ្រប់ៗគ្នា នាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៧ នេះ ក្រោមអធិបតីភាព របស់ឯកឧត្តម តុប សុភ័ក្ត្រ អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ លោកអូលីវីយេ ដ្មីតហាស្ល៊េរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានសន្តប៉ូល និងមានការចូលរួមពីសំណាក់ មន្ត្រីរដ្ឋរាជការ គណៈគ្រប់គ្រងវិទ្យាល័យ សាស្ត្រាចារ្យ អាណាព្យាបាល ព្រមទាំងនិស្សិតនៃវិទ្យាស្ថានសន្តប៉ូលជាច្រើនរូប។

និស្សិតចំនួន ៧៥រូប ដែលទទួលបរិញ្ញាបត្រនាពេលនេះ មានបរិញ្ញាបត្រក្សេត្រសាស្ត្រជំនាន់ទី២ បរិញ្ញាបត្រភាសាអង់គ្លេស បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ជំនាន់ទី៣ និងបរិញ្ញាបត្រព័ត៌មានវិទ្យាជំនាន់ទី៤។

តាមរបាយការណ៍របស់លោក ផុន សុផល នាយកនៃវិទ្យាស្ថានសន្តប៉ូលបានឲ្យដឹងថា វិទ្យាស្ថានបាននឹងកំពុងបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រចំនួន៥ មានដូចជា ថ្នាក់បរិញ្ញាបត្រព័ត៌មានវិទ្យា ថ្នាក់បរិញ្ញាបត្រក្សេត្រសាស្ត្រ ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងថ្នាក់បរិញ្ញាបត្រសង្គមកិច្ច។ និងបរិញ្ញាបត្ររងចំនួន៧ លើជំនាញ ប្រព័ន្ធកសិកម្មចម្រុះ សណ្ឋាគារនិងបដិសណ្ឋារកិច្ច ភាសាអង់គ្លេស គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យុទ័រ អភិវឌ្ឍន៍កម្មវិធីកុំព្យុទ័រ។

បច្ចុប្បន្ននេះមាននិស្សិតសិក្សាចំនួន ២៧៧នាក់ ក្នុងនោះថ្នាក់បរិញ្ញាបត្ររងចំនួន ៣៨នាក់។ លោកនាយក ផុន សុផល បានលើកឡើងទៀតថា វិទ្យាស្ថានបានផ្តល់ប្រយោជន៍ជាច្រើនជូននិស្សិត ដូចជា អន្តេវាសិកដ្ឋានសម្រាប់និស្សិតស្រីប្រុស អាហារដ្ឋានតម្លៃទាបជាងទីផ្សារ កម្មវិធីចុះកម្មសិក្សានៅសាកលវិទ្យាល័យដៃគូរបស់វិទ្យាស្ថានជាដើម។

ក្នុងនោះរួមមានសកលវិទ្យាល័យអន្តរជាតិចំនួន១០ គឺ សកលវិទ្យាល័យ នៅប្រទេសអ៊ីតាលី ប្រទេសកូរ៉េ ប្រទេសអូស្ត្រាលី ប្រទេសតង់ហ្សានី ប្រទេសហ្វីលីភីន ប្រទេសឥណ្ឌូនេស៊ី ប្រទេសថៃ ប្រទេសស៊ីងហ្គាពួរ និងជាមួយអង្គការយូណេស្កូទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស ហើយ និងសកលវិទ្យាល័យភូមិមិន្ទកសិកម្ម ដែលស្ថិតនៅក្នុងប្រទេសជាដើម។

លោកអភិបាលអូលីវីយេ ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថានសន្តប៉ូល បានអបអរសាទរចំពោះ និស្សិតទាំង ៧៥រូប ដែលទទួលបរិញ្ញាបត្រនៅថ្ងៃនេះ។ ក្នុងនោះដែរលោកអភិបាលក៏បានបង្ហាញ អំពីផែនការ នៃការវិទ្យាល័យឯកទេសសន្តហ្វ្រង់ស្វ័រ ដែលមានមុខជំនាញកសិកម្ម និងទេសចរណ៍។ លោកក៏បានលើកទឹកចិត្ត ឲ្យនិស្សិតចូលរួមបង្រៀននៅវិទ្យាល័យនេះ នូវជំនាញដែលគេបានរៀនដើម្បីហាត់ការផងដែរ។ លោកអភិបាលក៏បានបង្ហាញអំពីគម្រោង បង្កើតតំបន់អេកូទេសចរណ៍ នៅក្នុងខេត្តតាកែវនេះ គឺក្នុងស្រុងត្រាំកក់ ដែលនៅតាមបណ្តោយផ្លូវ ជាតិលេខ៣ គឺនៅក្នុងឃុំគុស ដែលមានរោងសិប្បកម្ម កែច្នៃម្ហូបអាហារ សិប្បកម្មតប្បាញ មានសាលមហាស្រពដ៏ធំដើម្បីសម្តែងសិល្បៈ តាមទម្រង់ផ្សេងៗមានល្ខោនបាសាក់ យីកេ របាំបូរាណ របាំប្រពៃណី របាំប្រជាប្រិយជាដើម ជូនភ្ញៀវ ដែលមកទស្សនា។ លោកថា លោកក៏បានកសាង សាលាបង្រៀនរបាំផងដែរ។ កន្លែងទាំងនេះ គឺត្រូវការកំលាំងចូលរួមរបស់និស្សិតគ្រប់ផ្នែក ដើម្បីបម្រើសេវាកម្មជូនភ្ញៀវ។ នៅក្នុងវិទ្យាល័យឯកទេស សន្តហ្វ្រង់ស្វ័រ នឹងសាងកន្លែងទទួលភ្ញៀវស្នាក់នៅ និងមានបើកភោជនីយដ្ឋានដើម្បីអាចសិស្សអនុវត្ត។ លោកបន្តថា ក្រៅពីនៅក្នុងខេត្តតាកែវក៏មាននៅភ្នំវល្លិ៍ក្នុងខេត្តកែបក៏ជាកន្លែងដែលពោរពេញ ដោយសក្តានុពលក្នុងវិស័យអេកូទេសចរណ៍នេះដែរ។ ព្រោះលោកបានបង្កើតកសិដ្ឋានមួយយ៉ាងធំលើផ្ទៃដី ៧០ហិតា ដោយមានកសិកម្មចម្រុះដូចជា គោ ជ្រូក ពពែ ដំណាំហូបផ្លែច្រើនមុខ ម្រេច ពោត។ល។ ទីនោះជាទីកន្លែងសម្រាប់និស្សិតអនុវត្តន៍ និងទទួលភ្ញៀវទេសចរណ៍ផងដែរ។

ក្រោយបានស្តាប់របាយការណ៍ និងផែនការណ៍នេះរួច លោក តុប សុភ័ក្ត្រ អនុរដ្ឋលេខាធិការក្រសួងទេសចណ៍ បានកោតសរសើរ និងគាំទ្រយ៉ាងពេញទំហឹងលើគម្រោងទាំងនេះនិងសូមលោកអភិបាលចុះបញ្ជីតាមលក្ខណៈច្បាប់ដើម្បីឲ្យផែនការទាំងនេះដំណើរការទៅដោយរលូន និងស្របច្បាប់។ លោកក៏បានអបអរសាទរនិងស្នាដៃជាច្រើនដែលវិទ្យាស្ថានសន្តប៉ូលចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ និងបណ្តុះបណ្តាលធនធានមនុស្សដើម្បអភិវឌ្ឍកម្ពុជាឲ្យចម្រើនឡើង។ ជាក់ស្តែងលោកលើកឡើងថា ទីតាំងរបស់វិទ្យាស្ថានសន្តប៉ូលដើមឡើយ ជាវាលស្រែសម្រាប់បង្កបង្កើនផលស្រូវ តែពេលនេះវាលស្រែសម្រាប់បណ្តុះបណ្តាលធនធានមនុស្សវិញ។ ក្នុងឱកាសនោះលោកក៏កោតសរសើរ ដល់និស្សិតជ័យលាភី និងបានផ្តាំផ្ញើសម្រាប់និស្សិតថ្មីឲ្យយកចិត្តទុកដាក់ក្នុងការសិក្សាដើម្បីទទួលបានអនាគតដ៏ល្អត្រចង់។

បន្ទាប់មកគណៈអធិបតីក៏ចែកសញ្ញាបត្រដល់និស្សិតទាំអស់ និងបានអញ្ជើញទស្សនាការតាំងបង្ហាញនូវស្នាដៃកែច្នៃរបស់សិស្សវិទ្យាល័យឯកទេស ស្នាដៃសិល្បៈនៃក្រុមសិល្បៈ ដែលមានវេទិកាសម្តែងយ៉ាងធំមួយ និងផលិតផលនានាដែលចេញពីសិប្បិកម្ម នៃគម្រោងអេកូទេសចរណ៍ភូមិចំការទៀង។

*ដោយ លី សុវណ្ណា*

# លោកអភិបាលអូលីវីយេ "ការិយាល័យនីមួយៗធ្វើឲ្យមានជីវិតរស់រវើក ក្នុងព្រះសហគមន៍"

លោកអូលីវីយេ ជ្មីតហាស្លែរ អភិបាលព្រះសហគមន៍ភូមភាគភ្នំពេញ មានប្រសាសន៍ទៅកាន់ បុគ្គលិកនៃការិយាល័យនានានៃព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ ក្នុងពិធីប្រារព្ធបុណ្យព្រះយេស៊ូប្រសូតសម្រាប់អ្នកបម្រើការតាមការិយាល័យនានា កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧។

តាមកម្មវិធីដែលបានគ្រោងទុក គឺចាប់ផ្ដើមអង្គប្រជុំដើម្បីស្ដាប់យោបល់ និងអនុសាសន៍នានាពីលោកអភិបាល ដែលការិយាល័យនីមួយៗត្រូវបំពេញ ព្រមទាំងព័ត៌មានអំពីព្រឹត្តិការណ៍ធំៗមួយចំនួនដែលនឹងកើតមានតាម គម្រោងការណ៍របស់ព្រះសហគមន៍ភូមិភាគភ្នំពេញក្នុងឆ្នាំ២០១៨ ដែលព្រះសហគមន៍បានកំណត់ជា "ឆ្នាំនៃគ្រួសារ"។

នៅក្នុងពេលជួបជុំនោះ លោកអភិបាលក៏បានរំឭកដល់ប្រធាននៃការិយាល័យទាំងអស់ឲ្យយកចិត្តទុកដាក់អនុវត្តន៍តាមផែន-ការសកម្មភាពរបស់ខ្លួន និងត្រូវរៀបចំផែនការសកម្មភាពក្នុងឆ្នាំនីមួយៗ ព្រមទាំងគម្រោងថវិការផងដែរ។ ជាងនេះត្រូវយកចិត្តទុកដាក់ធ្វើរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុ ប្រចាំខែ ប្រចាំឆ្នាំ ជូនទៅការិយាល័យភូមិភាគឲ្យបានជាប្រចាំ។

លោកអភិបាលព្រះសហគមន៍កាតូលិកអូលីវីយេ ក៏បានបង្ហាញនូវមោទនភាពចំពោះផលផ្លែជាច្រើនដែលការិយាល័យនានា ក្នុងភូមិភាគភ្នំពេញបានបំពេញ។ លោកថា "ការិយាល័យនីមួយៗធ្វើឲ្យមានជីវិតរស់រវើក ក្នុងព្រះសហគមន៍"។

ក្នុងពេលនោះដែរលោកអភិបាលក៏បានរំឭកដល់ប្រសាសន៍របស់សម្ដេចប៉ាដែលបានមានប្រសាសន៍ក្នុងដំណើរទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសបង់ក្លាដែស ចំនួនបីចំណុចដើម្បីអប់រំដល់អ្នកចូលរួមទាំងអស់ គឺទីមួយ "ខ្ញុំជាពន្លក...ព្រះជាម្ចាស់បានសាបព្រោះ គ្រាប់ពូជហើយណែនាំឲ្យគ្រាប់ពូជនោះរីកចម្រើនឡើង.....ខ្ញុំត្រូវការស្រោចទឹកគ្រាប់ពូជនោះ! ដោយយកចិត្តទុកដាក់ថែរក្សាគ្រាប់ពូជនោះ ដោយថ្នាក់ថ្នម បម្រើគ្នាទៅវិញទៅមក! អធិដ្ឋាន! ការយល់ចិត្ត"។ ទីពីរ គឺ "ថែរក្សាសុខដុមរមនា ជៀសវាងការបែកបាក់។ សត្រូវនៃសុខដុមរមនាគឺការនិយាយដើមគ្នា"។ ទីបី គឺ "ថែរក្សាអំណរសប្បាយ"។

ជាពិសេសលោកអភិបាលលើកទឹកចិត្តសហការីទាំងអស់ថា "ចូរមានភាពរឹងមាំនៅក្នុងសេចក្ដីសង្ឃឹម"។

បន្ទាប់ពីបានស្ដាប់ អនុសាសន៍នានារបស់លោកអភិបាលអូលីវីយេរួចមក លោកវិជ្ជបណ្ឌិត ជួង សារឿន អ្នកសម្របសម្រួលគណកម្មការសុខភាព តំណាងការិយាល័យទាំងអស់ បានថ្លែងអំណរគុណលោកអភិបាលអូលីវីយេដែលតែងយកចិត្តទុកដាក់ សម្របសម្រួល លើកទឹកចិត្ត ណែនាំ ដឹកនាំ ដល់គ្រប់ការិយាល័យទាំងអស់ឲ្យបានដើរទៅមុខ ស្របតាមគម្រោងការព្រះសហគមន៍ ក្នុងការបម្រើបងប្អូន និងប្រកាសដំណឹងល្អ។លោកថាគ្រប់ការិយា-ល័យទាំងអស់ប្ដេជ្ញាចិត្តខិតខំបំពេញការ-ងារតាមអនុសាសន៍ របស់លោកអភិបាលឲ្យបានសម្រេច។

ក្រោយពេលអង្គប្រជុំចប់ កម្មវិធីក៏បន្តដោយពិធីអរព្រះគុណព្រះជាម្ចាស់អបអរ-សាទរបុណ្យព្រះយេស៊ូប្រសូត។

ក្នុងធម្មទេសនាលោកអភិបាលក៏មានប្រសាសន៍ថែមទៀតដល់បងប្អូនចូលរួមថា "ចូរកុំធ្វើជាឧបសគ្គនៃការសង្គ្រោះ តែត្រូវធ្វើជាឧបករណ៍នៃការសង្គ្រោះ"។

ពិធីអរព្រះគុណបានបញ្ចប់ ដោយការដង្ហែរូបសំណាក់ព្រះកុមារយេស៊ូ ចូលក្នុងរូងភ្នំពេញដែលបានរៀបចំតុបតែងយ៉ាងស្អាត ដោយភ្លើងចំរុះពណ៌។ កម្មវិធីបានបន្តដោយការចែកវត្ថុអនុស្សាវរីយ៍ ដល់កុមារបុគ្គលិកទាំងអស់ និងទទួលទានអាហារសាមគ្គីក្នុងបរិយាកាសយ៉ាងសប្បាយរីករាយ និងស្និតស្នាលជាទីបំផុត។

ការិយាល័យក្នុងភូមិភាគភ្នំពេញមានដូចជា ការិយាល័យលោកអភិបាល សហ-គ្រិនភាពសង្គមភូមិភាគភ្នំពេញ ការិយា-ល័យយុវជន កុមារ និងជំទង់ ការិយាល័យសិល្បៈនិងរបាំ គណៈកម្មការពលករ គណៈកម្មការសុខភាព ការិយាល័យអប់រំជំនឿ គណៈកម្មការព្រះគម្ពីរ ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក ក្រុមទទួលស្វាគមន៍នៅភ្នំពេញថ្មី និងការិយាល័យសម្រាប់ការសិក្សាអប់រំ។



ថតដោយ សុធិរិទ្ធ

*ដោយ លី សុវណ្ណា*



សន្ដី ល្វីស ដឺ ម៉ារីយ៉ាក

នាងល្វីសកើតនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៥៩១។ ក្រោយពីបានរៀបការអស់រយៈពេល ១៣ឆ្នាំ ប្ដីនាងបានទទួលមរណភាព។ នាងក្លាយទៅជាស្ត្រីមេម៉ាយម្នាក់ ដែលមាន កូនប្រុសម្នាក់។ សន្ដៈ វ៉ាំងសង នៅប៉ូល ជួយណែនាំនាងល្វីសខាងផ្លូវវិញ្ញាណ។ គាត់ប្រមូលក្រុមបុរស និងស្ត្រី ដើម្បីជួយអ្នកក្រីក្រ និងអ្នកជំងឺនៅក្នុងព្រះសហគមន៍នីមួយៗ។ ដោយមាននាងល្វីសជួយជ្រុំជ្រែង គាត់បង្កើតក្រុមគ្រួសារបងស្រីនៃធម៌ មេត្តាករុណា ដើម្បីជួយអ្នកក្រីក្រ និងអ្នកជំងឺ។ នាងមានទំនាក់ទំនងជាមួយស្ត្រីអភិជន ជាច្រើននាក់ ហើយនឹងជាមួយរដ្ឋាភិបាល ដើម្បីជួយឧបត្ថម្ភក្រុមទាំងអស់នោះ។ នាងល្វីសមានសុខភាពមិនសូវល្អប៉ុន្មានទេ តែនាងធ្វើការយ៉ាងធ្ងន់ធ្ងរ ដើម្បីជួយអ្នកក្រីក្រ និងអ្នកជំងឺ។ នាងជានារីម្នាក់ពោរពេញដោយសេចក្ដីស្រឡាញ់ និងសុភាពរាបសា។ នាងមានប្រសាសន៍ទៅកាន់ក្រុមបងស្រីថា៖ ចូរមានចិត្តខ្នះខ្នែងពេលបម្រើអ្នកក្រីក្រ។ ចូរស្រឡាញ់ និងលើកទឹកចិត្តគេ ដូចជាព្រះយេស៊ូផ្ទាល់ខ្លួន។ នាងល្វីសទទួលមរណភាពនៅឆ្នាំ១៦៦០។ ក្រុមបព្វជិតានាងជាក្រុមដ៏ធំមួយនៅក្នុងព្រះសហគមន៍កាតូលិក។

# ពិធីបុណ្យឆ្លងព្រះវិហារ សន្តប៉ូល ស្ថិតក្នុងឃុំស្ទឹង ខេត្តបាត់ដំបង

គ្រីស្តបរិស័ទយ៉ាងច្រើនកុះករមកពីព្រះសហគមន៍នានាក្នុងភូមិភាគបាត់ដំបង បានជួបជុំគ្នាក្នុងពិធីបុណ្យឆ្លងព្រះវិហារសន្តប៉ូល ស្ថិតក្នុងឃុំស្ទឹង ខេត្តបាត់ដំបង កាលពីថ្ងៃទី៨ ធ្នូ ២០១៧។ ពិធីបុណ្យប្រារព្ធទៅក្រោមអធិបតីលោក គីគេ ហ្វីការេដូ អភិបាលនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង រួមជាមួយបូជាចារ្យយ៉ាងច្រើនកុះករ។

ព្រះសហគមន៍កាតូលិកស្ទឹងបានចាប់កើតឡើងក្នុងឆ្នាំ២០០៥ដោយមានគ្រួសារគ្រីស្តបរិស័ទមួយចំនួននៅទីនោះ ដែលបានឆ្ងាយពីព្រះសហគមន៍តាំងពីសម័យសង្គ្រាមស៊ីវិលបានកើតមានក្នុងតំបន់បាត់ដំបង។ ក្រោយមកមានបងប្អូនពេញវ័យ និងយុវជនមួយចំនួនបានចាប់អារម្មណ៍រៀនអប់រំជំនឿ ប៉ុន្មានឆ្នាំក្រោយមកក៏បាន ទទួលអគ្គសញ្ញាជ្រមុជទឹកក្លាយជាគ្រីស្តបរិស័ទ ដោយមានលោកបូជាចារ្យទម្លាប់ សុផលជាបូជាចារ្យទទួលខុសត្រូវ។ ក្នុងឆ្នាំ២០១៥ លោកបូជាចារ្យទម្លាប់សុផល ត្រូវបានផ្លាស់ប្តូរជំនួសដោយបូជាចារ្យថ្មី គឺលោកបូជាចារ្យម៉ូង រស់។ ក្នុងដំណាក់កាលដែលលោកម៉ូង រស់ ទទួលខុសត្រូវព្រះសហគមន៍នេះមានភ័ព្វសំណាង ទទួលបានការគាំទ្រ និងផ្តល់ថវិកាសាងសង់ព្រះវិហារដោយសប្បុរសជនជាតិកូរ៉េ គឺលោកម៉ាកុស អាន។ លោកម៉ាកុស អានបានជួយកសាងព្រះវិហារថ្មីចំនួន២រួចមកហើយនៅក្នុងភូមិភាគបាត់ដំបង គឺព្រះវិហារសន្តីម៉ារីម៉ាដាឡា នៅប៉ោយប៉ែត និងព្រះវិហារសន្តអន់ ដ្រេ នៅព្រះសហគមន៍និគមន៍ ហើយព្រះវិហារសន្តប៉ូលគឺជាព្រះវិហារទីបី។

មានប្រសាសន៍ក្នុងធម្មទេសនា លោកគីគេ ហ្វីការេដូ បានរំឭកដល់លោកម៉ាកុស អាន ដែលជាអ្នកផ្តល់បច្ច័យកសាងព្រះវិហារ ទោះបីលោកមិនបានមកតែលោករួមចិត្តអធិដ្ឋានជាមួយទាំងអស់គ្នា។ ដោយសារថ្ងៃបុណ្យឆ្លងនេះត្រូវនឹងថ្ងៃបុណ្យព្រះនាងម៉ារីគ្មានជំពាក់បាប លោកអភិបាលបានដាស់តឿនបងប្អូនឲ្យយកចិត្តទុកដាក់ស្តាប់ព្រះបន្ទូលព្រះជាម្ចាស់ ដោយអធិដ្ឋានយកពេលវេលានៅជាមួយព្រះជាម្ចាស់។ យកគំរូតាមព្រះនាងម៉ារី ព្រោះព្រះនាងម៉ារីពោរពេញដោយជំនឿ មានចិត្តសុភាពរាបសា ដាក់ខ្លួនបម្រើ និងសាមញ្ញរហូត។ និងចុងក្រោយលោករំឭកឲ្យគ្រីស្តបរិស័ទទាំងអស់ ចេះកែប្រែចិត្តគំនិតដូចសន្តប៉ូលហ៊ានទទួលខុសត្រូវ លោកថា"ធ្វើខុស ត្រូវចេះហ៊ានទទួលកែ មកធ្វើត្រូវវិញ។ សូមឲ្យយើងចេះកែ គឺកែប្រែចិត្តគំនិតធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់"។

ក្នុងឱកាសនោះដែរ លោកម៉ូងរស់ ជាបូជាចារ្យ ទទួលបន្ទុកព្រះសហគមន៍សន្តប៉ូល ស្ទឹង បានមានប្រសាសន៍ យើងមានព្រះវិហារថ្មីបង្ហាញថា យើងមានទីកន្លែងច្បាស់លាស់ ដើម្បីប្រកាសជំនឿរបស់យើង។ អាចធ្វើសកម្មភាពអប់រំជំនឿដល់យុវជននិងកុមារ ជួយបញ្ចូនបន្តជំនឿដល់គេ និងបងប្អូនដែលមិនស្គាល់ព្រះយេស៊ូ ឲ្យគេបានឃើញវត្តមានរបស់ព្រះយេស៊ូ។ លោកបន្ត "ខ្ញុំពិតជាមានអំណរសប្បាយ ដែលមានព្រះវិហារថ្មី។ ពិតមែនអ្វីដែលយើងធ្វើ យើងនឹងអធិដ្ឋានអ្វីដែលយើងធ្វើ យើងនឹងធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គ ហើយដោយសារព្រះអង្គយើងចង់ធ្វើកិច្ចការទាំងនោះ"។ លោកបានសូមឲ្យបងប្អូនបន្តអធិដ្ឋានសម្រាប់បេសកកម្មរបស់ ព្រះសហគមន៍ថ្មីនេះ ដើម្បីអាចនិយាយអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយសមរម្យទៅកាន់បងប្អូនឯទៀតៗ និងសូមឲ្យព្រះសហគមន៍នៅទីនេះបានរីកចម្រើនផង។



ថតដោយ ឫទ្ធិ រដ្ឋ

ព្រះសហគមន៍សន្តប៉ូល ស្ទឹងមានគ្រីស្តបរិស័ទ៦០នាក់ តែសព្វថ្ងៃមានតែ១០នាក់មកជាប់លាប់ ព្រោះពួកគេបានធ្វើចំណាកស្រុកទៅប្រទេសថៃ និងមានយុវជនព្រមទាំងជំទង់ ចំនួន១៥ ទៅ២០នាក់ ។ ក្នុងនោះព្រះសហគមន៍ក៏មានសាលាមត្តេយ្យសម្រាប់អប់រំកុមារតូចផងដែរ។

ដោយ លី សុវណ្ណា

# លោកអភិបាលអូលីវីយេ ជំរុញឲ្យមាតាបិតាយកចិត្តទុកដាក់ចំពោះបុត្រធីតា



ថតដោយ លីហៀង

នៅក្នុងពិធីបុណ្យគោរពព្រះនាងម៉ារីមិនជំពាក់បាប និងអធិដ្ឋានពេញមួយយប់ដើម្បីការត្រាស់ហៅលើកទី៦៦នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ នៅព្រះវិហារសន្តយ៉ូសែប មណ្ឌលសកម្មភាពភ្នំពេញខាងជើង កាលពីថ្ងៃទី៧ ធ្នូ ២០១៧ នេះ លោកអភិបាលអូលីវីយេ បានជំរុញដល់មាតាបិតាទាំងអស់ឲ្យយកចិត្តទុកដាក់ចំពោះបុត្រធីតារបស់ខ្លួន នៅចំពោះមុខគ្រីស្តបរិស័ទជាច្រើនរយនាក់ដែលបានចូលរួមជាច្រើនរយនាក់។

នៅក្នុងធម្មទេសនានៃកម្មវិធីបុណ្យខាងលើ លោកអភិបាលអូលីវីយេ បានណែនាំគ្រីស្តបរិស័ទដោយមានប្រសាសន៍ដូច្នេះថា "សូមឪពុកម្តាយធ្វើយ៉ាងម៉េច ដើម្បីឲ្យកូនស្គាល់ព្រះជាម្ចាស់ និងស្រឡាញ់ព្រះជាម្ចាស់" ដោយលើកយកគំរូរបស់លោកយ៉ាយហាណា និងលោកតាគីមដែលជាឪពុកម្តាយរបស់ព្រះនាងម៉ារី និងឪពុកម្តាយរបស់សន្តីតេរេសា ដែលបានរៀបចំកន្លែងទុកសម្រាប់កូននៅស្ថានបរមសុខ។ លោកអភិបាលបានទទូចឲ្យគ្រីស្តបរិស័ទយកគំរូតាមក្រុមគ្រួសាររបស់ព្រះយេស៊ូផ្ទាល់គឺ យកចិត្តទុកដាក់ចំពោះគ្រួសារ ដូចលោកយ៉ូសែប បានយកចិត្តទុកដាក់ថែរក្សាក្រុមគ្រួសារទោះបីជាគ្មានកន្លែងសម្រាកត្រឹមត្រូវក៏ដោយ។ មានការទទួលខុសត្រូវខ្ពស់ ដោយស្តាប់ និងអនុវត្តតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ដូចឪពុកម្តាយព្រះយេស៊ូដែលបានស្តាប់ និងអនុវត្តតាម ដើម្បីឲ្យព្រះបន្ទូលដឹកនាំជីវិតប្តីប្រពន្ធជាមួយព្រះកុមារយេស៊ូគ្រប់ពេលវេលា និងយកចិត្តទុកដាក់អប់រំណែនាំ ដើម្បីឲ្យកូនរីកចម្រើនតាមព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ជានិច្ច។

លោកអភិបាល ក៏បានជំរុញទៀតថា យើងមានគម្រោងការមួយយ៉ាងពិសេស គឺអប់រំណែនាំកូនចៅ ដោយអាចចាក់គ្រឹះបន្តិចម្តងៗតាមគ្រួសារនីមួយៗ ដើម្បីឲ្យកូនស្រី និងកូនប្រុសចូលបម្រើក្នុងព្រះសហគមន៍ និងឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់។

លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ផ្តាំផ្ញើដល់ឪពុកម្តាយទាំងអស់ទៀតថា "ប្រសិនបើកូនចង់ធ្វើជាបូជាចារ្យ បងប្រុស បងស្រី សូមកុំបដិសេធចំពោះកូន"។ លោកមានប្រសាសន៍យ៉ាងដូច្នេះ គឺដើម្បីឲ្យមានយុវជនយុវនារីអាចឆ្លើយតបទៅនឹងការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដើម្បីបម្រើព្រះសហគមន៍ប្រទេសកម្ពុជា ដែលជាហេតុលោកបង្កើតឲ្យមានការអធិដ្ឋានដើម្បីការត្រាស់ហៅ ជារៀងរាល់ដើមខែនីមួយៗតាមមណ្ឌលសកម្មភាពនានានៃភូមិភាគភ្នំពេញនាឆ្នាំ២០១២កន្លងមក។ លោកក៏បានប្រកាសផងដែរថា ការអធិដ្ឋានលើកក្រោយគឺធ្វើនៅមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង និងបន្តរហូតលើកទី១០០យ៉ាងតិច។

ដោយ ដាលីស

# និស្សិតទេវវិទ្យាល័យ សិលា សុខ ធឿន ទទួលមុខងារថ្លែងព្រះបន្ទូល

ព្រះវិហារព្រះកុមារយេស៊ូបឹងទំពុន នៃមណ្ឌលសកម្មភាពភ្នំពេញខាងត្បូង បានរៀបចំពិធីបុណ្យអភិបូជាប្រកាសទទួលបងប្រុស សិលា សុខ ធឿនឲ្យបំពេញមុខងារជាអ្នកប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់តាមប្រពៃណីព្រះសហគមន៍កាតូលិក ដែលជាជំហានទីពីរមុននឹងទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ ក្រោមអធិបតីភាព លោកអភិបាលអូលីវីយេ ឝ្មីតអីស្លែរ និងមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ កាលពីថ្ងៃទី១០ ធ្នូ ២០១៧។

នៅក្នុងថ្ងៃនោះដែរ លោកអភិបាលអូលីវីយេ ក៏បានបង្ហាញអំពីអត្ថបទព្រះគម្ពីរដំណឹងល្អដែលនិយាយអំពីលោកយ៉ូហានបាទីស្ត ដែលបង្ហាញព្រះយេស៊ូឲ្យគេស្គាល់ រួចលោកបានណែនាំគ្រីស្តបរិស័ទទាំងអស់ ជាពិសេសបងប្រុសធឿន ឲ្យអនុវត្តតាមលោកយ៉ូហានបាទីស្ត ដោយយកចិត្តទុកដាក់ប្រកាសពីព្រះបន្ទូលដែលបានចាប់កំណើតជាមនុស្ស។

លោកបន្តថា បេសកកម្មរបស់យើងដែលត្រូវធ្វើប្រចាំថ្ងៃគឺ សម្តែងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ លោកអូលីវីយេ ក៏បានបង្ហាញអំពីរបៀបនៃការសម្តែងធម៌មេត្តាករុណានេះផងដែរគឺ ត្រូវប្រកាសដំណឹងល្អអំពីព្រះយេស៊ូដែលកំពុងតែយាងមក និងធ្វើដំណើរជាមួយយើងឲ្យអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត។ បងប្រុសធឿនត្រូវប្រកាសដំណឹងល្អយ៉ាងពិសេសតាមរបៀបរស់នៅជាគ្រីស្តបរិស័ទ។ លោកបញ្ជាក់ថា ដំណឹងល្អមិនមែនជារឿងអាថ៌កំបាំងដើម្បីរក្សាទុកនៅក្នុងដួងចិត្ត តែត្រូវប្រកាសឲ្យមនុស្សទាំងឡាយបានឮ។ ត្រូវយល់ថា កន្លែងណាដែលមានព្រះបន្ទូលរបស់ព្រះជាម្ចាស់ កន្លែងនោះគឺជាទ្រព្យសម្បត្តិរបស់យើង។ លោកអភិបាលបានលើកយកគំរូដែលលោកយ៉ូហានបាទីស្តបានប្រកាសដំណឹងល្អនៅតាមវាលរហោស្ថាន គឺប្រៀបដូចទៅនឹងដួងចិត្តដែលគិតរវល់តែរឿងលោកិយ មិនបានបង្កើតទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ដូច្នេះត្រូវទៅប្រកាសដំណឹងល្អឲ្យមនុស្សទាំងនេះ ដើម្បីឲ្យពួកគេបានទទួលពន្លឺនៅក្នុងដួងចិត្ត។ ត្រូវយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលទៅក្នុងដួងចិត្ត និងស្តាប់ជារៀងរាល់ថ្ងៃដើម្បីឲ្យព្រះបន្ទូលចិញ្ចឹមជីវិតយើង ដោយកែប្រែចិត្តគំនិត និងទុកពេលដើម្បីឲ្យព្រះបន្ទូលកែប្រែសមត្ថភាពរបស់យើង តាមរបៀបដែលយើងបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗ។

បន្ទាប់ពីធម្មទេសនា លោកអភិបាលអូលីវីយេបានអធិដ្ឋានទូលសូមអង្វរព្រះជាម្ចាស់ប្រទានព្រះពរដល់ បេក្ខជន សុខ ធឿន ដើម្បីបំពេញមុខងារជាអ្នកថ្លែងព្រះបន្ទូលតាមរយៈការបម្រើព្រះជាម្ចាស់អស់ពីដួងចិត្ត អស់ពីជំនឿ អស់ពីសេចក្តីស្រឡាញ់ និងដោយស្មោះត្រង់ជានិច្ច។

និស្សិតទេវវិទ្យាល័យ សុខ ធឿន ក៏បានប្រកាសឡើងទទួលព្រះគម្ពីរពីលោកអភិបាលអូលីវីយេ និងមានប្រសាសន៍នៅចុងបញ្ចប់ពិធីបុណ្យលើកតម្កើង និងអរព្រះគុណថា "ខ្ញុំមានកិត្តិយសដែលបានទទួលជំហានទីពីរ ក្នុងនាមជាកូនសិស្សលោកអភិបាល ដើម្បីបន្តទៅកាន់ជីវិតជាបូជាចារ្យ។ បងប្រុសបន្តថា មានថ្ងៃនេះក៏ដោយសារទទួលបានការយល់ព្រមទាំងបីគឺ ខ្លួនឯង ទេវវិទ្យាល័យ និងលោកអភិបាល។ លោកថា នេះបង្ហាញថា លោកអភិបាលបានយកចិត្តទុកដាក់ និងគិតគូដល់ព្រះសហគមន៍ជានិច្ច។ បងប្រុស ក៏បានសំណូមពរសូមឲ្យគ្រីស្តបរិស័ទទាំងអស់បន្តអធិដ្ឋានសម្រាប់រូបលោក និងនិស្សិតទេវវិទ្យាល័យដើម្បីសម្រេចជីវិតនៅក្នុងការត្រាស់ហៅជាបូជាចារ្យដើម្បីបម្រើព្រះសហគមន៍។

*សរសេរដោយ ដាលីស*



*ថតដោយ សុធីរិទ្ធ*

# ព្រះសហគមន៍ចំប៉ា ប្រារព្ធបុណ្យរំឮកដល់ឧបការី ( សន្ត ហ្វ្រង់ស្វ័រសាវីយ៉េ )

រូបសំណាកសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ ត្រូវបានព្រះវិហារសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ ព្រះសហគមន៍ចំប៉ា នៃមណ្ឌលសកម្មភាពទន្លេមេគង្គ បានរៀបចំដង្ហែយ៉ាងឱឡារិក នៅក្នុងភូមិចំប៉ា ក្នុងស្រុកកៀនស្វាយ ខេត្តកណ្តាល។ កម្មវិធីនេះធ្វើឡើងក្រោមអធិបតីភាព លោកអភិបាលអូលីវីយេ កាលពីថ្ងៃទី៣ ធ្នូ ២០១៧ ដោយមានគ្រីស្តបរិស័ទចូលរួមជាច្រើនកុះករ។

មុននឹងប្រារព្ធពិធីបុណ្យអភិបូជា ព្រះសហគមន៍បានរៀបចំរូបសំណាកសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ និងដង្ហែដោយមានចម្រៀង ព្រមទាំងមានបាចផ្កានៅតាមផ្ទះនីមួយៗនៅភូមិចំប៉ា ដើម្បីអរព្រះគុណព្រះជាម្ចាស់ និងអរគុណដល់សន្ត ហ្វ្រង់ស្វ័រសាវីយ៉េដែលបានជួយថែរក្សាដល់អស់បងប្អូនដែលរស់នៅក្នុងភូមិចំប៉ា។

នៅក្នុងធម្មទេសនា លោកអភិបាលអូលីវីយេ បានមានប្រសាសន៍រំឭកអំពីប្រវត្តិរបស់សន្ត ហ្វ្រង់ស្វ័រសាវីយ៉េ ដែលជាគំរូរបស់គ្រីស្តបរិស័ទ ដោយមានគំនិតមកប្រកាសដំណឹងល្អនៅក្នុងតំបន់អាស៊ីជាពិសេសនៅប្រទេសចិន តែគាត់មិនបានចូលទៅប្រកាសដំណឹងល្អអំពីព្រះជាម្ចាស់នៅប្រទេសចិនទេ តែគាត់បានទៅកាន់ប្រទេសជប៉ុន និងមានទំនាក់ទំនងល្អជាមួយអាជ្ញាធរជប៉ុន រហូតដល់មានគ្រីស្តបរិស័ទជប៉ុនប្រមាណជាសាមសិបម៉ឺននាក់ ដែលក្នុងនោះមានគ្រីស្តបរិស័ទជាច្រើនមានជំនឿរឹងមាំតាមរយៈ ការណែនាំរបស់លោកបូជាចារ្យ ហ្វ្រង់ស្វ័រសាវីយ៉េ រហូតក្លាយជាមរណសាក្សី។

លោកអភិបាលបន្តថា ព្រះជាម្ចាស់បានទៅសួរសុខទុក្ខប្រជាជនជប៉ុនតាមរយៈសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ ដើម្បីឲ្យពួកគេមានជំនឿរឹងមាំ ហើយសព្វថ្ងៃព្រះជាម្ចាស់បានមកសួរសុខទុក្ខយើងតាមផ្ទះនីមួយៗ។ លោកបានបន្ថែមថា សម្រាប់រដូវរង់ចាំនេះ សូមឲ្យយើងរៀបចំចិត្តគំនិតដោយសម្អាតខាងក្នុងដើម្បីទទួលព្រះជាម្ចាស់ដែលយាងមកសួរសុខទុក្ខយើង ដូចព្រះយេស៊ូមានព្រះបន្ទូលថា "ចូរប្រុងស្មារតី ដោយអធិដ្ឋានជានិច្ច"។

លោកអូលីវីយេ បានជំរុញនិងលើកទឹកចិត្តគ្រីស្តបរិស័ទទាំងអស់ឲ្យយកគំរូតាមសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ ទោះបីជាបានស្លាប់មុនគោលដៅទៅប្រទេសចិន តែមួយជីវិតរបស់គាត់បានឈ្នះឧបសគ្គដោយមានសេចក្តីសង្ឃឹមជានិច្ច។ លោកបានផ្តាំផ្ញើទៅបងប្អូនគ្រីស្តបរស័ទ ទាំងអស់ឲ្យមានអំណរសប្បាយដោយបម្រើ និងមានសេចក្តីសង្ឃឹមជានិច្ច។

នៅក្នុងកម្មវិធីបុណ្យដ៏ឱឡារិកនេះផងដែរ ព្រះវិហារសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ ក៏មានរៀបចំឲ្យកុមារដែលមានអាយុ១១ឆ្នាំដល់១៥ឆ្នាំ ទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្តលើកដំបូងផងដែរ ដោយកុមារទាំងនោះជាកូនរបស់គ្រីស្តបរិស័ទ និងបានទទួលអគ្គសញ្ញាជ្រមុជទឹកតាំងពីតូច។

ព្រះសហគមន៍ចំប៉ា តែងតែប្រារព្ធពិធីរំឭកដល់សន្ត ហ្វ្រង់ស្វ័រសាវីយ៉េ ជារៀងរាល់ឆ្នាំ ដោយអធិដ្ឋាន ទូលអង្វរព្រះជាម្ចាស់តាមរយៈសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ និងជឿថាសន្តនេះបានជួយការពារថែរក្សាអ្នកភូមិនេះពិតមែន និងដាក់ស្តែងសន្ត ហ្វ្រង់ស្វ័រសាវីយ៉េ បានជួយកុំឲ្យមានការបាក់ដីច្រាំងទន្លេនាកាលពីប៉ុន្មានឆ្នាំកន្លងទៅនេះ។

*ដោយ ដាលីស*



*ថតដោយៈ អន់ ហំ*

# ប្រធានាធិបតីអាមេរិក គាំទ្រការរើរដ្ឋធានីអ៊ីស្រាអែល

លោក ដូណាល់ ត្រាំ ជាប្រធានាធិបតីអាមេរិកទីមួយ ដែលប្រកាសទទួលស្គាល់ជាផ្លូវការនូវការរើរដ្ឋធានី របស់ប្រទេសអ៊ីស្រាអែល មកកាន់ទីក្រុង យេរូសាឡឹម។

ការសម្រេចទទួលស្គាល់របស់លោកត្រាំថា ទីក្រុង យេរូសាឡឹម ជារដ្ឋធានីថ្មីរបស់អ៊ីស្រាអែលនេះបាន បង្កឱ្យផ្ទុះការរិះគន់ស្ទើរទូទាំងពិភពលោក។

លោកប្រធានាធិបតី ដូណាល់ ត្រាំ បានទទួលស្គាល់ទីក្រុង យេរូសាឡឹមដ៏ចម្រូងចម្រាស់ ជារដ្ឋធានីរបស់អ៊ីស្រាអែលកាលពីថ្ងៃពុធទី៦ ខែធ្នូ ឆ្នាំ២០១៧ ដោយជំរុញឱ្យមានការរិះគន់ផ្នែកការទូតស្ទើរតែពេញសកលលោក និងការបារម្ភអំពីការបង្ហូរឈាមជាថ្មីនៅមជ្ឈិមបូព៌ា។

យេរូសាឡឹម គឺជាទីក្រុងដ៏ប្រទាញប្រទង់រវាង អ៊ីស្រាអែល និង រដ្ឋប៉ាឡេស្ទីន ហើយលោកត្រាំ ជាប្រធានាធិបតីទីមួយ នៅក្នុងអំឡុង៧ទសវត្សរ៍ដែលបានសម្រេចគាំទ្រគោលនយោបាយ អ៊ីស្រាអែល នៅក្នុងការប្តូររដ្ឋធានីពីទីក្រុង តេអាវីវ មកយេរូសាឡឹម។

លោក ត្រាំ បានប្រកាសពីសេតវិមានថា "អ៊ីស្រាអែលជាប្រទេសអធិបតេយ្យភាពដែលមានសិទ្ធិដូចប្រជាជាតិដែលមានអធិបតេយ្យភាពដទៃទៀតដែរ ដើម្បីកំណត់រដ្ឋធានីរបស់ខ្លួន"។

ត្រាំបាន និយាយថា "វាជាពេលវេលាដើម្បីទទួលស្គាល់ទីក្រុង យេរូសាឡិមជារដ្ឋធានីរបស់អ៊ីស្រាអែលជាផ្លូវការ"។ គាត់ហានអំពាវនាវឱ្យមានភាពស្ងប់ស្ងាត់ និង "សំឡេងនៃការអត់ឱនដើម្បីយកឈ្នះលើចិត្តស្អប់"។

ក្រុមអ្នកការទូតបាននិយាយថា ប្រទេសចំនួន ៨ រួមទាំងចក្រភពអង់គ្លេស បារាំង និងអ៊ីតាលី បានទទួចឱ្យមានកិច្ចប្រជុំបន្ទាន់មួយនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដើម្បីឆ្លើយតបទៅនឹងចំណាត់ការរបស់ត្រាំនេះ។

# ប្រធានាធិបតីរុស្ស៊ីនៅក្នុងតំណែងប្រកាសបន្តឈររឈ្មោះជាប្រធានាធិបតីមួយអាណត្តិទៀត

លោក វ្លាឌីមៀរ ពូទីន ប្រធានាធិបតីរុស្ស៊ីបាននិយាយកាលពីថ្ងៃទី៦ ធ្នូថា លោកនឹងស្វែងរកតំណែងជាប្រធានាធិបតីមួយអាណត្តិទៀតពីការបោះឆ្នោតនៅឆ្នាំក្រោយ។

លោកបានធ្វើការប្រកាសបែបនេះ នៅក្នុងសុន្ទរកថាមួយទៅកាន់កម្មករនៅរោងចក្រផលិតរថយន្តមួយនៅទីក្រុងនីស្នី នូវហ្គោរ៉ូដ (Nizhny Novgorod)។

លោកវ្លាឌីមៀរ ពូទីន បាននិយាយថា "ខ្ញុំនឹងដាក់បេក្ខភាពសម្រាប់តំណែងប្រធានាធិបតី"។

លោកវ្លាឌីមៀរ ពូទីន បានឡើងកាន់អំណាចនៅរុស្ស៊ីចាប់តាំងពីឆ្នាំ២០០០មក ដោយធ្លាប់កាន់តំណែងជា ប្រធានាធិបតី និងជានាយករដ្ឋមន្ត្រី។

ប្រសិនបើលោកឈ្នះនៅក្នុងការបោះឆ្នោតដែលគេគ្រោងនឹងរៀបចំនៅខែមីនានោះ លោកនឹងធ្វើជាប្រធានាធិបតីរហូតដល់ឆ្នាំ២០២៤។

# អង្គការសហប្រជាជាតិបញ្ឈប់ការផ្តល់ជំនួយម្ហូបអាហារដល់កុមារកូរ៉េខាងជើង

កម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិបានប្រកាសបញ្ឈប់ការដឹកជញ្ជូនស្បៀងអាហារទៅឱ្យកូរ៉េខាងជើង បើទោះបីជាជំនួយភាគច្រើនទាំងនោះ គឺសម្រាប់កុមារនិងទុរគ្គតជនដែលអត់ឃ្លាននៅក្នុងប្រទេសនេះក៏ដោយ។

ការសម្រេចចិត្តនេះកើតឡើងចំពេលមានភាពតានតឹងកាន់តែកើនឡើងដែលពាក់ព័ន្ធនឹងកម្មវិធីនុយក្លេអ៊ែររបស់កូរ៉េខាងជើង ប៉ុន្តែទោះយ៉ាងនេះក្តី អង្គការកម្មវិធីស្បៀងអាហារពិភពលោកបានបដិសេធហេតុផលនេះ ដោយបាននិយាយថាការសម្រេចចិត្តនេះ គឺសុទ្ធតែទាក់ទងនឹងការខ្វះមូលនិធិជំនួយ។

កាសែតកូរ៉េ កូរ៉េថែម បានរាយការណ៍ឱ្យដឹងថា កុមារចំនួន១៩០.០០០នាក់ នៅប្រទេសកូរ៉េខាងជើងបានពឹងផ្អែកលើជំនួយនេះ ដែលទើបតែត្រូវបានផ្អាកនេះ។ កម្មវិធីស្បៀងអាហារពិភពលោកនេះ បានអះអាងថាការខ្វះលុយបាន ធ្វើឱ្យការផ្តល់ផ្គង់ជំនួយនេះមិនអាចធ្វើទៅរួច។

លោក លីម យ៉ុងជុន ប្រធានកម្មវិធីស្បៀងអាហារកូរ៉េ បាននិយាយថា កម្មវិធីស្បៀងអាហារនេះត្រូវការប្រមូលប្រាក់ឱ្យបានចំនួន២៥,៥លានដុល្លារដើម្បីអាចផ្តល់អាហារដល់កុមារ និងក្រុមងាយរងគ្រោះដទៃទៀតនៅប្រទេសកូរ៉េខាងជើងសម្រាប់រយៈពេល៦ខែបន្ទាប់។ ឥឡូវនេះ កម្មវិធីស្បៀងអាហារនេះ មានលុយតែពាក់កណ្តាលប៉ុណ្ណោះនៃចំនួនលុយសរុបនេះ៕

# ប្រទេសចំនួន៤៩ បានរំលោភការសម្រេចដាក់ទណ្ឌកម្មលើកូរ៉េខាងជើង

ប្រភពព័ត៌មានបរទេសបានរាយការណ៍ថា មានប្រទេសជាច្រើនរួមទាំងប្រទេសមហាអំណាយនៅ លោកខាងលិចផងដែរ គឺបានរំលោភនឹងការសម្រេចដាក់ទណ្ឌកម្ម លើប្រទេសកូរ៉េខាងជើង។

ក្រុមអ្នកជំនាញដែលមានមូលដ្ឋាននៅទីក្រុងវ៉ាស៊ីនតោន បាននិយាយថា ប្រទេសរាប់សិបមិនបានអនុវត្តឱ្យបានពេញលេញនូវការដាក់ទណ្ឌកម្មជាអន្តរជាតិដែលត្រូវបានដាក់ទៅលើប្រទេសកូរ៉េខាងជើងនោះទេ។

ក្រុមអ្នកជំនាញនៃវិទ្យាស្ថានវិទ្យាសាស្ត្រ និងសន្តិសុខអន្តរជាតិនេះបាននិយាយនៅលើគេហទំព័ររបស់ខ្លួន កាលពីថ្ងៃអង្គារទី៥ ខែធ្នូថា សរុបចំនួន៤៩ប្រទេស ដែលរួមទាំង ប្រទេសចិន អាល្លឺម៉ង់ ប្រេស៊ីល ឥណ្ឌា និងបារាំងផងដែរនោះ ត្រូវគេរកឃើញថាបានរំលោភលើក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិរវាងខែមីនា ឆ្នាំ២០១៤ និងខែកញ្ញា ឆ្នាំ២០១៧។

ឯកសារនេះ បានបង្ហាញថា ប្រទេសចំនួន១៣នៅក្នុងបញ្ជីឈ្មោះប្រទេសទាំងនេះ គឺរួមបញ្ចូលទាំងប្រទេសគុយបា អ៊ីរ៉ង់ មីយ៉ាន់ម៉ា និងស៊ីរី បានជាប់ពាក់ព័ន្ធក្នុងទម្រង់នៃការដោះដូរលើវិស័យយោធាជាមួយកូរ៉េខាងជើង។

របាយការណ៍នេះបានកើតឡើងចំពេលដែលមានការគាំទ្រច្រើនឡើងពីសហគមន៍អន្តរជាតិចំពោះការដាក់ទណ្ឌកម្មលើកូរ៉េខាងជើង៕

# ប្រធានអង្គការប្រឆាំងនុយក្លេអ៊ែរជាម្ចាស់ពានរង្វាន់ណូបែលសន្តិភាពឆ្នាំនេះ

ជ័យលាភីពានរង្វាន់ណូបែលសន្តិភាពនាឆ្នាំនេះត្រូវបានធ្លាក់ទៅលើប្រធាននៃអង្គការយុទ្ធនាការអន្តរជាតិដើម្បីលុបបំបាត់អាវុធនុយក្លេអ៊ែរ ក្រោយពេលដែលសង្គ្រាមនុយក្លេអ៊ែរ ក្លាយជាប្រធានបទដ៏ក្តៅគគុករវាងអាមេរិក និងកូរ៉េខាងជើង។

លោកស្រី ប៊ីទ្រីស ហ្វាញ ប្រធានអង្គការនេះ បានប្រាប់ទីភ្នាក់ងារសារព័ត៌មានបារាំង ប៉ុន្មានម៉ោងមុនពិធីប្រគល់ពានរង្វាន់ណូបែលនេះថា "ឥឡូវនេះយើងកំពុងមើលឃើញស្ថានភាពគ្រោះថ្នាក់បំផុតដែលធ្វើឱ្យមនុស្សជាច្រើនមិនស្រួលចិត្ត"។

លោកស្រី ប៊ីទ្រីស ហ្វាញ បានបន្ថែមថា "ប៉ុន្តែប្រសិនបើអ្នកមានការព្រួយបារម្ភអំពីលោកដូណាល់ ត្រាំ ដែលមាននុយក្លេអ៊ែរ ឬលោក គីម ជុងអ៊ុន អ្នកប្រហែលជាព្រួយបារម្ភអំពីអាវុធនុយក្លេអ៊ែរ ពីព្រោះអ្នកទទួលស្គាល់ថា ប្រព័ន្ធរាំងស្កាត់មិនមែនចេះតែមានប្រសិទ្ធភាពទេ"។

មេដឹកនាំអាមេរិក និងកូរ៉េខាងជើង "គ្រាន់តែជាមនុស្សដែលមានការគ្រប់គ្រងដើម្បីបញ្ចប់ពិភពលោកនេះ គ្មាននរណាផ្សេងអាចធ្វើរឿងនេះបានឡើយ"។

រដ្ឋាភិបាលក្រុងព្យុងយ៉ាងកាលពីប៉ុន្មានខែថ្មីៗនេះបានបង្កើនការសាកល្បងមីស៊ីល និងនុយក្លេអ៊ែរ ខណៈផ្តោះផ្តងការគំរាមកំហែងវោហាសាស្ត្រសង្គ្រាមជាមួយលោកដូណាល់ ត្រាំ ដែលបានបញ្ជាឱ្យមានការបង្ហាញកម្លាំងយោធាជាបន្តបន្ទាប់។

អង្គការនេះ ជាអង្គការចម្រុះនៃអង្គការក្រៅរដ្ឋាភិបាលរាប់រយនៅជុំវិញពិភពលោក បានប្រឹងប្រែងដើម្បីឱ្យមានសន្ធិសញ្ញាហាមឃាត់អាវុធនុយក្លេអ៊ែរ ដែលត្រូវបានអនុម័តកាលពីខែកក្កដា ដោយប្រទេសចំនួន ១២២។ ទោះបីជាមានសន្ធិសញ្ញានេះជាប្រវត្តិសាស្ត្រក្តី ក៏ប៉ុន្តែវាត្រូវបានធ្វើឱ្យចុះខ្សោយ ដោយសារអវត្តមាននៃមហាអំណាចនុយក្លេអ៊ែរចំនួន ៩ ក្នុងចំណោមប្រទេសហត្ថលេខីទាំងអស់៕

# យេរូសាឡឹម ទឹកដីកណ្តាលនៃទំនាស់រវាងអ៊ីស្រាអែល និងពិភពអារ៉ាប់



ការប្រកាសទទួលស្គាល់ទីក្រុងយេរូសាឡឹមថា ជារដ្ឋធានីរបស់ប្រទេសអ៊ីស្រាអែល កាលពីពេលថ្មីៗនេះ បានបណ្តាលឲ្យ ពិភពលោកជាពិសេស គឺពិភពអារ៉ាប់ រង្គោះរង្គើឡើង ដោយសារតែទីក្រុងបុរាណ មួយនេះគឺជាទីក្រុងមួយដ៏ចំណាស់បំផុត នៅមជ្ឈឹមបូព៌ា ដែលនៅពេលនេះ ទាំង អ៊ីស្រាអែលក៏ចង់បាន ហើយពលរដ្ឋប៉ាឡេស្ទីនក៏ចង់បាន ហើយសុទ្ធតែអះអាង ថា ទីក្រុងនេះ ជារដ្ឋធានីរបស់ពួកគេ រៀងៗខ្លួន ។

ជុំវិញបញ្ហានេះយោងទៅតាមការផ្សាយ របស់កាសែតអង់គ្លេស ហ្គាឌៀន បានឲ្យ ដឹងថា នេះគឺជា ភាពក្លាហានមួយរបស់ រដ្ឋបាលលោក ដូណាល់ ត្រាំ នៅក្នុងការ អះអាងថា អាមេរិក នឹងរើស្ថានទូត របស់ ខ្លួនទៅកាន់ទីក្រុងនេះ ខណៈដែលរដ្ឋ សភាអាមេរិក បានអនុម័តវាមកតាំងតែ ពីឆ្នាំ១៩៩៥មកនោះ។

មានការអះអាងថា ទីក្រុងយេរូសាឡឹម គឺជារដ្ឋធានីរបស់ ជនជាតិជ្វីប ដែលជា ម្ចាស់ប្រទេសអ៊ីស្រា អែល តាំងតែពី ៣០០០ ឆ្នាំមុន ហើយក្រោយមក រដ្ឋបាល លោក ប្រធានាធិបតីអាមេរិក បារ៉ាក់ អូបាម៉ា បាន ទទួលស្គាល់ទីក្រុងនោះត្រឹមតែជារដ្ឋធានី ស្រមោលសម្រាប់ជនជាតិជ្វីប និងប៉ាឡេស្ទីន ។

ទីក្រុងយេរូសាឡឹម ត្រូវបានគេអះអាង ថា គឺជាទីក្រុងដ៏ពិសិដ្ឋនៃជំនឿសាសនា ៣ ជាពិសេស ពីសំណាក់ជនជាតិជ្វីប(ជន ជាតិយូដាក្នុងគម្ពីរគ្រីស្តសាសនា) ប៉ុន្តែ ជនជាតិអារ៉ាប់មិនដែលបានអនុវត្តទេ នៅ ពេលដែលគេបានគ្រប់គ្រង ទីក្រុងនេះ រវាងឆ្នាំ១៩៤៨ ដល់ឆ្នាំ១៩៦៧។ មាន ការអះអាងថា ជនជាតិប៉ាឡេស្ទីន បាន អះអាងថា ទីក្រុងនេះ គឺជារដ្ឋធានីរបស់ ពួកគេ ជាគំនិតគ្មានមូលដ្ឋានប្រវត្តិសាស្ត្រ ដោយសារ តែពួកគេ មិនមានវត្តមាន ឬ មិនមានជាតិនៅក្នុងប្រវត្តិសាស្ត្រ។ ម្យ៉ាង វិញទៀត ប៉ាឡេស្ទីនគឺ បាត់សមាជិក ដោយ សារតែសកម្មភាពរបស់ពួកគេផ្ទាល់។ ការ អះអាងថា ទីក្រុងនេះ ជារដ្ឋធានីរបស់ខ្លួន គឺក្រោយពេលដែលមានការពិភាក្សាសន្តិភាព រវាងអ៊ីស្រាអែល និងប៉ាឡេស្ទីន ហើយ នៅពេលនោះ ទើបប៉ាឡេស្ទីនបានអះ អាងថា ទីក្រុងយេរូសាឡឹម ខាងកើត ជារដ្ឋធានីរបស់ខ្លួន។ ជាការពិតចលនា នៃការទាមទារនោះគឺជាយូរ រវាងអ៊ីស្រា អែល និងប៉ាឡេស្ទីន។ អ៊ីស្រាអែល ត្រូវបាន គេដឹងថា គឺមានដែនដីតាំងតែពី យុគសម័យលោហៈ ហើយរាជាណាចក្រជន ជាតិជ្វីបដែលជាម្ចាស់ប្រទេស អ៊ីស្រាអែល បានបង្កើតប្រទេសឯករាជ្យនៅរង្វង់ឆ្នាំ ១១០ មុនគ្រីស្តសករាជ ប៉ុន្តែបានបាត់បង់ វិញនៅក្នុងរង្វង់ឆ្នាំ ៦៣មុនគ្រីស្តសករាជ ដោយជនជាតិអារ៉ាប់ ដែលសម័យកាល នោះគឺខ្លាំងក្លា។

ចាប់តាំងពីមិនមានប្រទេស ជនជាតិ ជ្វីបគឺបានរស់នៅពាសពេញពិភពលោក រហូតក្លាយជាជនជាតិដែលរងគ្រោះច្រើន ជាងគេនៅក្នុងអំឡុងសម័យសង្គ្រាមលោក លើកទីពីរ ហើយក្រោយមក ពោលគឺ ក្រោយសង្គ្រាមបញ្ចប់ ពួកគេក៏បានរួបរួម គ្នា បង្កើតជាប្រទេសឯករាជ្យមួយនៅក្នុង ឆ្នាំ១៩៤៨ ហើយបានបដិសេធការដឹកនាំ របស់ជនជាតិអារ៉ាប់ពីដែនដីប៉ាឡេស្ទីន ចាប់ពីពេលនោះមក។ បន្ទាប់ពីប្រកាស ឯករាជ្យទឹកដីនៃតំបន់វេសបេង និងហ្គាសា គឺនៅក្រោមការកាន់កាបរបស់បណ្តារដ្ឋ ជិតខាងនៅអារ៉ាប់ទេ ប៉ុន្តែក្រោយសង្គ្រាម ជាច្រើនលើកជាច្រើនសារជាមួយនឹងបណ្តា ប្រទេសនៅអារ៉ាប់នៅឆ្នាំ១៩៦៧ អ៊ីស្រាអែល បានពង្រីកទឹកដីពីវេសបេងទៅ ហ្គោលដែនហាយ ហើយទៅដល់តំបន់ ហ្គាសាស្ទ្រីបថែមទៀត ។

តាមឯកសារ បន្ទាប់ពីនោះមក អ៊ីស្រាអែល និងអារ៉ាប់ក៏មានទំនាស់ជាច្រើន ថ្នាក់រដ្ឋនិងរដ្ឋខណៈដែលពលរដ្ឋអារ៉ាប់ ដែលធ្លាប់រស់នៅដែនដីប៉ាឡេស្ទីន ក៏បាន ចាប់ផ្តើមមានទំនាស់នឹងគ្នា ស៊ីសាច់ហុត ឈាម ដោយជនជាតិអារ៉ាប់ ដែលគេដឹង ថា ធ្លាប់រស់នៅ ប៉ាឡេស្ទីននេះ បានទាមទារ បង្កើតរដ្ឋរបស់គេដែរ ជាហេតុបណ្តាល ឲ្យមាន ទំនាស់ជាហូរហែ រហូតដល់ឆ្នាំ ២០០៥ អ៊ីស្រាអែល ក៏បានចាប់ផ្តើម ពិចារណា ផ្តល់ទឹកដីមួយចំនួន នៅហ្គាសាស្ទ្រីប ជូនជនជាតិអារ៉ាប់ឡើងវិញ ។

ចាប់តាំងពីបង្កើតប្រទេសនេះឡើងវិញ នៅឆ្នាំ១៩៤៨ មកដល់បច្ចុប្បន្ននេះ អ៊ីស្រាអែល គឺចង់បានទីក្រុងនេះ ធ្វើជារដ្ឋធានីរបស់ខ្លួន រហូតដល់មានការប្រកាស ទទួលស្គាល់ពីរដ្ឋបាលលោកប្រធានាធិបតី អាមេរិក ដូណាល់ ត្រាំ កាលពីថ្ងៃទី០៨ ខែធ្នូ ថ្មីនេះ ខណៈដែលពលរដ្ឋប៉ាឡេស្ទីន ក៏ចង់បាន ទីនោះជារដ្ឋធានីរបស់ខ្លួនដែរ នៅពេលដែលខ្លួនមានប្រទេស។

គួររំឭកថា ទីក្រុងយេរូសាឡឹម នេះ គឺ ជាទីក្រុងបុរាណមួយ ប៉ុន្តែទីក្រុងនេះ ត្រូវ បានដណ្តើមទៅ ដណ្តើមមក ប្រហែលជា ២០ដង តាំងតែពីឆ្នាំ៣០០០មុនគ្រីស្ត សករាជមកនោះ។ ក្រោយមករហូតដល់ ឆ្នាំ៩៦០ មុនគ្រីស្តសករាជ ព្រះវិហា បុរាណរបស់ជនជាតិជ្វីបទីមួយ ត្រូវបាន គេដឹងថា បានកសាងនៅទឹកដីនោះ ប៉ុន្តែ ក្រោយមក ក៏មានការដណ្តើមកាន់កាប់ ពី រាជាណាចក្របុរាណជាច្រើនរាប់ទាំងចក្រភព បាប៊ីឡូន រ៉ូម៉ាំង អូតូម៉ង់... ហើយជន ជាតិជ្វីបបានចូលមករស់នៅទីក្រុងនេះ ទៅ វិញទៅមករហូតដល់មានប្រទេស។ ក្រោយ មកនៅឆ្នាំ១៩១៧ ទីក្រុងនោះ ត្រូវបាន អាណានិគមអង់គ្លេសចាប់យកវិញម្តង។ ក្រោយមក នៅឆ្នាំ១៩៤៨ ក្រោយពេល ដែលអ៊ីស្រាអែល បង្កើតប្រទេស ក៏បាន កាន់កាប់ចែកគ្នារវាងអ៊ីស្រាអែល និងហ្សកដង់ ហើយនៅឆ្នាំ១៩៦៧ អ៊ីស្រាអែល បានកាន់កាន់ទាំងអស់តែម្តង ដោយរួម ទាំងភាគខាងកើតដែលគ្រប់គ្រងដោយ ហ្សកដង់ផងដែរ។ ប្រជាជនអារ៉ាប់នៅ ក្នុងទីក្រុងនេះ អាចរស់នៅទីនោះបាន ប៉ុន្តែ ពួកគេមិនមានប្រជាជាតិនឹងគេនោះទេ។

*ដោយអរិយបុត្រ*



# សម្តេចប៉ាបជំរុញឲ្យមន្ទីរពេទ្យផ្តោតសំខាន់លើសេចក្តីស្រឡាញ់ជាងការរកប្រាក់ចំណេញ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បាននិយាយថាការថែរក្សារបស់ព្រះសហគមន៍ចំពោះអ្នកជំងឺជាពិសេសតាមមន្ទីរពេទ្យកាតូលិកគឺជាដំណោះស្រាយមួយចំពោះ "គំនិតអាជីវកម្មនៅទូទាំងពិភពលោក ដែលកំពុងបង្វែរការថែទាំសុខភាពទៅជាសហគ្រាសរកប្រាក់ចំណេញ"។

នៅក្នុងសាររបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ សម្រាប់ទិវាពិភពលោកសម្រាប់អ្នកជំងឺនាថ្ងៃទី១១ កុម្ភៈ ២០១៨ សម្តេចប៉ាប បានជំរុញឱ្យគ្រីស្តបរិស័ទកាតូលិកជាបុគ្គល និងសហគមន៍បន្តផ្តល់សេវាថែទាំសុខភាពដោយក្តីស្រឡាញ់ចំពោះអ្នកជំងឺ។ តាមសារព័ត៌មានកាតូលិកញូវ ស៊ីវីស បានឲ្យដឹងថា ព្រះសហគមន៍កំណត់យកថ្ងៃបុណ្យរំឭកព្រះនាងម៉ារីនៅទីក្រុងលួដ (Lady of Lourdes)ជារៀងរាល់ឆ្នាំសម្រាប់បារព្ធទិវាអ្នកជំងឺនេះ។ ហើយសម្រាប់ឆ្នាំ២០១៨ នេះ សម្តេចប៉ាប បានផ្តោតអារម្មណ៍យ៉ាងខ្លាំងនិងសង្កត់ធ្ងន់លើគោលគំនិតបេសកកម្មរបស់ព្រះសហគមន៍ ក្នុងការលើកកម្ពស់ផ្លូវវិញ្ញាណ និងសេចក្តីត្រូវការផ្នែកសីរៈរបស់មនុស្ស។

ក្នុងសារនោះ សម្តេចប៉ាបបានអធិស្ឋានថា "សូមឱ្យការអធិស្ឋានរបស់យើងចំពោះមាតានៃព្រះសង្គ្រោះ ស្តាប់ពាក្យ អង្វររបស់យើងរាល់គ្នា គឺសូមឲ្យសមាជិកគ្រប់រូបនៃព្រះសហគមន៍រស់នៅដោយមានសេចក្តីស្រឡាញ់នៃការបម្រើជីវិត និងសុខភាពសម្រាប់មនុស្សជាតិ"។ សារព័ត៌មានដដែលបានបន្តថា សម្តេចប៉ាបបានសម្តែងការព្រួយបារម្ភរបស់ព្រះនាងម៉ារីដែលជាម្តាយរបស់ព្រះសហគមន៍ចំពោះអ្នកជំងឺតាំងពីដើមរៀងមក រហូតដល់បច្ចុប្បន្ននេះ។

សម្តេចប៉ាបបានមានប្រសាសន៍ទៀតថា "នៅប្រទេសដែលមានប្រព័ន្ធថែរក្សាសុខភាពសាធារណៈគ្រប់គ្រាន់ កិច្ចការរបស់បព្វជិត-ជិតា និងភូមិភាគរបស់ព្រះសហគមន៍ និងមន្ទីរពេទ្យរបស់ពួកគេ មានគោលបំណងមិនត្រឹមតែផ្តល់ការថែទាំសុខភាពដែលមានគុណភាពនោះទេ ប៉ុន្តែថែមទាំងផ្តល់នូវសារៈសំខាន់នៃភាពជាមនុស្សក្នុងដំណើរការព្យាបាលផងដែរ ទោះជាការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រក៏ត្រូវគោរពយ៉ាងពេញលេញចំពោះតម្លៃជីវិត និងសម្រាប់សីលធម៌ជាគ្រីស្តបរិស័ទ"។ សម្តេចប៉ាបបន្ថែមទៀតថា ទោះបីក្នុងប្រទេសដែលប្រព័ន្ធថែទាំសុខភាពមិនមានគ្រប់គ្រាន់ ព្រះសហគមន៍ក៏ត្រូវព្យាយាមធ្វើអ្វីដែល អាចធ្វើបានដើម្បីកែលម្អសេវាសុខភាព, លុបបំបាត់អត្រាស្លាប់របស់ទារកនិងប្រយុទ្ធប្រឆាំងនឹងជំងឺរីករាលដាល។ នៅក្នុងប្រទេសអ្នកមាននិងអ្នកក្រ គឺមិនខុសគ្នាទេ ព្រះសហគមន៍ បានផ្តោតលើការថែទាំអ្នកជម្ងឺ សូម្បីតែពេលមិនអាចព្យាបាលបានក៏ដោយ។ សម្តេចប៉ាបបានដាស់តឿនស្ថាប័នថែទាំសុខភាពកាតូលិក និងគ្រូពេទ្យបុគ្គលិក គិលានុបដ្ឋាយិកា និងសមាជិកបុគ្គលិកឱ្យចងចាំប្រពៃណីរបស់ព្រះសហគមន៍ក្នុងការថែរក្សាអ្នកជម្ងឺ និងបន្តការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការបន្តការបម្រើបែបនេះ។ សម្តេចប៉ាបក៏មិនភ្លេចដែរ ចំពោះសេចក្តីស្រឡាញ់ដ៏ទន់ភ្លន់ និងការតស៊ូរបស់គ្រួសារជាច្រើនក្នុងការថែទាំកុមារពិការ ដូចជាឪពុកម្តាយនិងសាច់ញាតិរបស់ពួកគេ។ ការថែទាំដែលផ្តល់ឱ្យនៅក្នុងគ្រួសារគឺជាសាក្សីដ៏អស្ចារ្យនៃសេចក្តីស្រឡាញ់ចំពោះមនុស្សជាតិ។ វាចាំបាច់ត្រូវបានទទួលស្គាល់ និងគាំទ្រដោយគោលនយោបាយសមស្រប"។

# មូលនិធិពាន់លានដុល្លារបំរុងសម្រាប់ការបម្រែបំម្រួលអាកាសធាតុ

កាលពីថ្ងៃទី១២ ធ្នូ ២០១៧នេះ កម្មវិធីបរិស្ថានរបស់អង្គការសហប្រជាជាតិ និងធនាគារដ៏ធំក្នុងពិភពលោក BNP Paribas បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ នៅឯកិច្ចប្រជុំពិភពមួយដើម្បីបង្កើតគ្រឹះស្ថានហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ដោយផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិការ អភិវឌ្ឍមូលធន ជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងបណ្តាប្រទេសកំពុងរីកចម្រើន។

តាមរយៈគេហទំព័របម្រែប្រួលអាកាសធាតុនៃអង្គការសហប្រជាជាតិបានឲ្យដឹងថា អង្គការសហប្រជាជាតិ ផ្នែកបរិស្ថាន និងធនាគារធំលំដាប់ពិភពលោក BNP Paribas នឹងសហការគ្នាដើម្បីកំណត់នូវគម្រោងពាណិជ្ជកម្មសមស្រប ជាមួយនឹងផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គមដែលអាចវាស់វែងដោយគោលដៅនៃការផ្តល់មូលធនចំនួន ១០ ពាន់លានដុល្លារនៅត្រឹមឆ្នាំ ២០២៥ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។

BNP គឺជាក្រុមហ៊ុនធនាគារផ្តល់សេវាហិរញ្ញវត្ថុ និងជាធនាគារបារាំងមួយដែលមានទីស្នាក់ការធំនៅទីក្រុងប៉ារីស ហើយ Paribas មានការិយាល័យកណ្តាលនៅទីក្រុងឡុងដ៍។ BNP Paribas វាត្រូវបានបង្កើតឡើងតាមរយៈការច្របាច់បញ្ចូលគ្នារវាង Banque Nationale de Paris និង Paribas ក្នុងឆ្នាំ ២០០០ និងជាធនាគារមួយក្នុងចំណោមធនាគារធំបំផុតនៅក្នុងពិភពលោក។

គេហទំព័រដដែលនេះ ឲ្យដឹងទៀតថា គោលបំណងរបស់អង្គការសហប្រជាជាតិ និងធនាគាលំដាប់ពិភពលោកនេះ គឺដើម្បីគាំទ្រដល់គម្រោងតូចៗដែលទាក់ទងទៅនឹងការទទួលបានថាមពលកកើតឡើងវិញ កសិកម្មព្រៃឈើ ប្រព័ន្ធទឹក និងរបបកសិកម្មប្រកបដោយនិរន្តរភាពផ្សេងៗទៀត។

កម្មវិធីទ្រទ្រង់ហិរញ្ញវត្ថុនិរន្តរភាព គឺជាកិច្ចសហប្រតិបត្តិការដំបូងគេបង្អស់រវាងសហគមន៍វិនិយោគិន ដៃគូផ្នែកអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដោយមានការគាំទ្រពីរដ្ឋាភិបាលជាតិ។

អគ្គលេខាធិការអង្គការសហប្រជាជាតិ លោក អាន់តូនីញ៉ូ ហ្គូតេរ៉េស (Antonio Guterres) បានមានប្រសាសន៍លើtwitter របស់លោកកាលពីថ្ងៃម្សិលមិញផងដែរ ថា ហិរញ្ញវត្ថុ គឺជាគន្លឹះមួយជំរុញឲ្យសកម្មភាពតយុទ្ធនឹងការប្រែប្រួលអាកាសធាតុបានទទួលជោគជ័យ។

មហិច្ឆិតារបស់យើង គឺចង់ឲ្យការប្រែប្រួលអាកាសធាតុវិលទៅរកភាពប្រក្រតីឲ្យបានលឿនជាងការគិត ហើយនេះក៏ជាសង្គ្រាមដែលយើងមិនអាចចាញ់បានឡើយ។ កិច្ចព្រមព្រៀងនេះត្រូវបានបង្កើតឡើងលើគម្រោង ហិរញ្ញប្បទានតំបន់ត្រូពិចដែលជាកិច្ចសហការរវាងអង្គការសហប្រជាជាតិផ្នែកបរិស្ថាន ធនាគារ BNP Paribas មជ្ឈមណ្ឌលកសិកម្មព្រៃឈើពិភពលោក និងស្ថាបនមូលធនADM ន ប្រទេសឥណ្ឌូណេស៊ី។

# អភិបូជាជាកម្លាំងប្រកាសដំណឹងល្អ

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានថ្លែងកាលពីថ្ងៃទី១៣ ខែធ្នូក្នុងអំឡុងពេលជួបជាមួយមហាជនទូទៅប្រចាំសប្តាហ៍ ក្នុងសាលប្រជុំ ប៉ូលទី៦ ថា "តើយើងមិនអាចអនុវត្តតាមដំណឹងល្អ ដោយគ្មានកម្លាំងពិធីអរព្រះគុណ ឬ អភិបូជានោះទេ"។

សម្តេចប៉ាបបានមានប្រសាសន៍ថា "យើងមិនទៅអភិបូជាដើម្បីថ្វាយអ្វីមួយដល់ព្រះទេ ប៉ុន្តែយើងទៅគឺដើម្បីទទួលបានពីព្រះអង្គនូវអ្វីដែលយើង ត្រូវការយ៉ាងពិតប្រាកដ"។ ពិធីអភិបូជានៅថ្ងៃអាទិត្យគឺជាពេលវេលា និងទីកន្លែងដែលគ្រីស្តបរិស័ទ ទទួលព្រះករុណាទិគុណ និងកម្លាំងដើម្បីរក្សាជំនឿចំពោះព្រះបន្ទូលព្រះអង្គហើយអនុវត្តតាមដោយស្រឡាញ់អ្នកដទៃហើយជាសាក្សីអំពីសេចក្តីទាំងអស់នេះក្នុងលោកីយ។ ក្នុងពេលនោះសម្តេចប៉ាបក៏បានឆ្លើយតបទៅនឹងសំណួរថា ហេតុអ្វីបានជាវាសំខាន់ណាស់ក្នុងការទៅអភិបូជានៅថ្ងៃអាទិត្យ ព្រោះបានរស់នៅក្នុងសីលធម៌ល្អ និងស្រឡាញ់អ្នកដទៃហើយនោះ? លោកបានថ្លែងថាអភិបូជាថ្ងៃអាទិត្យមិនមែនគ្រាន់តែជាកាតព្វកិច្ចនោះទេ។ "យើងជាគ្រីស្តបរិស័ទចាំបាច់ត្រូវចូលរួមក្នុងពិធីអភិបូជាថ្ងៃអាទិត្យ ដោយសារតែព្រះគុណរបស់ព្រះយេស៊ូគ្រីស្តដែលគង់ជាមួយយើង និងក្នុងចំណោមយើង នោះយើងអាចអនុវត្ត តាមព្រះបន្ទូល និងធ្វើជាសាក្សីរបស់ព្រះអង្គផងដែរ"។ ក្នុងពេលនោះ សម្តេចប៉ាបក៏បានមានប្រសាសន៍ទៅកាន់អ្នកនិយាយភាសាអារ៉ាប់ថា "ដូចជារុក្ខជាតិត្រូវការព្រះអាទិត្យ និងអាហារបំប៉នឱ្យមានជីវិត។

ចំពោះគ្រីស្តបរិស័ទគ្រប់គ្នាក៏ត្រូវការថ្ងៃអាទិត្យដើម្បីអរសប្បាយក្នុងជីវិត"។

# គ្រីស្តបរិស័ទកម្ពុជាចូលរួមទទួលដំណើរទស្សនកិច្ចសម្តេចប៉ាបនៅប្រទេសភូមា




តំណាងគ្រីស្តបរិស័ទ តាមមណ្ឌលសកម្មភាពភ្នំពេញ តំណាងគ្រីស្តបរិស័ទនៃព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង រួមទាំងលោកបូជាចារ្យ និងដូនជីមួយចំនួនផង ចំនួន១២៥នាក់ ដឹកនាំដោយលោកអភិបាលអូលីវីយេ បានធ្វើដំណើរទៅប្រទេសភូមា នាយប់ថ្ងៃទី២៦ ខែវិច្ឆិកាកន្លងទៅ ដើម្បីទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ និងធ្វើបូជនីយេសន៍ទៅសក្ការដ្ឋានមួយចំនួនផង។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ មកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅប្រទេសភូមាពីថ្ងៃទី២៧-៣០ ខែវិច្ឆិកា ឆ្នាំ២០១៧។

ក្នុងដំណើរនៅប្រទេសភូមា ក្រុមទាំងអស់បានទៅទស្សនកិច្ចនៅទេវវិទ្យាល័យវិសាលវិហារ (អសនៈវិហារ) ក្រុងយ៉ាងហ្គោន ព្រះវិហារសន្តសិលា និងសន្តប៉ូលក្នុងក្រុងយ៉ាងហ្គោន។ ធ្វើបូជនីយេសនៅសក្ការដ្ឋាននៃព្រះនាងម៉ារីល្អដ៏ នៅក្នុងខេត្តមួយ មានចំងាយប្រមាណជាង ១៦០ គីឡូម៉ែត្រពីក្រុងយ៉ាងហ្គោន។

នៅថ្ងៃទី២៧ខែវិច្ឆិកា ក្រុមទាំងអស់រួមទាំងលោកអភិបាល បានឈរអមតាមផ្លូវទទួលស្វាគមន៍ ដំណើរមកដល់របស់សម្តេចប៉ាប។

នៅតាមកន្លែងនីមួយៗ ដូចជានៅទេវវិទ្យាល័យក្រុមទាំងអស់បានទទួលអំពីព័ត៌មាន និងឈ្វេងយល់អំពីស្ថាភាពនៃការអប់រំក្នុងទេវវិទ្យាល័យ និងអំពីស្ថានភាពការត្រាស់ហៅនៅក្នុងព្រះសហគមន៍កាតូលិកនៅភូមា ដែលបានរៀបរាប់និងធ្វើសក្ខីកម្មដោយលោកបូជាចារ្យនាយកទេវវិទ្យាល័យផ្ទាល់។

លោកបានចែក រំលែកអំពីជីវិតនៃព្រះសហគមន៍កាតូលិកក្នុងប្រទេសភូមា និងអំពីរបៀបដែលដំណឹងល្អបានទៅដល់ប្រជាជនក្នុងប្រទេសនេះ ដែលធ្វើឲ្យមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីគ្រីស្តបរិស័ទកម្ពុជា។ ក្នុងនោះដែរក៏មានជួបលោកអភិបាលពីរអង្គ និងលោកបូជាចារ្យមួយចំនួន។

ក្នុងដំណើរទស្សនកិច្ចនេះលោកអភិបាលអូលីវីយេបានមានប្រសាសន៍ថា ក្រុមបានចូលរួម ទទួលស្វាគមន៍សម្តេចប៉ាបតាមដងផ្លូវ ចូលរួមអភិបូជាជាមួយសម្តេចប៉ាបនៅថ្ងៃទី២៩ នៅទីវាល និងថ្ងៃទី៣០ ចូលរួមអភិបូជាជាមួយសម្តេចប៉ាបម្តងទៀតនៅវិសាលវិហារ ដែលជាអភិបូជាសម្រាប់យុវជននៅភូមា។ លោកអភិបាលបន្តថា សម្រាប់យើងជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ជាឱកាសមួយពិសេស ដែលយើងបានជួបជាមួយសម្តេចប៉ាប ដែលជាតំណាងរបស់ព្រះយេស៊ូនៅលើផែនដីនេះ ដែលជាអ្នកការពារថែរក្សាជំនឿរបស់យើង និងណែនាំឲ្យព្រះសហគមន៍ទៅជាអង្គតែមួយក្នុងអង្គព្រះគ្រីស្ត។

ហេតុនេះពេលយើងជួបជាមួយសម្តេចប៉ាបនៅភូមាហាក់បីដូចជាព្រះសហគមន៍កម្ពុជាជួបជាមួយសម្តេចប៉ាបផ្ទាល់ដែរ។ លោកថា ពិតណាស់យើង១២៥នាក់ ដែលជាតំណាងពីព្រះសហគមន៍ និងកន្លែងនីមួយៗ ចូលក្នុងមហាគ្រួសារព្រះសហគមន៍កាតូលិកធំណាស់។ គ្រួសារនេះដែលសម្តេចប៉ាបបានលើកទឹកចិត្ត ផ្តល់កម្លាំង ឲ្យបន្តប្រកាសដំណឹងល្អ ដើម្បីឲ្យយើងយកចិត្តទុកដាក់ធ្វើជាសាក្សីនៃធម៌មេត្តាករុណា ជាពិសេសសម្រាប់អ្នកតូចតាច។

លោកអភិបាលក៏បានលើកឡើងនូវបន្ទូលរបស់សម្តេចប៉ាបក្នុងពេលជួបជាមួយបងប្អូនគ្រីស្តទូទៅ និងជួបជាមួយយុវជនថា "ចូរយើងធ្វើជាសក្សី នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ និងការសម្រុះសម្រួល"។

ដូច្នេះសម្រាប់យើងជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជា ពេលមកប្រទេសកម្ពុជាវិញ នៅតាមកន្លែងនីមួយៗត្រូវយកចិត្តទុកដាក់ណែនាំប្រជាជន គ្រីស្តបរិស័ទឲ្យចេះសហការណ៍គ្នា យល់ចិត្តគ្នាដើម្បីកសាងប្រទេសយើង។ យើងមាន អំណរសប្បាយយ៉ាងពេញលក្ខណៈ និងសូមអរព្រះគុណព្រះជាម្ចាស់ ដែលបានប្រទានអំណោយទានតាមរយៈសម្តេចប៉ាប តាមរយៈព្រះពររបស់សម្តេចដល់យើងដែរ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅប្រទេសភូមាកាលពីថ្ងៃទី២៧-៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ហើយលោកបន្តដំណើរទៅប្រទេសបង់ក្លាដេសរហូតដល់ថ្ងៃទី២ ធ្នូ។ ចំពោះក្រុមប្រតិភូតំណាងកម្ពុជាបានធ្វើដំណើរត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី៣០ ខែវិច្ឆិកា ប្រកបដោយអំណរសប្បាយ និងសុវត្ថិភាព។

*ដោយ លី សុវណ្ណា*



# កម្រងរូបភាពគ្រីស្តបរិស័ទកម្ពុជា ចូលរួមទទួលដំ























# ណើរទស្សនកិច្ចសម្តេច ប៉ាប នៅប្រទេសភូមា

















# ទស្សនៈពលរដ្ឋចម្រុះអំពីស្ថានភាពសង្គមក្រោ

ក្រោយពេលគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងតែមួយគត់មាននៅក្នុងសភា កើតចេញពីការបោះឆ្នោតកាលពីឆ្នាំ២០១៣ ត្រូវបានរំលាយនៅក្រោមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក្រោយពេលដែលអាជ្ញាធរបានរកឃើញថា គណបក្សនេះបានឃុបឃិតជាមួយនឹងបរទេសជាប្រព័ន្ធដើម្បី បង្កអំពើក្បត់ជាតិ តាមរយៈសាលដីការតុលាការកំពូលរបស់ប្រទេសកាលពីថ្ងៃទី១៦ វិច្ឆិកា ២០១៧ ពលរដ្ឋកម្ពុជាភាគច្រើនយល់ថា នេះគឺជាការអនុវត្តច្បាប់របស់កម្ពុជា គ្រាន់តែភាគច្រើនចេះតែព្រួយបារម្ភរឿងសំពាធពីអន្តរជាតិ និងផលប៉ះពាល់ដល់ជីវភាពរបស់ពួកគេតែ ប៉ុណ្ណោះ។

លោក ជា ពិសី ជាអាជីវករមួយរូបបាននិយាយថា នេះគឺជាការអនុវត្តច្បាប់។ គណបក្សសង្គ្រោះជាតិធ្វើខុស គឺត្រូវតែទទួលខុសត្រូវ។លោកបានសំដែងយោបល់ទៀតថា គណបក្សមួយនេះគិតតែប្រឆាំងខ្លាំងពេក ប៉ុន្តែសូម្បីតែថ្នល់មួយចង្អាមក៏ធ្វើមិនបានផង ម៉្យាងវិញទៀតគេធ្វើអ្វីមិនដែលចេះត្រូវ ដូច្នេះរំលាយក៏រំលាយទៅ ។

លោក ពិសី មិនបានពន្យល់វែងឆ្ងាយច្រើនទេ ដោយសារតែលោកជាប់ធុរៈ និងមមាញឹកនៅក្នុង អាជីវកម្មរកស៊ីប្រចាំថ្ងៃរបស់គាត់ ប៉ុន្តែអាជីវករផ្សេងៗមួយចំនួនទៀតក៏មានយោបល់ស្រដៀងគ្នា នេះផងដែរ គ្រាន់តែអ្នកខ្លះព្រួយបារម្ភរឿងបាតុកម្ម រឿងសន្តិសុខ និងសុវត្ថិភាពសង្គម ដែលអាចកើតមានជាយថាហេតុមកលើពួកគេក្រោយការសម្រេចរបស់អាជ្ញា-ធរបែបនេះ។

អ្នកស្រី ហុង សុខហៀង ជាអាជីវករមួយរូបទៀតក៏បានសំដែងយោបល់ថា លោកស្រីក៏អត់មានការសោកស្តាយអ្វីដែរ ចំពោះចំណាត់ការផ្លូវច្បាប់របស់អាជ្ញាធរកម្ពុជា មកលើអតីតគណបក្សប្រឆាំងនៅក្នុងប្រទេសមួយនេះ ។

លោកស្រីបានបញ្ជាក់ថា "ឲ្យវាអីចឹងចុះ ព្រោះគណបក្សអ្វីដឹកនាំឲ្យតែប្រជាពលរដ្ឋឈ្លោះតែគ្នាចឹង។ គេរំលាយចោលចឹងសមហេតុសមផល ខ្ញុំគាំទ្រ"។

លោកស្រី សុខហៀង ដែលជាអាជីវករមួយរូបនៅក្នុងផ្សារមួយនៅ ស្រុកកៀនស្វាយ ខេត្តកណ្តាល បានថ្លែងបន្ត ទៀតថា ពេលដំបូងដូចជាព្រួយបារម្ភដែរ ប៉ុន្តែក្រោយការរំលាយដូចជាគ្មានអ្វីកើតឡើងផង ហើយសង្គមដូចជានៅតែដដែល។

លោកស្រីបានបញ្ជាក់ថា "ទោះបីរំលាយអីចឹងក៏ខ្ញុំ អត់មានឃើញប្រជា-ពលរដ្ឋណាជ្រួលច្របល់ ក្តៅក្រហាយអីផង។ ដូចជាអត់ឃើញមានអ្វីផង ព្រោះអីខ្ញុំអង្គុយលក់ដូរធម្មតា ដូចអត់មានរឿងអ្វីកើតឡើងផង"។

លោកស្រីបានថ្លែងបន្តថា នេះប្រហែលជាដោយសារប្រជាពលរដ្ឋមើលឃើញថា គណបក្សប្រឆាំង អត់មានចេះស្រលាញ់ប្រទេសជាតិ គិតតែញុះញ៉ង់ឲ្យខ្មែរហើយនឹងខ្មែរឈ្លោះគ្នាចឹង ហើយទៅ ទៅចូលដៃចូលជើងជាមួយបរទេសដើម្បីធ្វើបាបខ្មែរគ្នាឯងចឹង។

លោកស្រីបានថ្លែងទៀតថា លោកស្រីក៏អត់មានត្រូវដូរចិត្តអត់ទៅបោះឆ្នោតអីដែរ។ លោកស្រីនឹងទៅ បោះឆ្នោត គ្រាន់តែថាពេលអត់គណបក្សប្រឆាំងដូចជាហេងហាង។

លោកស្រីបានបញ្ជាក់ថា "ជាធម្មតាប្រទេសត្រូវតែមានគណបក្សប្រឆាំង ហើយពេលអត់មានគណបក្សប្រឆាំងអីចឹងដូចម៉េចទេ"។

លោកស្រីបានបញ្ជាក់ទៀតថា "ពេលខ្លះខ្ញុំចង់បានអ្នកប្រឆាំងដើម្បីឲ្យមានការរីកចម្រើន កុំឲ្យប្រឆាំងឲ្យទៅក្បត់ជាតិខ្លួនឯង ទៅលើកជើងបរទេសដើម្បីបំផ្លាញជាតិខ្លួនឯង ខ្ញុំអត់គាំទ្រទេគណបក្សអីចឹងៗទេ។ ខ្ញុំមិនមែនអត់ចង់ឲ្យមានគណបក្សប្រឆាំងទេ ប៉ុន្តែគួរតែឲ្យមាន ដើម្បីធ្វើអ្វីមកដើម្បីជួយជាតិជួយប្រទេសយើង មិនមែនឃុបឃិតនឹងបរទេសធ្វើបែបនេះទេ"។

លោកស្រីបានបញ្ជាក់ទៀតថា "ខ្ញុំចង់បានតែប៉ុណ្ណឹងទេ ខ្ញុំជាប្រជាពលរដ្ឋ ខ្ញុំគ្រាន់តែចង់បានអីចឹង ខ្ញុំអត់ចង់បានសង្គ្រាម ហើយខ្ញុំក៏ចង់បានសេចក្តីសុខប៉ុណ្ណោះ" ។

លោក សាញ់ ណារិទ្ធី ជាប្រជាពលរដ្ឋមួយរូប បានថ្លែងនៅក្នុងខេត្តសៀមរាប ខណៈបាននាំគ្រួសារ ដើរកំសាន្តនៅបរិវេណប្រាសាទអង្គរវត្តថា ព្រួយបារម្ភដែរពេលដែលគណបក្សប្រឆាំងត្រូវរំលាយ ប៉ុន្តែចេះអត់មានបញ្ហាអី ។

លោកបានបញ្ជាក់ថា "និយាយមិនភ័យ មិនបារម្ភម៉េច បើតាមផ្លូវឃើញសុទ្ធតែប៉ូលីស ទាហាន ហើយមានកាំភ្លើងប្រចូងប្រាង

### កម្ពុជាមិនត្រឡប់នៅរកប្រព័ន្ធនយោបាយឯកបក្សជាថ្មីឡើងវិញឡើយ

លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស បានបញ្ជាក់ជំហរកម្ពុជាជាញឹក-ញាប់នៅពេល ដែលជួបជាមួយនឹងបណ្តាភ្ញៀវបរទេស និងឯកអគ្គរដ្ឋទូតប្រទេសនានាថា កម្ពុជានឹងមិនត្រឡប់ ទៅរកនយោបាយឯកបក្សឡើយ ។

ជំហរអះអាងនេះ គឺតត្រូវបានលើកឡើងជាបន្តបន្ទាប់ដោយអ្នកនាំពាក្យក្រសួងការបរទេស នៅក្រោយពេលដែលលោក ប្រាក់ សុខុន បានទទួលជួបពិភាក្សាជាមួយនឹងតំណាង សហគមន៍អឺរ៉ុប និងឯកអគ្គរដ្ឋទូតមហាអំណាច និងម្ចាស់ជំនួយនានា ។

លោកបានបន្តថាកម្ពុជានឹងនៅតែប្រកាន់យកមាគ៌ាលទ្ធិប្រជាធិបតេយ្យពហុបក្ស ហើយនឹងរៀបចំ ការបោះឆ្នោតទៅតាមកាលបរិច្ឆេទដែលបានត្រៀមទុក ។

គួររំលឹកថា អាសនៈរបស់គណបក្សសង្គ្រោះជាតិទាំងនៅក្នុងសភា និងនៅឃុំ/សង្កាត់ នឹងត្រូវបែងចែកដោយគណៈកម្មាធិការជាតិរៀបចំបោះឆ្នោតប្រគល់ជូនគណបក្សដែលបានចូលរួមការបោះឆ្នោត ផ្អែកតាមច្បាប់។



រូបភាពឯកសារ ថតដោយ លី វណ្ណា

# យការរំលាយគណបក្សប្រឆាំង

ប៉ុន្តែអត់អីសភាពការណ៍ស្ងប់ស្ងាត់ ហើយឥឡូវនៅតែមានពលរដ្ឋ ធ្វើដំណើរទៅមក ដើរលេងទីនេះទីនោះ ជាប្រចាំ ។

អាជីវករជាម្ចាស់ហាងនំមួយរូប ដែលសុំមិនបញ្ចេញអត្តសញ្ញាណបានសំដែងការព្រួយបារម្ភថា សភាពការណ៍ចំពោះមុខ ចាប់តាំងពីក្រោយការរំលាយគណបក្សប្រឆាំងមកដល់ពេលនេះ គឺសភាពការណ៍ដូចជាមិនអីទេ គ្រាន់តែវារៀងស្ងាត់ជាងធម្មតា។

លោកបានបន្តថា អ្នកដំណើរ នៅតែធ្វើដំណើរដើរលេង ទៅនេះទៅនោះ ពេញតែផ្លូវ ទាំងថ្ងៃទាំងយប់ ដដែលទេ ប៉ុន្តែគ្រាន់តែរាងរឹតត្បិតលើការចំណាយបន្តិចប៉ុណ្ណោះ។

លោកបានបញ្ជាក់ថា "គ្មានដែលឃើញផ្លូវជាតិស្ងាត់ទេ មនុស្សធ្វើដំណើរទាំងថ្ងៃទាំងយប់ គ្មានទំនេរទេ តែគ្រាន់តែថា ដូចជាម្នាក់ៗរាងដូចជាមិនសូវហ៊ានចាយវាយច្រើនដូចពីមុន"។

លោកបានបន្តទៀតថា ចំណូលពីការលក់នៅហាងនំរបស់លោក ដូចជាមានការធ្លាក់ចុះ ដែលនេះ ជាបច្ច័យមួយ ដែលលោកកំពុងតែមានការព្រួយបារម្ភដែរ ដោយសារតែនៅហាងនំរបស់លោក មានបុគ្គលិកទាំងកម្មករ និងអ្នកលក់សរុប ជាង ២០ នាក់។ លោកបានបន្តថា ប្រសិនបើការលក់នេះ នៅតែបន្តធ្លាក់ចុះថែមទៀត មិនយូរទេ លោកក៏នឹងពិចារណាកាត់បន្ថយកម្មករនិងបុគ្គលិក មួយចំនួន ចេញខ្លះ។

លោកបានបញ្ជាក់ថា "វាលំបាកពន្យល់ណាស់ ប៉ុន្តែខ្ញុំអាចប្រៀបធៀបទៅបានអីចេះ កាលពីមុន(មុនការំលាយគណបក្ស) លក់អស់ ១០០នំអីចឹង ប៉ុន្តែឥឡូវដូចជាបានត្រឹមពី ៧០ ទៅ៨០នំប៉ុណ្ណោះ"។

លោក ស៊ីន ឧត្តម ជាប្រជាពលរដ្ឋមួយរូបផ្សេងទៀត បានបន្តចែករំលែកការព្រួយបារម្ភបន្តទៀតថា បើរំលាយអាជ្ញាធរចង់រំលាយគណបក្សណាទៀតក៏ដោយក៏ពលរដ្ឋហាក់ឆ្អែតឆ្អន់មិនរំជើបរំជួល និងទំនោរទៅតាមសភាពការណ៍ដូចជាពីមុន បន្តទៀតឡើយ ប៉ុន្តែអ្វីដែលយើងព្រួយបារម្ភគឺថា ខ្លាចរឿងសំពាធពីបរទេសពីព្រោះប្រទេសធំៗដែលជាតែទីផ្សារធំៗរបស់យើងកំពុងតែសម្លឹងមើល មកកាន់កម្ពុជា នៅក្នុងក្រសែភ្នែកមួយដែលកំពុងតែលំអៀងទៅរកចំណុចអវិជ្ជមាន។

លោកបានបន្តថា រឿងរំជើបរំជួលគឺថាគ្មានទេ ប៉ុន្តែអ្វីដែលយើងបារម្ភគឺខ្លាចអាមេរិក និងសហគមន៍អឺរ៉ុប គេបិទទីផ្សារយើង គឺចប់ហើយ ។

លោកបានបញ្ជាក់ថា "អារឿងនាំចេញស្រូវអង្ករ ម្រេចអីមិនប៉ុន្មានទេ តែយ៉ាប់ គឺយ៉ាប់រឿងអាទីផ្សារ រោងចក្រកាត់ដេរ "។

លោកបានបន្តថា ខាងរាជរដ្ឋាភិបាលប្រាកដជាដឹង ហើយប្រហែលមានវិធានការណ៍ ដែរហើយ ប៉ុន្តែយើងខ្ញុំព្រួយបារម្ភមែនទែន ពីព្រោះតែអាមេរិក និងសហគមន៍អឺរ៉ុប លុបចោលការអនុគ្រោះ ផ្សេងៗដើម្បីនាំចេញទៅទីផ្សារគេ គឺយ៉ាប់មែនទែន។

លោកបានបន្តថា មិនមែនជារឿងលេងសើចបានទេ មនុស្សរាប់ម៉ឺននាក់កំពុងតែបម្រើការនៅក្នុង វិស័យនេះ ហើយបើគេឈប់អនុគ្រោះដឹងតែយ៉ាប់តែម្តង ហើយបើវិស័យកាត់ដេរនេះមានបញ្ហានោះ។ បើពួកគេដួល អ្នកដែលទទួលផលពីពួកគេមានតាំងពីកន្លែងស្នាក់នៅ អាជីវកម្មជុំវិញតាមរោងចក្រ សូម្បីតែការដឹកជញ្ជូនក៏ប៉ះពាល់ដែរ ។

លោកបានបញ្ជាក់ថា "ចង់រាជរដ្ឋាភិបាលរំលាយគណបក្ស ប៉ុន្មានដងទៀតក៏ពលរដ្ឋមិនសូវជារំជើបរំជួលទេ ប៉ុន្តែបើប្រទេសធំៗគេយកទីផ្សាររបស់យើងមកធ្វើជាសំពាធមកលើយើងដឹងតែ ចប់ហ្មង"។

លោកបានបន្តថា "កម្មករឥឡូវមានរាប់សែននាក់ តែទីផ្សារមានបញ្ហា ពួកគាត់យ៉ាប់តែម្តង មិនដឹងបានការងារណាធ្វើទេ ហើយបើឲ្យទៅធ្វើស្រែឬចំការវិញប្រហែលក៏យ៉ាប់ដែរ ពីព្រោះឥឡូវនេះ អ្នកខ្លះលក់ដីលក់ស្រែកេរម៉ែចាយអស់ហើយ។ *ដោយ អរិយាបុត្រ*

### គណបក្សសង្គ្រោះជាតិត្រូវបានរំលាយក្រោយចាប់កំណើតបានជាង ៥ ឆ្នាំ

គណបក្សសង្គ្រោះជាតិដែលគេដឹងថា គឺជាគណបក្សនយោបាយមួយដែលបង្កើតឡើងដោយគណបក្សប្រឆាំងពីរ គឺគណបក្សសម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស កាលពីខែកក្កដា ឆ្នាំ២០១២ បានត្រូវរំលាយចោលនៅថ្ងៃទី ១៦ វិច្ឆិកា ២០១៧។

ការរំលាយនេះ ត្រូវបានធ្វើឡើងដោយតុលាការកំពូលនៃប្រទេសក្រោមបណ្តឹងរបស់ក្រសួងមហាផ្ទៃ ពីបទឃុបឃិតនឹងបរទេសជាប្រព័ន្ធប្រព្រឹត្តអំពើក្បត់ជាតិ បន្ទាប់ពីប្រធានគណបក្សនេះ ត្រូវបានចាប់ខ្លួននៅក្នុងករណីនេះ ។

ក្រៅពីការរំលាយគណបក្ស មន្ត្រី និងសមាជិកជាន់ខ្ពស់របស់គណបក្សនេះ សរុបចំនួន ១១៨ នាក់ ត្រូវបានតុលាការហាមឃាត់មិនឲ្យធ្វើនយោបាយ ៥ ឆ្នាំ ។

គណបក្សសង្គ្រោះជាតិនៅមុនពេលរំលាយត្រូវបានគេដឹងថា គឺមានសមាជិកសភាចំនួន ៥៥រូប ដែលទទួលបានពីការបោះឆ្នោតជាតិកាលពីខែកក្កដា ឆ្នាំ២០១៣ ប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ចំនួន ៤៨៩ នាក់ និងមានសមាជិកក្រុមប្រឹក្សាជាច្រើនទៀត កាលពីការបោះឆ្នោតកាលពីខែ មិថុនា ថ្មីៗនេះ ។

ការបោះឆ្នោតជាតិឆ្នាំ២០១៣ គណបក្សមួយនេះ បានទទួលសម្លេងគាំទ្រ ចំនួន ២,៩ លាន សន្លឹក ដោយទទួលបាន៥៥ អាសនៈនៅក្នុងចំណោមអាសនៈសភា ១២៣ ហើយនៅក្នុងការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត គឺទទួលបានអ្នកគាំទ្រប្រមាណជា ៣,០៥ លាន សម្លេង ដោយទទួលបានសមាជិកក្រុមប្រឹក្សានៅតាមឃុំទាំងអស់ទូទាំងប្រទេស។

# ព្រះសហគមន៍កាតូលិកទទួលព្រះវិហារចំណាស់នៅលើកំពូលភ្នំបូកគោ ពីរាជរដ្ឋាភិបាលកម្ពុជា



ថតដោយ

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងបរិស្ថាន បានប្រគល់ព្រះវិហារដ៏ចំណាស់មួយ នៅលើកំពូលភ្នំបូកគោ ឲ្យព្រះសហគមន៍កាតូលិកនៅកម្ពុជាមកគ្រប់គ្រង និងកាន់កាប់។ ពិធីប្រគល់ និងទទួលនេះ ត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៧កន្លងទៅនេះ នៅមុខព្រះវិហារចំណាស់នេះ ក្នុងមរណីដ្ឋានឧទ្យានជាតិព្រះមុនីវង្ស (បូកគោ) ក្រោមអធិបតីលោកសាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ដែលចុះហត្ថលេខាប្រគល់ និងទទួលរវាងលោក ជា សំអាង អគ្គនាយក នៃអគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន និងលោកអភិបាលអូលីវីយេ ឆ្មិតហាស្លេរ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ។

ព្រះសហគមន៍ទទួលព្រះវិហារចំណាស់នៅលើកំពូលភ្នំបូកគោពីរាជរដ្ឋាភិបាលស្របពេលដែលព្រះសហគមន៍កាតូលិកកម្ពុជា ប្រារព្ធពិធីបុណ្យព្រះយេស៊ូប្រសូតប្រកបដោយអំណរសប្បាយ។

លោកសាយ សំអាល់ បានមានប្រសាសន៍ថា រដ្ឋាភិបាលបានសម្រេចប្រគល់ព្រះវិហារ ឱ្យទៅព្រះសហគមន៍កាតូលិកវិញ ដើម្បីរៀបចំធ្វើការជួសជុល ឲ្យមានសម្រស់ឡើងវិញ សម្រាប់ការប្រតិបត្តិតាមជំនឿនៃព្រះសហគមន៍កាតូលិក។ លោករដ្ឋមន្ត្រីក៏បានណែនាំផងដែរ ដល់ព្រះសហគមន៍កាតូលិក និងអ្នកពាក់ព័ន្ធទាំងអស់ឲ្យយកចិត្តទុកដាក់ការពារថែរក្សាអភិរក្ស និងប្រើប្រាស់ទីសក្ការដ្ឋានបេតិកភណ្ឌធម្មជាតិ និងអភិរក្សជីវៈចម្រុះសម្រាប់ជាប្រយោជន៍ដល់អ្នកជំនាន់ក្រោយ។

លោកអភិបាលអូលីវីយេ មានប្រសាសន៍ឲ្យដឹងថា ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជា ពិតជាមានអំណរសប្បាយមានមោទនភាព និងជាកិត្តិយសណាស់ ដែលលោករដ្ឋមន្ត្រីក្រសួងបរិស្ថាន បានប្រគល់ព្រះវិហារចាស់នៅលើភ្នំបូកគោនេះដល់ព្រះសហគមន៍។ លោកអភិបាលព្រះសហគមន៍ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជាតាមរយៈលោករដ្ឋមន្ត្រីក្រសួងបរិស្ថាន។ លោកអភិបាលបញ្ជាក់ថា ការពិតកន្លែងនេះបានសាងសង់កាលពីទស្សវត្សឆ្នាំ១៩២០ បានប្រើប្រាស់ និងធ្វើសកម្មភាពរហូតដល់ឆ្នាំ១៩៧៥ ។

ក្នុងមួយទស្សវត្សចុងក្រោយនេះ ព្រះសហគមន៍កាតូលិកតែងតែសុំការអនុញ្ញាតប្រើព្រះវិហារនេះ មួយឆ្នាំ២ដង ក្នុងឱកាសបុណ្យធំៗ ដូចជាបុណ្យចម្លង និងបុណ្យភ្ជុំជាដើម។ ព្រះសហគមន៍ក៏បានប្រើព្រះវិហារនេះ សម្រាប់ការសំណាក់ធម៌សម្រាប់អធិដ្ឋាន និងថ្វាយអភិបូជា ។

លោកអភិបាលបន្តថា ក្នុងថ្ងៃបុណ្យព្រះយេស៊ូប្រសូត ព្រះសហគមន៍បានទទួលអំណោយ ពិសេសមួយពីរដ្ឋាភិបាលដែលបានប្រគល់ព្រះវិហារនេះមកព្រះសហគមន៍កាតូលិកប្រើប្រាស់ ទុកជាកន្លែងសម្រាប់ថ្វាយបង្គំ និងជាកន្លែងអាចណែនាំគ្រីស្តបរិស័ទឲ្យស្រឡាញ់ ការពារបរិស្ថាន។ ដោយទីនេះមានព្រៃឈើ មានផ្កា និងមានទេសភាពល្អៗ។ ជាកន្លែងមួយពិសេសដើម្បីឲ្យព្រះសហគមន៍អាចអនុវត្តន៍ទស្សនៈព្រះសហគមន៍យ៉ាងពិតប្រាកដ ដោយដឹងថាព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ និងពិភពលោក ហើយប្រគល់ឲ្យមនុស្សលោកការពារថែរក្សា និងអភិវឌ្ឍន៍។ លោកបន្តថា "នៅទីនេះជម្រុញឲ្យយើងត្រូវតែថែរក្សា និងស្រឡាញ់ធម្មជាតិតែម្តង"។

លោកបូជាចារ្យ ស្ទេផាន សែ សាត បានមានប្រសាសន៍ថា លោកពិតជាមានក្តីរំភើប និងអំណរសប្បាយខ្លាំងណាស់ ពេលទទួលដំណឹងនេះ។ អរគុណរាជរដ្ឋាភិបាលដែលបានប្រគល់វិហារនេះដល់ព្រះសហគមន៍។

អ្នកស្រី យូ ប្រាកដ ក៏បានសម្តែងក្តីរំភើប រកពាក្យថ្លែងមិនបាន ដោយគ្រាន់នឹកដល់ព្រះបន្ទូលនានារបស់ព្រះជាម្ចាស់ និងកោតសរសេរតម្កើងព្រះជាម្ចាស់ ចំពោះអំណោយពិសេសរបស់រាជរដ្ឋាភិបាលដល់ព្រះសហគមន៍កាតូលិក។ កិច្ចការលោកអភិបាលមុនៗបានខិតខំ និងលោកអភិបាលអូលីវីយេបានបន្ត ពេលនេះបានផលសម្រេចហើយ។ "ខ្ញុំអស់ចិត្តហើយ! មានអំណរខ្លាំងណាស់។ ទោះបីស្លាប់ក៏បិទភ្នែកជិតដែរ"។

លោក ស្រីដាំ ប្រាជ្ញា ជាគ្រីស្តបរិស័ទជំនាន់ដើមនៃព្រះសហគមន៍កាតូលិកបាត់ដំបង ដែលធ្លាប់បានស្គាល់ និងចេញចូលអធិដ្ឋាននៅព្រះវិហារនេះ តាំងពីសង្គមបានពោឲ្យថា ពេលដែលលោកស្រីទទួលដំណឹងភ្លាមរំភើបចិត្តខ្លាំងណាស់ ស្ទើរធ្លាក់ទូរស័ព្ទពីដៃ។ លោកស្រីក៏បានចែកអំណរសប្បាយទាំងនេះជាមួយកូនចៅផងដែរ។ ពួកគេសប្បាយរួមជាមួយលោកស្រីចំពោះដំណឹងដ៏ល្អនេះ។

លោកស្រីបានបន្តថា "ខ្ញុំធ្លាប់មកអធិដ្ឋាន ក្នុងព្រះវិហារនេះកាលពីប៉ុន្មានឆ្នាំមុន។ ខ្ញុំស្រក់ទឹកភ្នែក ពេលអធិដ្ឋាន ក្នុងព្រះវិហារដែលគេបោះបង់ចោលបែបនេះ។ ពិតជាសង្វេកណាស់ ទីធ្លាប់អ៊ូអរ និងពោរពេញដោយអំណរសប្បាយ ក្លាយទីស្ងាត់ជ្រងំ"។ លោកស្រីថា តែចាប់ពីពេលនេះតទៅ មានជីវិតថ្មីហើយ និងលែងស្ងាត់ទៀតហើយ។

នេះជាលើកទីមួយហើយ ដែលព្រះសហគមន៍កាតូលិកនៅកម្ពុជា បានទទួលមរតកចាស់ សល់ពីសម័យដើម ដែលខ្មែរក្រហមមិនបានបំផ្លាញចោល ពីរាជរដ្ឋាភិបាលកម្ពុជា។

*ដោយៈ លីសុវណ្ណា និងឡុង សម្ភស្ស*